# ឈ្វេងយល់ព្រះធម៌



# នាមអ្នកមានឧបការៈក្នុងការងារធម្មទាន

លោកម្ចាស់គ្រូ ជោតិធម្មោ ភួន់ ភ្លី លោកម្ចាស់ ម៉យ ប៊ុនឫទ្ធិ
លោកម្ចាស់ ខៀន សុង លោកម្ចាស់ វ៉ាងហ្វីហុង
លោកម្ចាស់ ធន នីន លោកម្ចាស់ ទូច ចន្ថា
លោកម្ចាស់ គង់ ច័ន្ទសុភ័ក្រ្ត លោកម្ចាស់ ធី ចាន់ណា
លោកម្ចាស់ ភុំ មុនីរ័ត្ន លោកម្ចាស់ ចាន់ សុផាត(Paris)
លោកម្ចាស់ ផែន សារឿត លោកគ្រូធម្មាចារ្យ ជឹម ជំនិត
អ្នកម្តាយ.គី វណ្ណហាក់ អ្នកម្តាយ.វ៉ែន សុភាវត្តី ឧបាសកឪពុក.ស្រី ចាន់ រី
អ្នកម្តាយ.ឡាយ ហ៊ុនគី អ្នកម្តាយ.ឈី ឈៀវគង់ អ្នកម្តាយ.ឡឹក លាប
អ្នកម្តាយ.ជា សៀវគៀង អ្នកម្តាយ.យ៉ាវ៉ារី អ្នកម្តាយ.ថង កែវវិមាន
អ្នកម្តាយ.ស៊ីវ អម្មារា អ្នកម្តាយ.ដួង មាស អ្នកម្តាយ.សាន គឹមស៊ាង
អ្នកម្តាយ.ឆាន់ គឹមឃី អ្នកម្តាយ.គាត ឆម អ្នកម្តាយ.ឈិត ស្រីស្រស់
អ្នកម្តាយ.អ៊ឹម ចាន់ណាក់អ្នកម្តាយ.អ៊ឹម ចាន់ណា អ្នកម្តាយ.គិម លាង
អ្នកម្តាយ.អួម សាលឿត អ្នកម្តាយ.ព្រេជ សាមុន អ្នកម្តាយ.សឿត សល់
អ្នកម្តាយ.គិម ចន្ថា(៣) បងស្រី. យី បូចាន់ អ្នកម្តាយ.ឡុង ផាន់នី
អ្នកម្តាយ.សឿត សល់ អ្នកម្តាយ.ស្រី អូន អ្នកម្តាយ.ទៀ
អ្នកម្តាយ.គួ ប៊ុនគាង អ្នកម្តាយ.លី គឹមយ៉េង អ្នកម្តាយ.ប៊ូ យ៉ុន
អ្នកម្តាយ.លឹម ចន្ថន ឧបាស.សា ចាន់រ៉ាត់ អ្នកម្តាយ.ហុង ធិន
អ្នកម្តាយ.សន សំណាង អ្នកម្តាយ.សែម អ្នកម្តាយ.ស្រី អូន
អ្នកម្តាយ.អ៊ឹម ចន្ថា អ្នកម្តាយ.ផេង យីម អ្នកម្តាយ.អ៊ឹម មួយ
អ្នកម្តាយ.ពិនឈុនហ៊ាង អ្នកម្តាយ.កែមចាន់ថុល អ្នកម្តាយ.យឿន លៀន
អ្នកម្តាយ.ហុក ណារី លោកឪពុក.យូណូស អាសីស ព្រមទាំងបុត្រ(paris)

ឈ្មោះសៀវភៅ : **ឈ្វេងយល់ព្រះធម៌**
រៀបរៀងដោយ : សក្យមុនីភិក្ខុអត្តគុត្តោ **សំ ស៊ីណាង**
វាយកុំព្យូទ័រដោយ : សក្យមុនីភិក្ខុអត្តគុត្តោ **សំ ស៊ីណាង**
រចនាក្របដោយ : ភិក្ខុ ជោតបញ្ញោ **ខៀន សុខ**
ផ្សាយចេញ : វត្តកំផែង ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ព្រះរាជាណាចក្រកម្ពុជា។
កាលបរិច្ឆេទធ្វើចប់ :១០រោជ ខែ ស្រាពណ៍ ព.ស.២៥៥៧
បោះពុម្ពលើកទី ១ : ..៥០០........ក្បាល
គោលបំណង : សម្រាប់ជាធម្មទានទូទៅ
ផ្តល់មតិយោបល់ : ០៧៧ ៦៦១ ០២០/ ០៨៨ ៧៧៩ ២ ៤៦៦

# អារម្ភកថា

ព្រះពុទ្ធសាសនាមានអាយុវែងឆ្ងាយមកដល់សព្វថ្ងៃនេះ ចាប់តាំងពីព្រះពុទ្ធអង្គទ្រង់បរិនិព្វានទៅ ដោយសារមនុស្សជំនាន់ក្រោយៗមានការសិក្សាទ្រទ្រង់បន្តជាប់មកមិនដាច់ និងមានសទ្ធាជឿមាំក្នុងពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះអង្គយ៉ាងនេះហើយ ទើបធ្វើឱ្យព្រះពុទ្ធសាសនាស្ថិតនៅជាទីពឹងទីរលឹកដ៏ប្រសើរសម្រាប់ពុទ្ធសាសនិកជន និងដើម្បីបង្ហាននាំយកមកជាគោល ក្នុងការរៀបចំដំណើរជីវិតប្រព្រឹត្តទៅបានយ៉ាងល្អបំផុតរហូតមក។

នេះគឺជាវណ្ណកម្មទីពីរដែលខ្ញុំបានរៀបរៀងបន្ទាប់អំពី សៀវភៅទីមួយដែលមានឈ្មោះថា **សិក្សាព្រះគាថានានា** សៀវភៅទីពីរនេះមានឈ្មោះថា **ឈ្វេងយល់ព្រះធម៌** ។

តាមពិតទៅ ការដែលយើងរស់នៅក្នុងព្រះសាសនានេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់សម្តែងអំពីជីវិតថាត្រូវបានសេចក្តីទុក្ខបៀតបៀន មានទុក្ខតាមផ្លូវកាយ ទុក្ខតាមផ្លូវចិត្ត។ដើម្បីរំលត់ទុក្ខនេះបាន មានតែអរិយមគ្គប្រកបដោយអង្គ៨ប្រការតែប៉ុណ្ណោះ ដែលអាចដឹកនាំសត្វលោកឱ្យរួចអំពីអបាយភូមិ។

សៀវភៅនេះមានឈ្មោះថា **ឈ្វេងយល់ព្រះធម៌** បានជាខ្ញុំដាក់ឈ្មោះឱ្យយ៉ាងនេះ ព្រោះមនុស្សម្នាក់ៗត្រូវការធម៌ ហើយពុទ្ធបរិស័ទខ្លះចង់ទៅសិក្សាណាស់នៅតាមទីកន្លែងផ្សេងៗ ប៉ុន្តែត្រង់អកុសលចិត្តមាននៅក្នុងសន្តានមិនព្រមលះបង់ចោលសោះ ចេះតែចង់ទៅសិក្សានៅ

កន្លែងនេះកន្លែងនោះ។

ពុទ្ធបរិស័ទគ្រប់គ្នាបានដឹងហើយថា សម្បត្តិសួគ៌និព្វានមិនមែនមានសម្រាប់បុគ្គលដែលមិនខិតខំប្រឹងប្រែងបំពេញបារមីនោះឡើយ។ សូមឱ្យព្រះធម៌ស្ថិតនៅក្នុងចិត្តរបស់ពុទ្ធបរិស័ទ សូមឱ្យចិត្តនៃពុទ្ធបរិស័ទមានព្រះធម៌ជាអាហារប្រចាំជីវិតដោយសេចក្ដីគោរពផងចុះ។

នៅទីបញ្ចប់នេះ ខ្ញុំនៅតែមិនអស់ចិត្តចង់បញ្ជាក់បន្ថែមថា អត្ថន័យទាំងស្រុងប្រាកដជាជៀសមិនផុតពីកំហុសឆ្គង ពាក្យពេចន៍ វេយ្យាករណ៍ អត្ថន័យ សេចក្ដីខ្វះខាតជាក់ជាមិនខាននោះទេ។ ដូច្នេះ សូមខន្តីអភ័យអត់នូវទោសានុទោសទាំងអស់ដែលកើតមានក្នុងសៀវភៅនេះ ព្រមទាំងរង់ចាំទទួលយកនូវការរិះគន់ដើម្បីស្ថាបនាកែលំអដោយសេចក្ដីរីករាយ។

**ចាត់ដំបង:** ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែចេត្រ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ ។

សក្យមុនីភិក្ខុអត្ថគុត្តោ **សំ ស៊ីណាច**

# ១.ពណ៌នាព្រះត្រៃបិដក

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទៀបបរិនិព្វានព្រះអង្គទ្រង់បានប្រគល់ធម៌និងវិន័យឱ្យជាសាស្តាជំនួសព្រះអង្គថាៈ

**សិយា ខោ បនានន្ទ តុម្ហាកំ ឯវមស្ស អតីតសត្ថុកំ បាវចនំ នត្ថិ នោ សត្ថាតិ ន ខោ បនេតំ អានន្ទ ឯវំ ទដ្ឋព្វំ យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា។**

ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យប្រដៅ ដែលមានគ្រូប្រព្រឹត្តកន្លងទៅហើយ គ្រូរបស់យើងឈ្មោះថា មិនមានឡើយ ម្នាលអានន្ទ សេចក្តីនេះអ្នកកុំចូលចិត្តយ៉ាងនេះឡើយ ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធម៌ និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ។

លោកអធិប្បាយក្នុងសុមង្គលវិលាសិនីអដ្ឋកថាថាៈ

**តំ សកលម្បិ វិនយបិដកំ សុត្តន្តបិដកំ អភិធម្មបិដកំ មយិ និព្វុតេ តុម្ហាកំ សត្ថុ កិច្ចំ សាធេស្សតិ ។**

ព្រះវិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក សូម្បីទាំងអស់នោះ កាលតថាគតបរិនិព្វានទៅហើយ នឹងធ្វើកិច្ចរបស់ព្រះសាស្តាឱ្យសម្រេចដល់អ្នកទាំងឡាយ។

សេចក្ដីមកប៉ុណ្ណោះសម្ដែងឱ្យឃើញថា សូម្បីព្រះសម្មាសម្ពុទ្ធព្រះអង្គរំលត់ខន្ធចូលកាន់បរិនិព្វានមកដល់សព្វថ្ងៃនេះ ២៥៥៦ឆ្នាំជាងក៏ដោយ បើព្រះធម៌ និងព្រះវិន័យ ដែលព្រះអង្គទ្រង់សម្ដែងទុក និងព្រះអង្គទ្រង់បញ្ញត្តទុក នៅមាន ឈ្មោះថា ព្រះសម្មាសម្ពុទ្ធព្រះអង្គគង់ធរមាននៅ ព្រោះហេតុអ្វី? ព្រោះថា ធម៌ និងវិន័យនេះជាសាស្ដាសម្រាប់ចង្អុលបង្ហាញផ្លូវពុទ្ធបរិស័ទទាំងឡាយ។ កាលដែលព្រះពុទ្ធព្រះអង្គទ្រង់គង់នៅ មានតែព្រះពុទ្ធមួយអង្គប៉ុណ្ណោះ តែពេលដែលព្រះអង្គបរិនិព្វានទៅ ព្រះពុទ្ធមានរហូតដល់ ៨៤.០០០ព្រះអង្គ ព្រោះថា មួយធម្មក្ខន្ធស្មើនឹងព្រះពុទ្ធមួយអង្គ ដូច្នេះ គួរតែយើងគ្រប់គ្នាគោរពបដិបត្តិតាមធម៌ និងវិន័យដែលព្រះអង្គទ្រង់ត្រាស់សម្ដែង និងបញ្ញត្តទុក បើយើងមិនគោរពធម៌ និងវិន័យទេ ឈ្មោះថា យើងមិនគោរពព្រះពុទ្ធឡើយ។ ព្រោះហេតុអ្វីបានជាមិនគោរពព្រះពុទ្ធ? ព្រោះថា ព្រះធម៌មួយធម្មក្ខន្ធជាព្រះពុទ្ធមួយព្រះអង្គ ដូច្នេះធម៌និងវិន័យនេះជាព្រះអរហន្តសម្មាសម្ពុទ្ធ។ ការមិនគោរពព្រះធម៌ និងវិន័យ គឺជាការមិនគោរពព្រះពុទ្ធផងដែរ។

បច្ចុប្បន្ននេះ ក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនា និកាយថេរវាទ កាលនឹងសិក្សាឱ្យយល់ដល់សេចក្ដីពិតរបស់ព្រះពុទ្ធវចនៈ ដែលមាននៅក្នុងព្រះត្រៃបិដកយ៉ាងត្រឹមត្រូវ ដោយមិនឱ្យខុសភ្លាំងភ្លាត់នោះ ចាំបាច់ត្រូវអាស្រ័យគម្ពីរអដ្ឋកថា ដីកា និងគម្ពីរដទៃៗទៀតជាច្រើន។

សូម្បីក្នុងសម័យរបស់ព្រះថេរៈក្នុងកាលមុន ព្រះពុទ្ធវចនៈក៏ជារឿងដែលយល់បានដោយលំបាក។ ដូច្នេះហើយក្នុងសម័យនោះ ព្រះថេរៈអ្នកយល់ក្នុងព្រះពុទ្ធវចនៈរួបរួមយកនូវ**បកិណ្ណកទេសនា** មកចងក្រង

ជាពាក្យអធិប្បាយឱ្យស្រួលងាយយល់ ដល់កុលបុត្រជំនាន់ខាងក្រោយៗ ដែលហៅថា **អដ្ឋកថា**។

កាលកន្លងមកខាងក្រោយទៀត សូម្បីពាក្យអធិប្បាយហៅថា **អដ្ឋកថា** នោះ ក៏ជាសេចក្តីដែលយល់បានដោយលំបាកពេក ទើបព្រះថេរៈក្នុងសម័យនោះៗ ដែលជាអ្នកប្រាជ្ញាសេចក្តីអនុគ្រោះដល់បច្ឆិមជនឱ្យយល់ព្រះត្រៃបិដក និងវិនិច្ឆ័យផ្សេងៗ ទាំងជាសាសនវិនិច្ឆ័យ និងលោកវិនិច្ឆ័យ ដែលមាននៅក្នុងគម្ពីរអដ្ឋកថាផ្សេងៗ ហើយរចនាគម្ពីរឡើងអធិប្បាយ **សទ្ទប្បញ្ញត្តិ** និង **អត្ថប្បញ្ញត្តិ** ចំណែកណាដែលយល់លំបាក ដែលមានក្នុងអដ្ឋកថាឱ្យឈ្មោះថា **ដីកា** ព្រះថេរៈអ្នកទទួលរចនាដីកានោះមានច្រើនអង្គដូចជា ធម្មបាលត្ថេរៈ អានន្ទត្ថេរៈ វជិរពុទ្ធិត្ថេរៈ សារីបុត្តត្ថេរៈ ចោឡិយកស្សបត្ថេរៈ ជាដើម ។

នៅក្នុងបច្ចុប្បន្នកាលនេះ ពុទ្ធសាសនិកជន ដែលមានសទ្ធាជ្រះថ្លាចង់សិក្សានវង្គសត្ថុសាសន៍ឱ្យយល់ច្បាស់នោះ ចាំបាច់ត្រូវសិក្សាគម្ពីរផ្សេងៗ ដែលព្រះថេរៈទាំងឡាយបានរួបរួមជាគម្ពីរ **អដ្ឋកថា ដីកា** ទុក។

គម្ពីរទាំងនោះ អ្នកប្រាជ្ញបានចាត់ជាលំដាប់ផ្សេងៗគ្នា តាមសេចក្តីសំខាន់ៗ របស់គម្ពីរនីមួយៗគឺៈ

**១.ព្រះត្រៃបិដក** សំដៅដល់ព្រះពុទ្ធវចនៈទាំងអស់[1]

**២.អដ្ឋកថា** សំដៅដល់គម្ពីរអធិប្បាយព្រះត្រៃបិដក

**៣.បករណវិសេស** សំដៅដល់គម្ពីរដែលសង្ខេបព្រះត្រៃបិដក និងពោលពីវត្តប្រតិបត្តិក្នុងព្រះពុទ្ធសាសនា[2]

---

[1] ពាក្យថា ពុទ្ធវចនៈនេះ ពោលទុកដោយភាពជាប្រធាន ដោយពិតពុទ្ធភាសិត សាវកភាសិត ឥសិភាសិត ឬទេវតាភាសិតទាំងអស់ ដែលឡើងកាន់សង្គីតិ៣លើក ហៅថា ព្រះត្រៃបិដក។

**៤.ដីកា** សំដៅដល់គម្ពីរអធិប្បាយលើអដ្ឋកថា[3]

**៥.មូលដីកា** សំដៅដល់គម្ពីរអធិប្បាយអដ្ឋកថា

**៦.អនុដីកា** សំដៅដល់គម្ពីរអធិប្បាយមូលដីកា

**៧.គន្ថន្តរៈ** សំដៅដល់គម្ពីរក្រៅពីព្រះត្រៃបិដក អដ្ឋកថា មូលដីកា ដីកា និងអនុដីកា

**៨.គណ្ឋិ** សំដៅដល់គម្ពីរ ដែលអធិប្បាយសេចក្តីដែលលំបាកក្នុងអដ្ឋកថា ដីកា ដែលព្រះថេរៈទាំងឡាយជាអដ្ឋកថាចារ្យ និងជាដីកាចារ្យមិនអធិប្បាយទុក

**៩.យោជនា** សំដៅដល់ គម្ពីរដែលសំដែងពីពាក្យស័ព្ទ និងប្រាប់វិធីសម្ពន្ធពាក្យស័ព្ទទុកជាដើម

---

[2] បករណវិសេសនេះ ឃើញពោលសំដៅដល់វិសុទ្ធិមគ្គ ដែលជាគម្ពីរអដ្ឋកថាសង្ខេប ពន្យល់ព្រះត្រៃបិដកទាំងអស់ ពោលពីសីល សមាធិ និងបញ្ញា ដែលជាវត្តប្រតិបត្តិក្នុងព្រះសាសនា

[3] ក្នុងពាក្យ ដីកានេះ មានប្រើយ៉ាងនេះគឺ

ក. ដីកាដែលពន្យល់អដ្ឋកថាតែឯង ហៅឈ្មោះថា ដីកា ដដែល ។

ខ. ក្នុងករណី មានដីកាថ្មីមួយទៀតពន្យល់អំពីអដ្ឋកថាដែរ គេហៅឈ្មោះដីការចនាមុនថា បុរាណដីកា ហើយហៅដីការចនាក្រោយថា អភិនវដីកា ដូចដីការបស់អដ្ឋកថាកង្ខាវិតរណី ឬដីការបស់អដ្ឋកថាសីលក្ខន្ធវគ្គ ។

គ. ក្នុងករណី មានដីកាមួយទៀតពន្យល់បន្តពីខ្លួន គឺពន្យល់ពីដីកាដើម គេហៅឈ្មោះដីការចនាមុនថា មូលដីកា ហើយហៅដីការចនាក្រោយដែលពន្យល់អំពីដីកាដើមថា អនុដីកា ដូចដីការបស់អដ្ឋកថាអភិធម្ម គឺថាព្រះអានន្ទត្ថេរតែដីកាពន្យល់អដ្ឋកថា ទើបហៅឈ្មោះថា មូលដីកា ហើយព្រះធម្មបាលតែងដីកាក្រោយពន្យល់មូលដីកានោះបន្ត ទើបហៅឈ្មោះថា អនុដីកា ។

ដូចនេះ ជាសរុប ដីកាក្រោមមានពីរបែប គឺថា បើជាដីកាពន្យល់អដ្ឋកថា មានឈ្មោះថា អភិនវដីកា តែបើជាដីកាពន្យល់លើដីកាដើម មានឈ្មោះថា អនុដីកា ។

**១០.សទ្ទាវិសេស** សំដៅដល់ គម្ពីរសម្តែងសេចក្តីរបស់ពាក្យស័ព្ទតាមជួរនិរុត្តិសាស្ត្រ ។

**១.គម្ពីរព្រះត្រៃបិដក** មាន ៣ ចំណែកគឺ វិនយបិដក ១៣ ភាគ សុត្តន្តបិដក ៦៤ ភាគ និងអភិធម្មបិដក ៣៣ ភាគ រួមជា ១១០ ភាគ ។

## វិន័យបិដក មាន៥ គម្ពីរគឺ:

**១.អាទិកម្ម** (ទោសធ្ងន់)
**២.បាចិត្តិយ:** (ទោសស្រាល)
**៣.មហាវគ្គ** (វគ្គធំ)
**៤.ចុល្លវគ្គ** (វគ្គតូច)
**៥.បរិវារ:** (បទរាយរង)

## គម្ពីរសុត្តន្តបិដក មាន ៥ គម្ពីរ គឺ:

**១.ទីឃនិកាយ**
**២.មជ្ឈិមនិកាយ**
**៣.សំយុត្តនិកាយ**
**៤.អង្គុត្តរនិកាយ**
**៥.ខុទ្ទកនិកាយ**

ខុទ្ទកនិកាយមានគម្ពីរតូចៗ តទៅទៀតចំនួន ១៥ គឺ:
**១.**ខុទ្ទកបាឋ: អត្ថបទខ្លី
**២.**ធម្មបទ ផ្លូវនៃសច្ចធម៌
**៣.**ឧទាន គាថាធ្វើឱ្យកើតក្តីរីករាយ

៤.ឥតិវុត្តកៈ សូត្រដែលពោលថា មានដូច្នេះ
៥.សុត្តនិបាត សមុច្ច័យនៃសូត្រ
៦.វិមានវត្ថុ ស្តីពីវិមាននៅទេវបុរី
៧.បេតវត្ថុ និទានស្តីពីប្រេត
៨.ថេរគាថា គាថាព្រះថេរៈទេសនា
៩.ថេរីគាថា គាថាព្រះនាងថេរី
១០.ជាតក និទានជាតិ
១១.និទ្ទេស ការសម្តែងពន្យល់
១២.បដិសម្ភិទា វិជ្ជាភាគ
១៣.អបទាន ជីវភាពព្រះអរហន្ត
១៤.ពុទ្ធវំស ប្រវត្តិអង្គព្រះសម្ពុទ្ធ
១៥.ចរិយាបិដក វិធីប្រតិបត្តិតាមពុទ្ធចរិយា

## គម្ពីរអភិធម្មបិដកមានទាំងអស់ ៧ គម្ពីរគឺៈ

១.ធម្មសង្គណី ការចាត់របៀបធម៌
២.វិភង្គ ការចែករំលែកធម៌
៣.កថាវត្ថុ ចំណុចធម៌
៤.បុគ្គលប្បញ្ញត្តិ បញ្ញត្តិថាបុគ្គល
៥.ធាតុកថា ការវែកញែកធាតុ
៦.យមកៈ ធម៌ជាគូៗគ្នា
៧.បដ្ឋាន ធម៌ជាបច្ច័យទាក់ទងគ្នា

សរុបទាំងគម្ពីរវិនយបិដក សុត្តន្តបិដក អភិធម្មបិដក ទាំងអស់ខ្មែរយើង ធ្វើបាលីមួយខាង សម្រាយមួយខាងមាន ១១០ ក្បាល ។

ការធ្វើសង្គាយនានៅប្រទេសខ្មែរ ជាឧត្តមសង្គាយនាជាការប្រែគម្ពីរព្រះត្រៃបិដក ដែលមិនធ្លាប់មានមកក្នុងប្រទេសកាន់ព្រះពុទ្ធសាសនា មានតែប្រទេសខ្មែរយើងប៉ុណ្ណោះ ដែលបានផ្ទៀងផ្ទាត់ប្រែគម្ពីរព្រះត្រៃបិដកជាបាលីម្ខាង សម្រាយម្ខាងមុនប្រទេសនានា។ ការសង្គាយនានៅប្រទេសខ្មែរយើងអស់ថេរវេលា ៣ រាជ្យ គឺរាជ្យព្រះបាទស៊ីសុវត្ថិ មុនីវង្ស១ រាជ្យព្រះបាទនរោត្តម សីហនុ១ និងរាជ្យព្រះបាទសម្តេចនរោត្តមសុរាម្រឹត១ គឺតាំងពីពុទ្ធសករាជ ២៤៧៣ (គ.ស.១៩២៩) ដល់ពុទ្ធសករាជ ២៥១៣ (គ.ស. ១៩៦៩) ចំណាយវេលាអស់៤០ ឆ្នាំគត់។

# អធិប្បាយព្រះត្រៃបិដកដោយសង្ខេប

## (១) វិនយបិដក

ព្រះធម្មសង្គាហកាចារ្យទាំងឡាយបានតាំងទុក

-បារាជិក ៤ ថា **បារាជិកកណ្ឌ**

-សង្ឃាទិសេស ១៣ ថា **តេរសកណ្ឌ**

-សិក្ខាបទ ២ ថា **អនិយតៈ**

-សិក្ខាបទ ៣០ ទុកថា **និស្សគ្គិយបាចិត្តិយៈ**

-សិក្ខាបទ ៩២ ថា **បាចិត្តិយៈ**

-សិក្ខាបទ ៤ ថា **បាដិទេសនីយៈ**

-សិក្ខាបទ ៧៥ ថា **សេខិយៈ**

-ធម៌ ៧ ប្រការទុកថា **អធិករណសមថៈ**

**បញ្ជាក់:** សិក្ខាបទ ២២៧ នេះលោកហៅថា **គម្ពីរមហាវិភង្គ**[4]។

តអំពីនេះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយបានតាំង

-សិក្ខាបទ ៨ ក្នុងភិក្ខុនីវិភង្គថា កណ្ឌនេះឈ្មោះថា **បារាជិកកណ្ឌ**។

-សង្ឃាទិសេស ១៧ សិក្ខាបទទុកថានេះ **សត្តរសកណ្ឌ**។

-និស្សគ្គិយបាចិត្តិយៈ ៣០ សិក្ខាបទ ទុកថា **និស្សគ្គិយបាចិត្តិយៈ**។

-បាចិត្តិយៈ ១៦៦ សិក្ខាបទ ទុកថានេះ **បាចិត្តិយៈ**។

-បាដិទេសនីយៈ៨ សិក្ខាបទ ទុកថានេះ **បាដិទេសនីយៈ**

-សេក្ខិយៈ ៧៥ សិក្ខាបទ ទុកថានេះ **សេក្ខិយៈ**។

-ធម៌ ៧ ប្រការ ទុកថានេះ **អធិករណសមថៈ**។

**បញ្ជាក់:** សិក្ខាបទ ៣១១ ថា **ភិក្ខុនីវិភង្គ**។

តាំងវិភង្គទាំងពីរនេះ គឺភិក្ខុវិភង្គ និងភិក្ខុនីវិភង្គ ឈ្មោះថា **ឧភតោ-វិភង្គ** មាន ៧៤ ភាណវារៈ។

កាលព្រះធម្មសង្គាហកាចារ្យទាំងឡាយ សង្គាយនាឧភតោវិភង្គ រួចហើយ ក៏សង្គាយនាគម្ពីរខន្ធកៈទាំង៨២ (**មហាវគ្គ** និង**ចុល្លវគ្គ**) មានប្រមាណ ៨០ ភាណវារៈ។

ទើបសង្គាយនា **គម្ពីរបរិវារៈ** ១៦ មានប្រមាណ ២៥ ភាណវារៈ ហើយ តាំងទុកបិដកនេះឱ្យឈ្មោះថា **វិនយបិដក**។

---

[4] មហាវិភង្គ គឺលោកសំដៅយកទាំងវេរញ្ជកណ្ឌដែលជាពាហិរនិទាន ទាំងរឿងរ៉ាវសិក្ខាបទ ២២៧ ចំណែកឯ សិក្ខាបទ២២៧តែម្យ៉ាង លោកហៅថា ភិក្ខុវិភង្គវិញ ។

## (ខ) សុត្តន្តបិដក

សុត្តន្តបិដក មាន ៥ គម្ពីរគឺៈ

**១.ទីឃនិកាយ**

**២.មជ្ឈិមនិកាយ**

**៣.សំយុត្តនិកាយ**

**៤.អង្គុត្តរនិកាយ**

**៥.ខុទ្ទកនិកាយ**

**គម្ពីរទីឃនិកាយ** មានព្រះសូត្រ ៣៤ សូត្រ មានព្រហ្មជាលសូត្រ ជាដើម សង្គាយនាបាលីប្រមាណ ៦៤ ភាណវារៈហើយចាត់ជា ៣ វគ្គគឺ សីលក្ខន្ធវគ្គ ១ មហាវគ្គ ១ និងបាដិកវគ្គ (ច្បាប់ខ្លះថា បាដិកវគ្គ) ១។

ហេតុអ្វីបានជាហៅនិកាយទី ១ នេះថា **ទីឃនិកាយ**? បានជាហៅថា **ទីឃនិកាយ** ព្រោះជាទីប្រជុំ និងជាទីនៅរបស់ព្រះសូត្រទាំងឡាយដែលមានខ្នាតវែង។

**មជ្ឈិមនិកាយ** មានព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយ-សូត្រ ជាដើម ប្រមាណ ៨០ ភាណវារៈ មានខ្នាតកណ្តាលហើយចាត់ជា ១៥ វគ្គ។

**សំយុត្តនិកាយ** មានព្រះសូត្រ ៧៧៦២ សូត្រ មានឱឃតរណ-សូត្រ ជាដើម ប្រមាណ ១០០ ភាណវារៈ ដែលត្រាស់ទុកដោយអំណាចនៃទេវតាសំយុត្ត ជាដើម។

**អង្គុត្តរនិកាយ** មានព្រះសូត្រ ៩៥៥៧ សូត្រ មានចិត្តបរិយាទាន-សូត្រ ជាដើម ប្រមាណ ១២០ ភាណវារៈ ដែលត្រាស់ទុកដោយអំណាចនៃការបន្ថែមចំណែកនីមួយៗឡើង។

**ខុទ្ទកនិកាយ** គឺព្រះវិនយបិដក អភិធម្មបិដកទាំងអស់ និងគម្ពីរ ១៥ ប្រភេទ មានខុទ្ទកបាឋៈជាដើម ព្រះពុទ្ធវចនៈដ៏សេសវៀរលែងតែនិកាយ ៤ មានទីឃនិកាយជាដើមចេញ ។

ព្រះពុទ្ធវចនៈមានអង្គ ៩ គឺ **សុត្តៈ ១ គេយ្យៈ ១ វេយ្យាករណៈ ១ គាថា ១ ឧទាន ១ ឥតិវុត្តកៈ ១ ជាតក ១ អព្ភូតធម្ម ១ វេទល្លៈ ១ ។**

ឧភតោវិភង្គ និទ្ទេស ខន្ធកៈ និង បរិវារៈ មង្គលសូត្រ រតនសូត្រ នាលកសូត្រ តុវដ្តកសូត្រ ក្នុងសុត្តនិបាត និងពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដែលមានឈ្មោះថា **សូត្រ** សូម្បីដទៃទៀត គប្បីជ្រាបថា **សុត្តៈ** ។

សូត្រដែលមានគាថាទាំងអស់គប្បីជ្រាបថា **គេយ្យៈ** សូម្បីសគាថវគ្គទាំងអស់ក្នុងសំយុត្តនិកាយ គប្បីជ្រាបថា **គេយ្យៈ** ដែរ។

អភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងសូម្បីព្រះពុទ្ធវចនៈដទៃណាដែលមិនបានរួបរួមទុកដោយអង្គ ៨ ព្រះពុទ្ធវចនៈទាំងអស់នោះ គប្បីជ្រាបថា **វេយ្យាករណៈ**។

ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធដែលមិនមានឈ្មោះថាសូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថា **គាថា** ។

សូត្រ ៨២ សូត្រ ដែលប្រកបដោយគាថា សម្រេចដោយញាណកើតរួមដោយសោមនស្សវេទនា គប្បីជ្រាបថា **ឧទាន** ។

សូត្រ ១១០ សូត្រដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា **ទុត្តំ ហេតំ ភគវតា** គប្បីជ្រាបថា **ឥតិវុត្តកៈ** ។

ជាតក៥៥០រឿងមានអបណ្ណកជាតកជាដើម គប្បីជ្រាបថា **ជាតក**។

ព្រះសូត្រដែលប្រកបដោយរឿង មិនធ្លាប់កើតមានគួរអស្ចារ្យ ដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនធ្លាប់កើតមានគួរអស្ចារ្យ ៤ យ៉ាងនេះ មានក្នុងអានន្ទ ដូច្នេះគប្បីជ្រាបថា **អព្ភូតធម្មៈ** ។

ព្រះសូត្រដែលត្រូវសាកសួរទាំងអស់មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនីយសូត្រ និងមហាបុណ្ណមសូត្រជាដើម[5] គប្បីជ្រាបថា **វេទល្លៈ** ។

ព្រះពុទ្ធវចនៈឈ្មោះថា **អភិធម្មបិដក** បានដល់ ព្រះពុទ្ធវចនៈគឺៈ **ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលប្បញ្ញត្តិ កថាវត្ថុ យមកៈ បដ្ឋាន** ។

ព្រះពុទ្ធវចនៈ មាន ៨៤.០០០ ព្រះធម្មក្ខន្ធ ហើយក្នុងមួយធម្មក្ខន្ធ ៗ ព្រះអដ្ឋកថាចារ្យបញ្ជាក់ទុកក្នុងគម្ពីរសុមង្គលវិលាសិនីឱ្យរាប់យ៉ាងនេះថា

ព្រះពុទ្ធវចនៈមាន ៨៤.០០០ ដោយអំណាចនៃធម្មក្ខន្ធតើដូចម្តេច? ពិតមែន ព្រះពុទ្ធវចនៈទាំងនោះមាន ៨៤.០០០ ដោយអំណាចនៃធម្មក្ខន្ធដែលព្រះអានន្ទត្ថេរ សម្តែងទុកហើយយ៉ាងនេះថាៈ

**ទ្វាសីតិ ពុទ្ធតោ គណ្ហឹ ទ្វេ សហស្សានិ ភិក្ខុតោ ចតុរាសីតិ សហស្សានិ យេ មេ ធម្មា បវត្តិនោ** ។

---

[5] ព្រោះជាព្រះសូត្រដែលបានសាកសួរហើយ តែងបាន តែងទទួលនូវការចេះដឹងផង នូវការរីករាយផង ។ **វេទ+ល** ដែល**វេទ** ប្រែថា ដឹង ជ្រាប ឬត្រេកអរ ឯ **ល** មកពី**លភ** ប្រែថា បាន

ខ្ញុំរៀនយកធម៌អំពីសំណាក់ព្រះពុទ្ធ ៨២.០០០ ធម្មក្ខន្ធ អំពីសម្នាក់ភិក្ខុ ២.០០០ ធម្មក្ខន្ធ ព្រះធម៌ដែលប្រព្រឹត្តទៅក្នុងហឫទ័យរបស់ខ្ញុំ ទើបមានចំនួន ៨៤.០០០ ធម្មក្ខន្ធ។

បណ្ដាព្រះធម៌ ៨៤.០០០ ធម្មក្ខន្ធនោះ សូត្រដែលមានអនុសន្ធិច្រើន រាប់ធម្មក្ខន្ធដោយអំណាចអនុសន្ធិ ។ ក្នុងគាថាព័ន្ធទាំងឡាយ ពាក្យសួរ បញ្ហាមួយចាត់ជា១ធម្មក្ខន្ធ ពាក្យឆ្លើយបញ្ហាមួយចាត់ជា១ធម្មក្ខន្ធ ។

ក្នុងព្រះអភិធម្ម ការចែកតិកៈ ទុកៈនីមួយៗ និងការចែកវារៈចិត្តមួយវារៈៗ ឈ្មោះថា ១ធម្មក្ខន្ធ។ ក្នុងវិន័យ មានវត្ថុ មានមាតិកា មានបទភាជនីយ មានអន្តរាបត្តិ មានអាបត្តិ មានអនាបត្តិ និងមានការកំណត់តិកៈ[6]។ បណ្ដាវត្ថុ និងមាតិកាជាដើមនោះចំណែកនីមួយៗ គប្បីជ្រាបថា ១ធម្មក្ខន្ធ។ ព្រះពុទ្ធវចនៈទាំងអស់មាន ៨៤.០០០ ធម្មក្ខន្ធ ដោយអំណាចនៃធម្មក្ខន្ធដូចពណ៌នាមកនេះឯង។ ទាំងអស់នេះមានពិពណ៌នា ឈ្មោះព្រះត្រ័យបិដកដោយសង្ខេប និងព្រះអដ្ឋកថា សម្រាប់សិក្សាស្រាវជ្រាវហើយក៏មានព្រះត្រ័យបិដក អដ្ឋកថានិយាយអំពីនរក តិរិច្ឆាន ប្រេត អសុរកាយ ឋានសួគ៌ និព្វាន ដែលយើងចង់បាន និងមិនត្រូវការ[7] ។

[6] ដូចពាក្យថា តិកទុក្កដ តិកបាចិត្តិយ ជាដើម ។

[7] ចង់បាន គឺចង់បានឋានសួគ៌ និងនិព្វាន, មិនត្រូវការ គឺមិនត្រូវការនរក ប្រេត ជាដើម ។

# ២.ភូមិចតុក្កៈ

១.អបាយភូមិ ៤ ភូមិ

២.កាមសុគតិភូមិ ៧ ភូមិ

៣.រូបាវចរភូមិ ១៦ ភូមិ

៤.អរូបាវចរភូមិ ៤ ភូមិ រួមដោយពិស្តារ ៣១ ភូមិនេះគឺ ជាគុកសម្រាប់ដាក់សត្វលោកដែលវង្វេង។

## ៣.ចែកដោយពិស្តារ ៣១ ភូមិ

**១.អបាយភូមិ ៤ គឺ:**

**១.និរយោ** នរក

**២.បិត្តិវិសយោ** ភូមិនៃប្រេត

**៣.តិរច្ឆានយោនិ** កំណើតសត្វតិរច្ឆាន

**៤.អសុរកាយោ** អសុរកាយ។

**២.កាមសុគតិភូមិ ៧ គឺ:**

**១.មនុស្សា** ពួកមនុស្ស

**២.ចាតុម្មហារាជិកា** ទេវតាជាន់ចាតុម្មហារាជ

**៣.តាវត្តិំសា** ទេវតាជាន់តាវត្តិង្ស

**៤.យាមា** ទេវតាជាន់យាមា

**៥.តុសិតា** ទេវតាជាន់តុសិត

**៦.និម្មានរតី** ទេវតាជាន់និម្មានរតី

**៧.បរនិម្មិតវសវត្តី** ទេវតាជាន់បរនិម្មិតវសវត្តី។

**៣.រូបាវចរភូមិ ១៦ គឺ:**

**បឋមជ្ឈានភូមិ ៣ មាន:**

១.បារិសជ្ជា

២.បុរោហិតា

៣.មហាព្រហ្មា។

**ទុតិយជ្ឈានភូមិ ៣ មាន:**

១.បរិត្តាភា

២.អប្បមាណាភា

៣.អាភស្សរា។

**តតិយជ្ឈានភូមិ ៣ មាន:**

១.បរិត្តសុភា

២.អប្បមាណសុភា

៣.សុភកិណ្ហា។

**ចតុត្ថជ្ឈានភូមិ ៧ មាន:**

១.វេហប្ផលា

២.អសញ្ញីសត្តា

៣.សុទ្ធាវាសភូមិ ៥ គឺមាន: អវិហាភូមិ ១ អតប្បាភូមិ ១ សុទស្សាភូមិ ១ សុទស្សីភូមិ ១ អកនិដ្ឋាភូមិ ១ ។

**៤.អរូបាវចរភូមិ ៤ មាន:**

១.អាកាសានញ្ចាយតនភូមិ

២.វិញ្ញាណញ្ចាយតនភូមិ

៣.អាកិញ្ចញ្ញាយតនភូមិ

៤.នេវសញ្ញានាសញ្ញាយតនភូមិ។

សុគតិភូមិមានវចនត្ថៈថា **អនេកវិធសម្បត្តិអធិដ្ឋានតាយ សោភណា គន្តព្វាតិ ឧបដ្ឋិតព្វោ គតិ ចាតិ = សុគតិ** ដែលឈ្មោះថាសុគតិ ព្រោះអត្ថថា **ល្អ** ដោយភាពជាស្ថានទី ដែលទទួលសម្បត្តិមិនមែនតិច និងជា**គតិ** ព្រោះជាទីដែលសត្វគប្បីដល់ គឺគប្បីកើតឡើង។ សុគតិ ដែលប្រព្រឹត្តទៅជាមួយនឹងកាមតណ្ហា ឈ្មោះថា កាមសុគតិ។ កាមសុគតិនោះឯងជាភូមិ ឈ្មោះថា កាមសុគតិភូមិ។

# ៤.ភាពផ្សេងគ្នានៃទ្វីបទាំង ៤

១.មនុស្សក្នុងបុព្វវិទេហទ្វីប
២.មនុស្សក្នុងអបរគោយានទ្វីប
៣.មនុស្សក្នុងជម្ពូទ្វីប
៤.មនុស្សក្នុងឧត្តរកុរុទ្វីប។

បណ្ដាមនុស្សក្នុងទ្វីបទាំង៤នោះ មនុស្សក្នុងបុព្វវិទេហទ្វីបតាំងនៅទិសខាងកើតរបស់ភ្នំសិនេរុ ពួកមនុស្សទាំងនោះមានសម្បុរកាយ និងមានរូបរាង សណ្ឋាន ផ្ទៃមុខ ដូចព្រះចន្ទកន្លះចំណិត មានចិត្តស្ងប់ មានការប្រព្រឹត្តល្អ មានអាយុ ៧០០ ឆ្នាំ។

មនុស្សដែលនៅអបរគោយានទ្វីប តាំងនៅទិសខាងលិចរបស់ភ្នំសិនេរុ ពួកមនុស្សទាំងនោះមានរូបរាងសណ្ឋានផ្ទៃមុខ ដូចព្រះចន្ទពេញវង់ មានអាយុ ៥០០ ឆ្នាំ។

មនុស្សក្នុងជម្ពូទ្វីប តាំងនៅទិសខាងត្បូងរបស់ភ្នំសិនេរុ មានរូបរាងសណ្ឋាន ផ្ទៃមុខ ដូចពងមាន់ ឬ ៣ជ្រុង មានអាយុមិនស្ថិតស្ថេរ ក្នុងសម័យកាលណាមានគុណធម៌ចម្រើនឡើង សម័យនោះក៏មានអាយុច្រើនឡើងរហូតដល់មានអាយុ ១អសង្ខេយ្យឆ្នាំ តែសម័យណាមានគុណធម៌ថយចុះសម័យនោះក៏មានអាយុថយចុះរហូតនៅត្រឹម ១០ឆ្នាំ។

មនុស្សនៅក្នុងឧត្តរកុរុទ្វីប តាំងនៅទិសខាងជើងរបស់ភ្នំសិនេរុ ពួកមនុស្សក្នុងទ្វីបនោះ មានរូបរាង សណ្ឋាន ផ្ទៃមុខ ៤ជ្រុង មានអាយុ ១.០០០ ឆ្នាំស្មើគ្នាទាំងអស់។

# ៥.គុណធម៌វិសេសរបស់មនុស្ស និងទេវតា

ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីប ខ្ពង់ខ្ពស់ហួសពួកទេវតាជាន់តាវត្តិង្សផង និងពួកមនុស្សអ្នកនៅជម្ពូទ្វីបផងដោយស្ថាន៣យ៉ាង។ ស្ថាន ៣ យ៉ាងដូចម្តេច។ គឺមិនមានសេចក្តីអន្ទះសា ១ មិនមានសេចក្តីហួងហែង ១ មានអាយុទៀង មានកំណើតដ៏វិសេស ១ ។ ម្នាលភិក្ខុទាំងឡាយពួកមនុស្សនៅក្នុងឧត្តរកុរុទ្វីបតែងខ្ពង់ខ្ពស់ហួសពួកទេវតាជាន់តាវត្តិង្សផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាងនេះឯង។

ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាន់តាវត្តិង្សខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង។ ស្ថាន ៣ យ៉ាង តើដូចម្តេចខ្លះ។ គឺអាយុជាទិព្វ ១ សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាន់តាវត្តិង្សខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផងដោយស្ថាន ៣ យ៉ាងនេះឯង។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីប ខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកទេវតាជាន់តាវត្តិង្សផងដោយស្ថាន ៣ យ៉ាង។ ស្ថាន ៣ យ៉ាងតើដូចម្តេចខ្លះ។ គឺមានសេចក្តីក្លៀវក្លា ១ មានស្មារតីខ្ជាប់ខ្ជួន ១ មានការបំពេញព្រហ្មចរិយធម៌ដ៏វិសេស ១ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបខ្ពង់ខ្ពស់ហួសពួកមនុស្ស អ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកទេវតាជាន់តាវត្តិង្សផង ដោយស្ថាន ៣ យ៉ាងនេះឯង។

(អង្គុ.នវ.សត្តាវាសវគ្គ.៤៩.)

# ៦.វត្តបទទាំង ៧ យ៉ាង

## ដែលមាឃមាណពបានសមាទាន ថា

១.អាត្មាអញត្រូវចិញ្ចឹមមាតាបិតា អស់មួយជីវិត។

២.ត្រូវកោតក្រែងបុគ្គលជារៀមច្បងក្នុងត្រកូល អស់មួយជីវិត។

៣.ត្រូវមានវាចាល្អិតទន់ ផ្អែមល្ហែម អស់មួយជីវិត។

៤.មិនត្រូវមានវាចាញុះញង់ អស់មួយជីវិត។

៥.ត្រូវមានចិត្តប្រាសចាកសេចក្ដីកំណាញ់ជាមន្ទិល ជាអ្នកមានការបរិច្ចាគរួសរាន់ មានដៃលាងហើយដើម្បីនឹងឱ្យទាន ត្រេកអរនឹងការលះបង់ ជាអ្នកគួរគេសូមទានបាន ត្រេកអរក្នុងការឱ្យ និងការចែករំលែកទានហើយនៅគ្រប់គ្រងផ្ទះ អស់មួយជីវិត។

៦.ត្រូវមានវាចាទៀងទាត់ អស់មួយជីវិត ។

៧.មិនត្រូវមានសេចក្ដីក្រោធ បើទុកជាសេចក្ដីក្រោធកើតឡើងដល់អាត្មាអញត្រូវបន្ទោបង់នូវសេចក្ដីក្រោធនោះ មួយរំពេចអស់មួយជីវិត។

អ្នកចម្រើនឈានទៅកើតក្នុងព្រហ្មលោក ព្រះយោគាវចរចម្រើនបឋមជ្ឈាន ដែលជារូបាវចរកុសលបានបន្តិចបន្តួច រមែងកើតក្នុងពួកព្រហ្មជាន់បារិសជ្ជា គ្រាចម្រើនបឋមជ្ឈាននោះឯងបានថ្នាក់កណ្ដាល រមែងកើតក្នុងពួកព្រហ្មជាន់បុរោហិត គ្រាចម្រើនបឋមជ្ឈាននោះឯងបានយ៉ាងប្រណីត រមែងកើតក្នុងពួកព្រហ្មជាធំ គឺមហាព្រហ្ម។ មួយទៀត គ្រាចម្រើនទុតិយជ្ឈាន និងតតិយជ្ឈានបានបន្តិចបន្តួច រមែងកើតក្នុងពួកព្រហ្មជាន់បរិត្តាភា គ្រាចម្រើនបានថ្នាក់កណ្ដាល រមែងកើតក្នុងពួកព្រហ្មអប្បមាណា-

ភា គ្រាចម្រើនបានយ៉ាងប្រណីតរមែងកើតក្នុងពួកព្រហ្មអាភស្សរា។ គ្រាចម្រើនចតុត្ថជ្ឈានបានបន្តិចបន្តួច រមែងកើតក្នុងពួកព្រហ្មបរិត្តសុភា គ្រាចម្រើនឈាននោះបានថ្នាក់កណ្តាល រមែងកើតក្នុងពួកព្រហ្មអប្បមាណសុភា គ្រាចម្រើនបានយ៉ាងប្រណីត រមែងកើតក្នុងពួកព្រហ្មសុភកិណ្ហា ។ គ្រាចម្រើនបញ្ចមជ្ឈានបានហើយ រមែងកើតក្នុងពួកព្រហ្មវេហប្ផលា។ គ្រាចម្រើនបញ្ចមជ្ឈានឱ្យកម្ចាត់បង់សញ្ញាចេញ រមែងកើតក្នុងពួកព្រហ្មអសញ្ញីសត្វ។ ចំណែកព្រះអនាគាមី រមែងកើតក្នុងសុទ្ធាវាសភូមិទាំងឡាយ។ ព្រះយោគាវចរចម្រើនអរូបាវចរកុសលបានតាមលំដាប់ហើយ បានកើតក្នុងអរូបភូមិទាំងឡាយប៉ុណ្ណោះ ដូច្នេះឯង។

## ៧. កំពូលភព ឬកំពូលភូមិ មាន ៣ យ៉ាង

**១.វេហប្ផលា** ជាកំពូលរបស់រូបព្រហ្ម

**២.អកនិដ្ឋា** ជាកំពូលរបស់សុទ្ធាវាស

**៣.នេវសញ្ញានាសញ្ញាយតនៈ** ជាកំពូលរបស់អរូបភព។

ម្យ៉ាងទៀត ក្នុងភពនៃពួកព្រហ្មបារិសជ្ជាជាដើមនេះ ព្រះអរិយបុគ្គលដែលកើតក្នុងភពទាំង ៣ នោះ រមែងមិនកើតក្នុងព្រហ្មលោកជាន់ដទៃ ព្រោះជាន់វេហប្ផលា អកនិដ្ឋា និងអរូបទី ៤ ប្រសើរបំផុត។ មួយទៀត ព្រះអរិយទាំងឡាយ ដែលកើតក្នុងព្រហ្មលោកជាន់ខ្ពស់ៗឡើង ទៅក្រៅពីភពទាំង ៣ នោះមិនកើតក្នុងព្រហ្មលោកជាន់ទាបៗទេ។

## ៨.មរណុប្បត្តិ

**ការកើតឡើងនៃមរណៈមាន ៤ យ៉ាងគឺៈ**

**១.អាយុក្ខយមរណំ** ស្លាប់ព្រោះអស់អាយុ

**២.កម្មក្ខយមរណំ** ស្លាប់ព្រោះអស់កម្ម

**៣.ឧភយក្ខយមរណំ** ស្លាប់ព្រោះអស់ទាំងពីរយ៉ាង

**៤.ឧបច្ឆេទមរណំ** ស្លាប់ព្រោះកម្មចូលទៅកាត់ផ្តាច់។

នៅក្នុងគម្ពីរសម្មោហវិនោទនីអដ្ឋកថា សច្ចវិភង្គពោលថា

## មរណានុភក្ខ ៣ យ៉ាង

**១.ខណិកមរណំ** ការស្លាប់ដោយខណៈ

**២.សម្មុតិមរណំ** ការស្លាប់ដោយសន្មត

**៣.សមុច្ឆេទមរណំ** ការស្លាប់ដោយសមុច្ឆេទ។

## ៩.ឧបមាបីតិ និងសុខ

បីតិនេះ ប្រៀបដូចក្នុងករណីដែលបុគ្គលនឿយហត់ ក្នុងផ្លូវកន្តារៈ លុះបានឃើញ បានឮសំឡេងទឹកហូរក្នុងព្រៃ (សូម្បីនៅមិនទាន់បានផឹកជាដើម) ក៏កើតបីតិ សប្បាយខ្លាំងក្នុងចិត្តថា យើងនឹងបានផឹក បានងូតទឹកជម្រះរាងកាយឱ្យសប្បាយ ។ ចំណែកសុខនោះ ប្រៀបដូចបុគ្គលចូលទៅកាន់ម្លប់ក្នុងព្រៃ បានផឹក និងប្រើប្រាស់ទឹកតាមសប្បាយ។

-បីតិ បានដល់ សេចក្តីត្រេកអរក្នុងឥដ្ឋារម្មណ៍

-សុខៈ បានដល់ ការសោយរសនៃឥដ្ឋារម្មណ៍ដែលបានហើយ

-បីតិ មានក្នុងទីណាសុខៈក៏មានក្នុងទីនោះ

-សុខៈ មានក្នុងទីណា ក្នុងទីនោះមិនមែនសុទ្ធតែមានបីតិទេ

-បីតិ សង្គ្រោះចូលក្នុងសង្ខារក្ខន្ធ

-សុខៈ សង្គ្រោះចូលក្នុងវេទនាខន្ធ។

## ១០.គន្ធៈ[8] ៤ យ៉ាង

**១.សីលគន្ធៈ** គឺបានដល់ សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ

**២.សមាធិគន្ធៈ** គឺបានដល់ សម្មាវាយាម សម្មាសតិ និងសម្មាសមាធិ

**៣.បញ្ញាគន្ធៈ** គឺបានដល់ សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ

**៤.អាយតនគន្ធៈ** គឺបានដល់គន្ធារម្មណ៍។

## ១១.ពោធិបក្ខិយសង្គហៈ

**១.សតិប្បដ្ឋាន ៤ គឺ:**

**១.កាយានុបស្សនាសតិប្បដ្ឋាន**[9] សតិដ៏មានកម្លាំងកើតរួមនឹងការពិចារណាឃើញរឿយៗនូវកាយ

**២.វេទនានុបស្សនាសតិប្បដ្ឋាន** សតិដ៏មានកម្លាំងកើតរួមនឹងការពិចារណាឃើញរឿយៗនូវវេទនា

---

[8] គន្ធៈ ប្រែថា ក្លិន ។ គន្ធៈ៣ខាងដើមលោកសំដៅយកក្លិន ដែលជាគុណ គឺលោកយកអង្គនៃអរិយមគ្គមកពោលដោយអំណាចនៃគុណគឺសីល សមាធិ និងបញ្ញា ។ ឯគន្ធៈទី៤ សំដៅយកក្លិនធម្មតាដែលគួនឹងច្រមុះ ។

[9] កាយ គឺតួរូបធម៌ដែលជាអារម្មណ៍ អនុបស្សនា គឺបញ្ញាដែលពិចារណាឃើញរឿយៗ សតិប្បដ្ឋាន គឺជាតួសតិដ៏មានកម្លាំង ដូចនេះ កាយ គឺជារូបធម៌ កាយានុបស្សនា គឺជាបញ្ញាដែលតាមឃើញរឿយៗនូវកាយ ឯកាយានុបស្សនាសតិប្បដ្ឋាន គឺជាសតិដ៏មានកម្លាំងដែលកើតរួមនឹងបញ្ញាដែលតាមឃើញនូវកាយ ។

**៣.ចិត្តានុបស្សនាសតិប្បដ្ឋាន** សតិដ៏មានកម្លាំងកើតរួមនឹងការពិចារណាឃើញរឿយៗនូវចិត្ត

**៤.ធម្មានុបស្សនាសតិប្បដ្ឋាន** សតិដ៏មានកម្លាំងកើតរួមនឹងការពិចារណាឃើញរឿយៗនូវធម៌ ។

**២.សម្មប្បធាន ៤ គឺ:**

**១.បហានប្បធាន** ព្យាយាមលះបង់អកុសលធម៌ ដែលកើតឡើងហើយ។

**២.សំវរប្បធាន** ព្យាយាមញុំាងបាបអកុសល ដែលមិនទាន់កើត មិនឱ្យកើតឡើងបាន។

**៣.ភាវនាបធាន** ព្យាយាមញុំាងកុសល ដែលមិនទាន់កើតឱ្យកើតឡើង។

**៤.អនុរក្ខនាបធាន** ព្យាយាមរក្សាកុសលធម៌ដែលកើតឡើង ហើយឱ្យរឹងរឹតតែចម្រើនឡើង។

**៣.ឥទ្ធិបាទ ៤ គឺ:**

**១.ឆន្ទិទ្ធិបាទ**

**២.វីរិយិទ្ធិបាទ**

**៣.ចិត្តិទ្ធិបាទ**

**៤.វិមំសិទ្ធិបាទ។**

**៤.ឥន្ទ្រិយ ៥ គឺ:**

**១.សទ្ធិន្ទ្រិយ**

**២.វីរិយិន្ទ្រិយ**

**៣.សតិន្ទ្រិយ**

    ៤.សមាធិន្ទ្រិយ
    ៥.បញ្ញិន្ទ្រិយ
៥.ពលៈ ៥ គឺៈ
    ១.សទ្ធាពលៈ
    ២.វីរិយពលៈ
    ៣.សតិពលៈ
    ៤.សមាធិពលៈ
    ៥.បញ្ញាពលៈ
៦.ពោជ្ឈង្គ ៧ គឺៈ
    ១.សតិសម្ពោជ្ឈង្គៈ
    ២.ធម្មវិចយសម្ពោជ្ឈង្គៈ
    ៣.វីរិយសម្ពោជ្ឈង្គៈ
    ៤.បីតិសម្ពោជ្ឈង្គៈ
    ៥.បស្សទ្ធិសម្ពោជ្ឈង្គៈ
    ៦.សមាធិសម្ពោជ្ឈង្គៈ
    ៧.ឧបេក្ខាសម្ពោជ្ឈង្គៈ
៧.អដ្ឋមគ្គ ៨ គឺៈ
    ១.សម្មាទិដ្ឋិ
    ២.សម្មាសង្កប្បៈ
    ៣.សម្មាវាចា
    ៤.សម្មាកម្មន្តៈ
    ៥.សម្មាអាជីវៈ

**៦.សម្មាវាយាមៈ**

**៧.សម្មាសតិ**

**៨.សម្មាសមាធិ**

បណ្តាធម៌ទាំង ៧ នេះ សម្មាសតិតែម្យ៉ាងប៉ុណ្ណោះ លោកហៅថា សតិប្បដ្ឋាន ៤ និងសម្មាវាយាមៈ លោកហៅថា សម្មប្បធាន ៤ ដូចគ្នា។

# ១២.ភាសិតោវាទសង្ខេប

**ឱកាស** ខ្ញុំសូមគោរព!

**យោ បន ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ការោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ។**

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អាន បូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម។

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ។**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ។

**ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ។**

អំណត់ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតិដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ។**

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេក និងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**សីលសមាធិគុណានំ ខន្តិ បធានការណំ សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ។**

សេចក្តីអត់ធន់ ជាហេតុជាទីតាំងនៃគុណគឺសីល និងសមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចម្រើនដោយសេចក្តីអត់ធន់មែនពិត ។

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ។**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថាជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀល និងការឈ្លោះប្រកែក ជាដើម។

**ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុខាវហា។**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបធម៌ សេចក្តីអត់ធន់ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ។

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ។**

អ្នកអត់ធន់ ជាអ្នកមានមិត្រសម្លាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកអត់ធន់ រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃទេវតា និងមនុស្សទាំងឡាយ។

**អត្តនោបិ បរេសញ្ច អត្ថាវហោ វ ខន្តិកោ សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ។**

អ្នកអត់ធន់ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ជាអ្នកឡើងកាន់ផ្លូវជាទីទៅកាន់ស្ថានសួគ៌ និងព្រះនិព្វាន។

**សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ។**

អ្នកអត់ធន់ ឈ្មោះថាធ្វើតាមនូវព្រះពុទ្ធដីកាជាឱវាទ នៃព្រះសាស្តាមែនពិត អ្នកអត់ធន់ ឈ្មោះថា បូជានូវព្រះវិជិតមារដោយការបូជាដ៏ឧត្តម។

**ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ ។**

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយបានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិយាដល់ព្រមដោយខណៈគឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ។**

កិរិយាកើតឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ កិរិយាសម្តែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នា

របស់សង្ឃ ឬពួកក្រុមនាំមកនូវសេចក្ដីសុខ សេចក្ដីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្ដីសុខ។

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ។**

សេចក្ដីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ (ក្នុងទីស្ងាត់) ជាអ្នកមានធម៌បានស្ដាប់ហើយ ពិចារណាឃើញ (នូវធម៌) នាំមកនូវសេចក្ដីសុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយនាំមកនូវសេចក្ដីសុខក្នុងលោក។

**សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ។**

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិមានះនេះឯងនាំមកនូវសេចក្ដីសុខដ៏ឧត្ដម។

**កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ។**

កិរិយាត្រឡប់បានអត្តភាពជាមនុស្សជាការលំបាក ការរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្ដាប់នូវព្រះសទ្ធម្មជាការកម្រ កិរិយាកើតឡើងនៃព្រះពុទ្ធទាំងឡាយជាការកម្រ។

**សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មឹ ជិនសាសនេ កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ ។**

បុគ្គលឯណា បានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប។

**បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ។**

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹកទ្រង់ស្តេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាច ទ្រង់សម្តែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលមើលនូវសត្វលោកដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១។

**កុក្កុដេ គព្ភវាសោ ច សោណោ ចុតនិក្ខមិ ឧសភេ រាជសម្បត្តិ សសេ បព្វជិតោ ជិនោ។**

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ។

**កុក្កុដេ សព្វញ្ញូ ពុទ្ធោ តត្ថ ចក្កំ បវត្តយិ និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ។**

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សម្ដែងនូវព្រះធម្មចក្កក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ពុទ្ធសាសនានឹងគ្រប់ ៥.០០០ គត់ ក្នុងឆ្នាំជូត។

**ឱក្កន្តោ ច គរុវារស្មឹ សុក្រវារេ ច និក្ខមិ សម្ពុទ្ធោ ពុធវារស្មឹ អង្គារេ បរិនិព្វុតោ។**

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្មាសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ។

**អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ ។**

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មីខែអាសាឍ ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្មាសម្ពុទ្ធក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ។

**និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ ចតុរាសីតិសហស្សធម្មក្ខន្ធា សុទេសិតា អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ បាណិនំ ។**

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមាផង ព្រះពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ហ្មឺន ៤ ពាន់ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្ដែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងឋានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ។

**ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ ឋបេត្វា សម្មាសម្ពុទ្ធេន វុត្តប្បការេន បដិបត្តិបូជាយ បូជំ ករោន្តេន លោកិយលោកុត្តរសម្បត្តិសិទ្ធំ កាតព្វំ ឧកាស អារាធនំ ករោមិ។**

បុគ្គលគួរតម្កល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយទុកក្នុងចិត្តហើយធ្វើការបូជា ដោយបដិបត្តិបូជាដោយប្រការដែលព្រះសម្មាសម្ពុទ្ធត្រាស់សម្តែងហើយគួរធ្វើឱ្យសម្រេចនូវសម្បត្តិជាលោកិយៈ និងលោកុត្តរៈ ខ្ញុំសូមគោរព អារាធនាទុកដោយប្រការដូច្នេះ។

**ឧកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវប្បច្ចូស សមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហឧតុម្ហិ វិសាខមាសេ សុក្កប្បក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយ និព្វានធាតុយា។**

ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ទ្រង់បរិនិព្វានហើយដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូជិតក្រុងកុសិនារា ក្នុងបច្ចូសសម័យដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើតខែវិសាខ ក្នុងគិម្ហរដូវឆ្នាំម្សាញ់ ឯណោះហោង។

# ១៣.លោក ៣ យ៉ាង

ដំណើរទិដ្ឋិត្រូវការឱ្យគេពិពណ៌នា ពីភពភូមិស្ថានរបស់លោក ដើម្បីបង្ហាញប្រាប់នូវស្នាដៃរបស់ពួកគេថា ជាអ្នកសាងលោក។ ក្នុងបទថា **លោកកេ** មាន ៣ យ៉ាង គឺសត្តលោក ១ សង្ខារលោក ១ និងឱកាសលោក ១។ លោកទាំង ៣ នេះពួកសត្វទាំងឡាយណា ជាប់ទាក់ទងនឹងឥន្ទ្រិយប្រព្រឹត្តទៅតាមអំណាចរូបធម៌នាមធម៌ឈ្មោះថាសត្តលោក។ លោកដែលចែកចេញជាប្រភេទមានផែនដី និងភ្នំជាដើមឈ្មោះថាឱកាសលោក។

ចំណែកខន្ធទាំងឡាយក្នុងលោកទាំងពីរ ឈ្មោះថាសង្ខារលោក។ មានសម្ដែងនៅក្នុងព្រះអដ្ឋកថាលោកសូត្រក្នុងខុទ្ទកនិកាយឥតិវុត្តកៈលេខ ៤៥ ភាគទី ៤/៥១៥។ នៅពេលមានការសិក្សាច្រើន បញ្ញាក៏ចម្រើនរឿយៗ ដែលធ្វើឱ្យអ្វីៗ មិនធ្លាប់ដឹង ក៏កាន់តែជ្រួតជ្រាបស្គាល់មុខមាត់ជាក់ច្បាស់ថាសង្ខារលោកតាក់តែងឡើងអាស្រ័យបច្ច័យមានអ្វីខ្លះ? សម្រាប់ផ្សំផ្គុំធាតុទាំង ៤ គឺៈ ធាតុដី ធាតុទឹក ធាតុភ្លើង និងធាតុខ្យល់ឱ្យនិម្មិតនូវរូបភាពច្រើនប្រការ ដែលទាក់ទងទៅនឹងជីវិតមនុស្សមានវេទនាក្នុងកាយសោយអារម្មណ៍ជាសុខជាទុក្ខឬអទុក្ខមសុខ និងរៀបចំចលនារបស់ធម្មជាតិប្រព្រឹត្តទៅតាមកម្មជាអ្នកចាត់ចែង។

# ១៤.ឧបនិស្ស័យនៃការត្រាស់ដឹងធម៌

# នៃព្រះនាងបដាចារាថេរី

កាលនាងធ្វើដំណើរទៅដោយទួញខ្សឹកខ្សួលថា «បុត្ររបស់យើងម្នាក់ត្រូវខ្លែងឆាបយកទៅ បុត្រម្នាក់ទៀតត្រូវទឹកបន្សាត់យកទៅ ស្វាមីក៏ស្លាប់ក្នុងទីស្ងាត់» ជួបបុរសម្នាក់ដែលធ្វើដំណើរមកអំពីក្រុងសាវត្ថី ក៏សួរថា ម្នាលអ្នកដ៏ចម្រើន លោកមកអំពីទីណា?

បុរស: ម្នាលនាងដ៏ចម្រើន ខ្ញុំមកពីក្រុងសាវត្ថី។

បដាចារាធីតា: ម្នាលអ្នកដ៏ចម្រើន ត្រកូលឈ្មោះនេះ នៅជិតថ្នល់ឯណោះក្នុងក្រុងសាវត្ថី លោកស្គាល់ទេ?

បុ. ម្នាលនាងដ៏ចម្រើន ខ្ញុំស្គាល់ច្បាស់ណាស់ ប៉ុន្តែសូមកុំសួរដល់ត្រកូលនោះឡើយ បើនាងចង់ដឹងត្រកូលដទៃ ចូរសួរមកចុះ។

ធី. ការចង់ដឹងអំពីត្រកូលដទៃរបស់ខ្ញុំ មិនមានទេ, ខ្ញុំចង់ជ្រាបតែត្រកូលនោះប៉ុណ្ណោះ ដូច្នោះសូមលោកប្រាប់មក។

បុ. ម្នាលនាង ខ្ញុំមិនសមគួរនឹងប្រាប់នាងឡើយ។

ធី. ម្នាលអ្នកដ៏ចម្រើន ចូរប្រាប់មកចុះ ។

បុ.ម្នាលនាងដ៏ចម្រើន ថ្ងៃនេះ នាងមានឃើញភ្លៀងធ្លាក់ចុះមកមួយយប់ទល់ភ្លឺ ទេ ?

ធី. ម្នាលអ្នកដ៏ចម្រើន ខ្ញុំបានឃើញហើយភ្លៀងនោះ បង្អុរចុះមកដើម្បីខ្ញុំតែប៉ុណ្ណោះ មិនមែនធ្លាក់ដើម្បីអ្នកដទៃទេ ប៉ុន្តែខ្ញុំនឹងប្រាប់ហេតុ

ដែលភ្លៀងបង្អុរចុះមកដើម្បីខ្ញុំដល់លោកជាខាងក្រោយ មេត្តាប្រាប់ការប្រព្រឹត្តទៅនៃព្រឹត្តិការណ៍ ក្នុងផ្ទះសេដ្ឋីនោះដល់ខ្ញុំមុនចុះ។

បុ. ម្នាលនាងដ៏ចម្រើន ថ្ងៃនេះនៅពាក់កណ្តាលយប់ ផ្ទះរលំសង្កត់ជនទាំង៣នាក់ គឺ សេដ្ឋី ១ ភរិយាសេដ្ឋី ១ បុត្រសេដ្ឋី ១ ជនទាំង ៣ នាក់នោះ ត្រូវគេដុតនៅលើជើងថ្ករ១ជាមួយនឹងគ្នា ម្នាលនាងដ៏ចម្រើននោះផ្សែងនៅប្រាកដ នៅឡើយ។

ក្នុងខណៈនោះ នាងមិនបានដឹងថា សំពត់ដែលនាងស្លៀកនោះរបូតចេញពីខ្លួនឡើយ ដល់នូវភាពជាមនុស្សវិកលចរិត ឈរនៅមួយកន្លែងទួញយំខ្សឹកខ្សួលរៀបរាប់ថាៈ បុត្រពីរនាក់ស្លាប់ហើយ, ស្វាមីរបស់យើងក៏ស្លាប់ត្រង់ផ្លូវស្ងាត់, មាតាបិតានិងបងប្រុស ក៏ត្រូវដុតនៅលើជើងថ្ករតែមួយជាមួយនឹងគ្នា, មនុស្សទាំងឡាយឃើញនាងហើយ ក៏ហៅនាងថា "ស្រីឆ្កួត" រួចក៏យកសម្រាម អាចម៍ដី បាចដាក់លើក្បាលនាង យកដុំដីគប់គ្រវែងនិងប្រហារដោយប្រការផ្សេងៗ។

ព្រះសាស្តា ទ្រង់គង់សម្តែងធម៌ នៅកណ្តាលបរិស័ទទាំងបួន ក្នុងវត្តជេតពនមហាវិហារ បានទតឃើញនាងដែលជាអ្នកបំពេញបារមីមកមួយសែនកប្ប ដល់ព្រមដោយអភិនីហារកំពុងដើរមក។

បានឮថា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាម**បទុមុត្តរៈ** នាងបដាចារានោះ ឃើញព្រះថេរីជាអ្នកទ្រទ្រង់វិន័យមួយរូប ដែលព្រះបទុមុត្តរសាស្តាទ្រង់តែងតាំងទុកជាដំណែងក្នុងជាឯតទគ្គៈផ្នែកខាងវិន័យធរ ហាក់ដូចជាបានសក្កទេវរាជចាប់ត្រង់ដើមដៃទៅក្នុងសួននន្ទវ័ន ទើបធ្វើសេចក្តីល្អហើយតាំងសេចក្តីប្រាថ្នាទុកថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីខ្ញុំព្រះអង្គក៏គប្បីបានជាស្រីដ៏ឆ្នើម ក្នុងចន្លោះនៃព្រះថេរីអ្នកទ្រទ្រង់វិន័យទាំងឡាយ ក្នុង

សម្នាក់ព្រះពុទ្ធជាម្ចាស់ ដូចជាព្រះថេរីនេះដែរ, ព្រះបទុមុត្តរសម្ពុទ្ធទ្រង់ពិចារណាមើលនូវអនាគត ដោយអនាគតំសញ្ញាណ ក៏ទ្រង់ជ្រាបថា សេចក្តីប្រាថ្នារបស់នាងនឹងបានសម្រេច ទើបទ្រង់ព្យាករថា ក្នុងអនាគតកាល ស្រីនេះនឹងបានជាស្រីដ៏ឆ្នើមជាងព្រះថេរីទាំងឡាយជាអ្នកទ្រទ្រង់វិន័យ មានឈ្មោះថា **បដាចារាថេរី** ក្នុងសាសនា នៃព្រះពុទ្ធព្រះនាមគោតម ។

ព្រះសាស្តាទ្រង់ជ្រាបថា នាងជាស្រីមានសេចក្តីប្រាថ្នាតាំងទុកហើយយ៉ាងនេះ ជាអ្នកបរិបូណ៌ដោយអភិនីហារ កំពុងតែដើរមកអំពីចម្ងាយ ទ្រង់មានសេចក្តីត្រិះរិះថា «វៀរចាកតថាគតហើយ អ្នកដទៃដែលឈ្មោះថា អាចជាទីពឹងរបស់ស្ត្រីនេះ រមែងមិនមាន» នាងមានមុខឆ្ពោះទៅកាន់វិហារដោយប្រការណា ព្រះសម្មាសម្ពុទ្ធក៏ទ្រង់ធ្វើយ៉ាងនោះ។

បរិស័ទឃើញនាងហើយ ក៏ពោលថា ម្នាលអ្នកទាំងឡាយ កុំឱ្យស្ត្រីឆ្កួតនេះមកកាន់ទីនេះឡើយ។

ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរជៀសចេញ កុំហាមឃាត់នាងឡើយ ក្នុងកាលដែលនាងមកជិតដល់ព្រះសម្មាសម្ពុទ្ធក៏ទ្រង់ត្រាស់ថាៈម្នាលប្អូនស្រីនាងចូរមានស្មារតីឡើង។ ក្នុងខណៈពេលនោះឯង នាងក៏ត្រឡប់មានស្មារតីដោយពុទ្ធានុភាព។ ក្នុងពេលនោះ នាងក៏បានដឹងថា សំពត់ដែលនាងស្លៀកនោះរបូតចេញអំពីខ្លួននាងហើយ ញុំាងហិរិ និងឱត្តប្បៈឱ្យកើតឡើង ហើយអង្គុយបិទបាំងខាងមុខបរិស័ទទាំងឡាយ។ គ្រានោះ បុរសម្នាក់បានបោះសំពត់ដណ្តប់ទៅឱ្យនាង។ នាងស្លៀកសំពត់នោះហើយ ចូលទៅគាល់ព្រះសាស្តាថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ទៀបព្រះបាទទាំងគូ ដែលមានពណ៌

ដូចមាស ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គជាទីពឹងដល់នាងខ្ញុំព្រះអង្គផងចុះ ព្រោះថាបុត្ររបស់ខ្ញុំម្នាក់ត្រូវខ្លែងឆាបទៅ ម្នាក់ទៀតត្រូវទឹកបន្សាត់ទៅ ស្វាមីស្លាប់កណ្ដាលផ្លូវស្ងាត់ មាតាបិតា និងបងប្រុសត្រូវផ្ទះបាក់សង្កត់ស្លាប់ គេដុតនៅលើជើងថ្ករជាមួយគ្នា។

ព្រះសាស្ដាទ្រង់ស្ដាប់នូវពាក្យរបស់នាងហើយ ក៏ទ្រង់ត្រាស់ថា ម្នាលនាងបដាចារា នាងកុំព្រួយបារម្ភឡើយ នាងបានមកកាន់សម្នាក់របស់យើង ដែលអាចជាទីពឹងពុំនាក់អាស្រ័យរបស់នាងហើយ ដូចយ៉ាងថា ឥឡូវនេះ បុត្រម្នាក់របស់នាងត្រូវខ្លែងឆាបទៅហើយ ម្នាក់ទៀតត្រូវទឹកបន្សាត់ទៅ ស្វាមីស្លាប់នៅត្រង់ផ្លូវស្ងាត់ មាតាបិតា និងបងប្រុសត្រូវផ្ទះបាក់សង្កត់យ៉ាងណា ទឹកភ្នែកដែលហូរចេញអំពីភ្នែករបស់នាង ដែលយំក្នុងសង្សារវដ្ដនេះ ក្នុងវេលាដែលបិយជនមានបុត្រជាដើមស្លាប់នោះ ច្រើនជាងទឹកមហាសមុទ្រទាំងបួនទៅទៀត ដូច្នេះហើយបានជាទ្រង់ត្រាស់ព្រះគាថាយ៉ាងនេះថា

*ទឹកក្នុងសមុទ្រទាំង ៤ មានប្រមាណតិច, ទឹកភ្នែករបស់បុគ្គលដែលទុក្ខពាល់ត្រូវហើយ សោយសោកមិនមែនតិច គឺច្រើនជាងទឹកមហាសមុទ្រនោះទៅទៀត, ម្នាលនាងព្រោះហេតុអ្វី ទើបនាងនៅប្រមាទ។*

លុះព្រះសាស្ដា ទ្រង់ត្រាស់អនមតគ្គបរិយាយសូត្រយ៉ាងនេះហើយ សេចក្ដីសោកក្នុងចិត្តរបស់នាង បានដល់នូវភាពធូរស្រាល។ គ្រានោះព្រះសាស្ដាទ្រង់ជ្រាបថា នាងមានសេចក្ដីសោកស្រាលស្ដើងហើយ ក៏ទ្រង់ដាស់តឿនទៀត ហើយត្រាស់ថា ម្នាលបដាចារដែលឈ្មោះថាបិយជន មានបុត្រជាដើម មិនអាចដើម្បីជាទីពឹង ឬជាទីពួនរបស់បុគ្គល ដែលទៅកាន់

បរលោកបានឡើយ ព្រោះហេតុដូច្នោះ បុត្រជាដើមទាំងនោះ សូម្បីមានក៏ឈ្មោះថាមិនមានដោយពិត គឺមានដូចជាអត់ ចំណែកបណ្ឌិតជម្រះសីលហើយ គួរជម្រះផ្លូវដែលញ៉ាំងសត្វឲ្យដល់និព្វានរបស់ខ្លួនប៉ុណ្ណោះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថាៈ

*បុត្រទាំងឡាយមិនមានដើម្បីជាទីពឹង បិតាក៏មិនមាន សូម្បីផៅពង្សក៏មិនមាន, កាលបុគ្គលត្រូវសេចក្តីស្លាប់គ្របសង្កត់ហើយ ភាពជាទីពឹងក្នុងញាតិទាំងឡាយ រមែងមិនមាន, បណ្ឌិតជ្រាបអំណាចប្រយោជន៍នោះហើយ សង្រួមក្នុងសីល គប្បីជម្រះផ្លូវទៅព្រះនិព្វានដោយរហ័សកុំបង្អង់។*

ក្នុងកាលចប់ទេសនា នាងបដាចារាបានដុតកិលេស សល់ប្រមាណប៉ុនលំអងធូលីក្នុងផែនដីដ៏ធំ ហើយតាំងនៅក្នុងសោតាបត្តិផល ជនដទៃទៀត ជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម។

ចំណែកនាងបដាចារានោះ លុះបានជាព្រះសោតាបន្នហើយ ក៏ទូលសូមបព្វជ្ជានឹងព្រះសាស្តា។ ព្រះសាស្តាទ្រង់បញ្ជូននាងទៅកាន់សម្នាក់របស់ពួកនាងភិក្ខុនី ដើម្បីឱ្យភិក្ខុនីទាំងឡាយបំបួសនាង។

លុះនាងបានឧបសម្បទាហើយ មានឈ្មោះថា "បដាចារា" ព្រោះនាងមានអាការៈធ្លាក់ចុះ គឺជាអ្នកប្រព្រឹត្តវៀរចាកផ្ទាំងសំពត់។ ថ្ងៃមួយនាងនាំយកទឹក ដោយក្អមមកលាងជើង ក្នុងពេលដែលនាងលាងនោះ នាងបានស្រោចនូវទឹក។ ទឹកដែលនាងស្រោចនោះ ហូរទៅបានបន្តិច

ក៏ជ្រាបចូលទៅក្នុងដីអស់។ ទឹកដែលនាងស្រោចលើកទី ២ ហូរទៅបានឆ្ងាយជាងទឹកដែលនាងស្រោចលើកដំបូង, ទឹកដែលនាងស្រោចលើកទី ៣ ហូរទៅបានឆ្ងាយជាងទឹកដែលនាងស្រោចលើកទី ១ និងទី ២។ នាងកាន់យកទឹកនោះឯងជាអារម្មណ៍ កំណត់វ័យទាំង ៣ ហើយគិតថា សត្វទាំងនេះ ស្លាប់ក្នុងបឋមវ័យក៏មាន ដូចទឹកដែលយើងស្រោចលើកដំបូង, ស្លាប់ក្នុងមជ្ឈិមវ័យក៏មាន ដូចទឹកដែលយើងចាក់ចុះលើកទី ២ ហូរទៅបានឆ្ងាយជាងនោះ ស្លាប់ក្នុងបច្ឆិមវ័យក៏មាន ដូចទឹកដែលយើងស្រោចលើកទី ៣ ហូរទៅបានឆ្ងាយសូម្បីជាងនោះ។

ព្រះសាស្តា ទ្រង់គង់នៅព្រះគន្ធកុដិ ទ្រង់ផ្សាយព្រះរស្មីទៅកាន់សម្នាក់របស់នាង ហាក់ដូចជាព្រះអង្គទ្រង់នៅចំពោះមុខនាង ត្រាស់ថា "ម្នាលនាងបដាចារា ការដែលនាងគិតនោះ យ៉ាងហ្នឹងហើយ ព្រោះថាការរស់នៅមួយថ្ងៃក្តី មួយខណៈក្តី របស់បុគ្គលដែលឃើញនូវការកើតឡើង និងការរលត់ទៅនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅរយឆ្នាំរបស់បុគ្គលដែលមិនបានឃើញការកើតឡើង និងការរលត់ទៅនៃបញ្ចក្ខន្ធ" លុះទ្រង់សម្តែងដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា:

**យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។**

បុគ្គលណារស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើង និងការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់បុគ្គល ដែលឃើញការកើតឡើង និងការវិនាសទៅប្រសើរជាង។

ក្នុងកាលចប់ព្រះធម៌ទេសនា នាងបដាចារាបានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ។

✍📖✍

# ១៥.អ្នកដែលគ្មានឧបនិស្ស័យ

បានឮថា ព្រះបាទសុប្បពុទ្ធអង្គនោះ ទ្រង់ចងអាឃាតនឹងព្រះសាស្ដា ដោយហេតុ ២ ប្រការគឺ គិតថា ព្រះសមណគោតមអង្គនេះចេញទៅបួសចោលធីតារបស់យើង ១ បំបួសបុត្ររបស់យើងហើយ ស្ថិតនៅក្នុងឋានៈជាអ្នកមានពៀរនឹងបុត្ររបស់យើង ១ ។ ថ្ងៃមួយទ្រង់ព្រះតម្រិះថា យើងនឹងមិនឱ្យព្រះសមណគោតម យាងទៅកាន់ទីនិមន្ត លុះទ្រង់មានព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់គង់សោយទឹកច័ណ្ឌក្នុងចន្លោះផ្លូវ ដើម្បីបិទផ្លូវ ដែលជាទីយាងទៅកាន់ទីនិមន្តរបស់ព្រះសាស្ដា។ គ្រានោះ កាលព្រះសាស្ដាដែលមានសមណសង្ឃហែហម ស្ដេចយាងមកជិតដល់ទីនោះ ពួកមហាតលិកក្រាបទូលព្រះរាជាថា បពិត្រមហារាជ ព្រះសាស្ដាស្ដេចយាងមកហើយ ពេលនោះព្រះបាទសុប្បពុទ្ធ បានត្រាស់ទៅកាន់រាជបុរសថា អ្នកទាំងឡាយ ចូរទៅប្រាប់ព្រះសមណគោតមចុះថា ព្រះសមណគោតមអង្គនេះ មិនមែនចាស់ជាងយើងទេ យើងនឹងមិនឲ្យផ្លូវដល់ព្រះសមណគោតមអង្គនោះទេ សូម្បីពួកមហាតលិកទូលតឿនរឿយៗយ៉ាងណាក៏ដោយ ក៏ទ្រង់នៅតែគង់ ត្រាស់បញ្ជាយ៉ាងនោះដដែល។

ព្រះសាស្ដា មិនបានផ្លូវអំពីសម្នាក់ព្រះមាតុល (អ៊ំ) ទើបស្ដេចយាងត្រឡប់ទៅវិញ។ ឯព្រះបាទសុប្បពុទ្ធក៏បញ្ជូនចារបុរស (អ្នកស៊ើបការណ៍) ម្នាក់ទៅ ដោយព្រះតម្រាស់ថា អ្នកឯងចូរទៅស្ដាប់នូវពាក្យរបស់ព្រះសមណគោតមអង្គនោះ ហើយចូរត្រឡប់មកវិញ។ ចំណែកព្រះសាស្ដាកាលព្រះអង្គយាងត្រឡប់មកវិញ ទ្រង់ធ្វើនូវការញញឹមឱ្យប្រាកដ ព្រះអានន្ទត្ថេរ ក៏បានក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាបច្ច័យនៃ

កម្ម គឺការញញឹមរបស់ព្រះអង្គ? ទើបទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកមានឃើញព្រះបាទសុប្បពុទ្ធទេ? ព្រះអានន្ទត្ថេរបានទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ។ ព្រះសាស្តាទ្រង់ត្រាស់ថា ព្រះបាទសុប្បពុទ្ធនោះមិនឱ្យផ្លូវដល់ព្រះពុទ្ធប្រាកដស្មើដូចជាតថាគត បានធ្វើនូវកម្មដ៏ធ្ងន់ក្នុងថ្ងៃទី៧ អំពីថ្ងៃនេះ ព្រះអង្គនឹងចូលទៅកាន់ផែនដី (ធរណីស្រូប) ក្នុងទីជិតជើងជណ្តើរឮដ៏ខាងក្រោមនៃប្រាសាទ ៧ជាន់។ ចារបុរសនោះ បានស្តាប់នូវព្រះតម្រាស់របស់ព្រះមានព្រះភាគហើយ ទៅកាន់សម្នាក់ព្រះបាទសុប្បពុទ្ធ។ ព្រះបាទសុប្បពុទ្ធត្រាស់សួរថា ក្មួយរបស់យើងត្រឡប់ទៅវិញ បាននិយាយនូវពាក្យអ្វីខ្លះទេ? ចារបុរសនោះ បានក្រាបទូលតាមដែលខ្លួនបានឮ ។ ព្រះបាទសុប្បពុទ្ធ ទ្រង់ព្រះសណ្តាប់នូវពាក្យដែលចារបុរសនោះ ក្រាបទូលហើយ ទ្រង់ត្រាស់ថា ឥឡូវនេះ ទោសក្នុងការនិយាយនៃក្មួយរបស់យើង រមែងមិនមាន, ព្រះអង្គត្រាស់នូវពាក្យណា ពាក្យនោះរមែងមានដោយប្រការដូច្នោះមែន ប៉ុន្តែសូម្បីដូច្នោះក៏ដោយ ពេលនេះយើងនឹងផ្ចាញ់ផ្ចាលព្រះអង្គ ដោយការនិយាយកុហក ព្រោះព្រះអង្គមិនបានត្រាស់នឹងយើងដោយប្រាកដថា ព្រះបាទសុប្បពុទ្ធនឹងត្រូវបានធរណីស្រូបក្នុងថ្ងៃទី ៧ គ្រាន់តែត្រាស់ថា សុប្បពុទ្ធនឹងត្រូវធរណីស្រូបក្នុងទីជិតជើងជណ្តើរខាងក្រោមប្រាសាទប៉ុណ្ណោះ បើដូច្នោះតាំងអំពីថ្ងៃនេះទៅយើងមិនទៅកាន់ទីនោះ កាលបើដូច្នោះ យើងមិនត្រូវធរណីស្រូបក្នុងទីនោះឡើយ យើងនឹងផ្ចាញ់ផ្ចាលក្មួយរបស់យើង ដោយការនិយាយកុហក។ ព្រះបាទសុប្បពុទ្ធបញ្ជាឱ្យពួកមហាតលិកជញ្ជូនវត្ថុទាំងពួង ដែលជាគ្រឿងឧបភោគរបស់ព្រះអង្គ ទៅទុកលើប្រាសាទ ៧ ជាន់ បញ្ជាឱ្យដកជណ្តើរ ឱ្យបិទទ្វារ ដាក់មនុស្សមាឌមាំៗ ឱ្យយាមទ្វារមួយពីរនាក់ ហើយ

ត្រាស់ថា ប្រសិនបើពួកឯងឃើញយើងដើរចុះទៅខាងក្រោម ដោយប្រមាទសោត ពួកឯងគប្បីហាមឃាត់យើង លុះពោលដូច្នេះហើយ ក៏ទ្រង់គង់ក្នុងបន្ទប់ដ៏មានសិរីលើផ្ទៃប្រាសាទជាន់ទី ៧ ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវរឿងនោះហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទសុប្បពុទ្ធនេះ កុំថាឡើយគង់នៅលើផ្ទៃប្រាសាទរហូតនោះ ទោះបីហោះឡើងទៅកាន់វេហាស៍ ហើយអង្គុយក្នុងអាកាសក៏ដោយ ចូលទៅកាន់មហាសមុទ្រដោយសំពៅក៏ដោយ ចូលទៅកាន់ចន្លោះភ្នំក៏ដោយ ដែលឈ្មោះថា ភាវៈនៃព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ រមែងមិនមានពីរ ព្រះអង្គនឹងត្រូវធរណីស្រូប ក្នុងទីដែលតថាគតពោលហើយនោះឯង។ លុះដល់ថ្ងៃទី ៧ ក្នុងវេលាដូចដែលព្រះបាទសុប្បពុទ្ធបិទផ្លូវភិក្ខាចាររបស់ព្រះសាស្តានោះឯង សេះមង្គលរបស់ព្រះអង្គ ដែលនៅខាងក្រោមប្រាសាទ លោតកញ្ច្រោលឡើង ផាយធាក់ជញ្ជាំងនោះៗ។ ព្រះអង្គស្ថិតនៅប្រាសាទជាន់លើនោះឯង បានឮសំឡេងសេះ ក៏ត្រាស់សួរថា នោះជាសំឡេងអ្វី? ពួកមហាតលិកក្រាបទូលព្រះរាជាថា សេះមង្គលលោតកញ្ច្រោល។ ចំណែកសេះនោះ គ្រាន់តែឃើញព្រះបាទសុប្បពុទ្ធភ្លាមក៏ឈប់ស្ងៀម។ ខណៈនោះ ព្រះអង្គមានបំណងនឹងចាប់សេះនោះ បានស្តេចក្រោកចាកទីប្រថាប់ បែរព្រះភក្ត្រមករកទ្វារទាំងឡាយ។ ទ្វារប្រាសាទទាំង ៧ ក៏បើកឯង ជណ្តើរទាំងឡាយក៏តាំងនៅក្នុងទីដូចដើម។ ពួកមនុស្សដែលមានមាឌធំៗ ត្រង់ជាន់នោះៗ ចាប់ព្រះបាទសុប្បពុទ្ធត្រង់ព្រះសូរង ហើយច្រានឱ្យមានព្រះភក្ត្រចុះមកខាងក្រោម ខណៈនោះ មហាប្រថពី បែកញែករង់ចាំទទួលព្រះបាទ

សុប្បពុទ្ធ នៅជិតជើងជណ្តើរខាងក្រោមប្រាសាទនោះឯង, ព្រះអង្គលិចចូលទៅក្នុងផែនដី ហើយក៏កើតក្នុងអវិចីនរកនៅពេលនោះឯង។

តាមរឿងរ៉ាវនៃព្រះបាទសុប្បពុទ្ធដែលកើតក្នុងត្រកូលសក្យផង ជាអ៊ំនិងជាឪពុកក្មេករបស់ព្រះសម្មាសម្ពុទ្ធផង ក៏ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃមិនអាចជួយបាន ព្រោះព្រះអង្គអាស្រ័យនឹងធម៌អាក្រក់ គឺអកុសល។

# ១៦.រឿងព្រះមិលក្ខត្ថេរ

បានឮមកថា ព្រះមិលក្ខត្ថេរៈនោះ ក្នុងកាលនៅជាគ្រហស្ថ ចិញ្ចឹមជីវិតដោយការធ្វើបាណាតិបាត ដាក់ចម្រូងអន្ទាក់ និងអង្គប់ មួយមុខ ១០០ ក្នុងព្រៃ សន្សំនូវបាបដ៏ច្រើន។ ក្រោយមក ថ្ងៃមួយនាយមិលក្ខៈនោះ បរិភោគនូវសាច់ដែលអាំងឆ្អិនហើយឮដំរងើកភ្លើង។ ត្រាច់ទៅក្នុងទីដាក់អន្ទាក់ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ទើបបើកក្អមទឹក ដែលតាំងនៅមិនឆ្ងាយពីព្រះថេរៈអ្នកនៅក្នុងព្រៃមួយអង្គ ដែលកំពុងតែដើរចង្ក្រម កាលមិនឃើញទឹកសូម្បីត្រឹមតែទទឹកដៃ ក៏ក្រោធខឹង ហើយពោលថា «នែភិក្ខុ លោកបរិភោគភិក្ខា ដែលគ្រហស្ថទាំងឡាយប្រគេនហើយ ក៏សឹងលក់ លោកមិនដងទឹកដាក់ក្នុងពាងទឹក គ្រាន់ធ្វើជាថ្នាំភ្នែកខ្លះ ការធ្វើដូច្នេះ មិនគួរទេ»។ ព្រះថេរៈគិតថា អាត្មាអញបានដងទឹកដាក់ពាងពេញអស់ហើយ ហេតុអ្វីទៅហ្ន៎ ទើបនាយមិលក្ខៈនេះ ពោលដូច្នេះ? ដូច្នេះហើយក៏និមន្តទៅមើល បានឃើញពាងទឹកពេញប្រៀបហើយ ក៏យកស័ង្ខសម្រាប់ដងទឹក ដងចាក់ឱ្យពេញហើយទើបឱ្យ។ នាយមិលក្ខៈនោះ ផឹកទឹកគ្រប់ ៣២ស័ង្ខ ហើយមានចិត្តសង្វេគថា «ធម្មតាពាងទឹកដែលមានទឹកពេញហើយយ៉ាងដូច្នេះ អាស្រ័យកម្មរបស់អាត្មាអញ ទើបបានកើតឡើងប្រៀបដូចជាអំបែងក្បឿងដ៏ក្តៅ អត្តភាពរបស់អាត្មាអញក្នុងអនាគតកាល នឹងកើតទៅជាយ៉ាងដូចម្តេចហ្ន៎? ដូច្នេះហើយក៏ពោលថា «បពិត្រលោកម្ចាស់ សូមលោកម្ចាស់ មេត្តាញ៉ាំងខ្ញុំព្រះករុណាឱ្យបានបួសផង»។ ព្រះថេរៈប្រាប់កម្មដ្ឋានមានស្បែកជាគម្រប់៥ ហើយបានញ៉ាំងនាយមិលក្ខៈនោះឱ្យបួសហើយ។ ស្ថានទីដែលនាយមិលក្ខៈនោះ សម្លាប់

សត្វម្រឹគ និងជ្រូកជាច្រើន និងស្ពានទី ដែលនាយមិលក្ខៈនោះដាក់អន្ទាក់ និងអង្គុប់ទាំងឡាយ រមែងប្រាកដ ដល់សាមណេរមិលក្ខៈនោះ ដែលកំពុងតែធ្វើនូវសមណធម៌ កាលបើសាមណេរមិលក្ខៈនោះ តាមរឮកនូវកម្មដែលបានធ្វើហើយនោះ, សេចក្តីក្តៅក្រហាយ ក៏កើតឡើងក្នុងសរីរាង្គកាយ។ ចិត្តរមែងមិនឡើងកាន់វីថិនៃកម្មដ្ឋាន ដូចជាគោកោងមិនព្រមដើរទៅកាន់គន្លងនង្គ័លដូច្នោះ ។

សាមណេរមិលក្ខៈនោះ ត្រូវសេចក្តីមិនត្រេកអរគ្របសង្កត់ហើយដោយគិតថា អាត្មាអញនឹងនៅធ្វើអ្វី ដោយភាពជាសមណៈ។ ដូច្នេះហើយទៅកាន់សម្នាក់នៃព្រះថេរៈ ថ្វាយបង្គំហើយក៏ពោលថា បពិត្រលោកម្ចាស់ខ្ញុំព្រះករុណា មិនអាចធ្វើសមណធម៌បានឡើយ។ ព្រះថេរៈពោលថា ចូរអ្នកធ្វើនូវហត្ថកម្មចុះ ។ សាមណេរនោះ បានទៅកាប់ដើមឈើ មានដើមឧទុម្ពរជាដើម មកធ្វើជាគំនរយ៉ាងធំ ហើយសួរថា ឥឡូវនេះខ្ញុំព្រះករុណានឹងធ្វើអ្វី? ព្រះថេរៈបានប្រាប់ថា ចូរអ្នកដុតគំនរឈើនោះចោល។ សាមណេរនោះដុតភ្លើងក្នុងទិសទាំង ៤ ហើយ ក៏មិនអាចដើម្បីដុតឱ្យឆេះបានឡើយ។ ព្រះថេរៈពោលថា បើដូច្នោះ ចូរអ្នកគេចចេញទៅ។ ហើយធ្វើប្រឹថពីឱ្យបែកចេញជាពីរផ្នែកហើយ យកភ្លើងមានពន្លឺប្រមាណស្មើនឹងពន្លឺអំពិលអំពែកអំពីអវិចីនរក មកដាក់លើគំនរឈើនោះឯង។ ព្រះថេរៈនោះ ដុតគំនរឈើដែលមានទំហំប្រមាណប៉ុណ្ណោះ ឱ្យឆេះមួយរំពេច ដូចជាដុតស្លឹកឈើស្ងួតដូច្នោះ។ គ្រានោះ ព្រះថេរៈលុះសម្តែងអវិចីនរកហើយ ទើបញ៉ាំងសេចក្តីសង្វេគឱ្យកើតឡើងដល់សាមណេរមិលក្ខៈនោះថា «បើអ្នកនឹងសឹក អ្នកនឹងឆេះនៅក្នុងអវិចីនរកនោះ»។

សាមណេរមិលក្ខៈនោះ ចាប់ដើមតាំងពីបានឃើញអវិចីនរកមក ក៏ភ័យស្លុតស្លន់ ទើបសួរថា «បពិត្រលោកម្ចាស់ដ៏ចម្រើន តើព្រះពុទ្ធ-សាសនាជាហេតុនាំសត្វឱ្យចេញចាកទុក្ខឬ » ដូច្នេះ ។ ព្រះថេរៈប្រាប់ថា «ម្នាលអ្នកដ៏មានអាយុ មែនហើយ»។ សាមណេរនោះ ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលបើព្រះពុទ្ធសាសនា ជានិយ្យានិកៈ ខ្ញុំនឹងធ្វើនូវការរើខ្លួនឱ្យទាល់តែរួច ចូរលោកម្ចាស់កុំខ្វល់ឡើយ ដូច្នេះ។ តាំងអំពីពេលនោះមក លោកធ្វើនូវសមណធម៌ ប្រឹងប្រែងព្យាយាមបំពេញវត្តប្រតិបត្តិ កាលបើសេចក្ដីងោកងុយគ្របសង្កត់ ក៏បានដាក់ចំបើងទទឹកលើក្បាលហើយ គង់ទម្លាក់ជើងទាំង ២ ចូលទៅក្នុងស្រះទឹក។ ថ្ងៃមួយសាមណេរនោះ ត្រងទឹកហើយដាក់ក្អមទឹកនៅលើភ្លៅ បានឈររង់ចាំការស្រក់ដាច់អស់ទៅនៃទឹកពាង។ លំដាប់នោះឯង ព្រះថេរៈឱ្យនូវនិទ្ទេសនេះដល់សាមណេរថាៈ

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**
**សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ។**

យស រមែងចម្រើនកុះករ ដល់បុគ្គលមានសេចក្ដីប្រឹងប្រែង មានស្មារតី មានការងារស្អាត ជាអ្នកពិចារណារួចហើយទើបធ្វើ ជាអ្នកសង្រួមរស់នៅដោយធម៌ មិនមានសេចក្ដីប្រមាទ។

សាមណេរមិលក្ខៈនោះ បានបង្អោននូវគាថាទាំង ៤ បាទ នោះមកក្នុងខ្លួនថា «ធម្មតាបុគ្គលអ្នកមានសេចក្ដីប្រឹងប្រែង គប្បីដូចជាអាត្មា សូម្បីបុគ្គលអ្នកមានសតិស្មារតី ក៏គប្បីដូចជាអាត្មាអញ»។ល។ សូម្បីបុគ្គលអ្នកមិនប្រមាទ ក៏គប្បីដូចជាអាត្មាអញផងដែរ។

សាមណេរមិលក្ខៈនោះ លុះបង្អោនគាថានោះមកទុកក្នុងខ្លួន យ៉ាងដូច្នេះហើយ ឈរនៅក្នុងជំហានជើងនោះឯង កាត់ផ្តាច់នូវសំយោជនៈដែលជាចំណែកខាងក្រោម ៥ យ៉ាង ហើយញ៉ាំងមគ្គ និងផលទាំងឡាយ ៣ ឱ្យកើតឡើងហើយ ។

(មានក្នុងអដ្ឋកថាទុតិយវគ្គ ឯកនិបាត អង្គុត្តរនិកាយ)

# ១៧.អត្ថរបស់អាសវៈ

**អាសវា វិយាតិ = អាសវា** ធម៌ណា មានសភាព ដូចសុរា ធម៌នោះ ឈ្មោះថា អាសវៈ បានដល់ លោភៈ ទិដ្ឋិ មោហៈ ។ ពាក្យថា អាសវៈ ចែកចេញជា២បទគឺ **អា + សវ = អាសវ។ អា** ប្រែថា វដ្តទុក្ខដ៏អង្វែង ដែលមិនមានកំណត់។ **សវៈ** ប្រែថា ចម្រើនរុងរឿង។ កាលរួមចូលទាំង ២ បទហើយ ប្រែថា ធម៌ដែលធ្វើឱ្យវដ្តទុក្ខដ៏យូរអង្វែង មិនមានកំណត់នោះ ចម្រើនរុងរឿងមិនមានទីបំផុត។ បានសេចក្តីថា ការប្រព្រឹត្តទៅនៃខន្ធ ៥ របស់សត្វទាំងឡាយម្នាក់ៗ សុទ្ធតែកើតហើយស្លាប់ៗហើយកើត រស់នៅយ៉ាងនេះអស់កាលជាយូរអង្វែង មិនមានកំណត់។ សេចក្តីនេះបង្ហាញឱ្យឃើញថា វដ្តទុក្ខរបស់សត្វទាំងឡាយនោះ ចម្រើនរុងរឿងជាអនេកមិនមានទីបំផុត។ ម្យ៉ាងទៀតពាក្យថា **អា** ប្រែថា មានដែនកំណត់ដល់ភវគ្គភូមិ គឺនេវសញ្ញានាសញ្ញាយតនភូមិ ឬមានដែនកំណត់ដល់គោត្រភូញាណ។ **សវៈ** ប្រែថា កើតបាន ឬហូរទៅបាន។ រួមបញ្ចូលគ្នា ប្រែថាកើតបាន ឬហូរទៅបានរហូតដល់ភវគ្គភូមិ ឬគោត្រភូ ដោយអំណាចការធ្វើឱ្យជាអារម្មណ៍។ **អាសវៈ** សំដៅយកគ្រឿងត្រាំនៅដ៏យូរឧបមាដូចជាសុរា ជាវត្ថុដែលត្រូវត្រាំទុកយូរ ទើបបណ្តាលឱ្យអ្នកពិសាអាចស្រវឹងបាត់ស្មារតី អាចធ្វើនូវអំពើដែលមិនគួរធ្វើបាន យ៉ាងណា សភាពនៃធម៌ ដែលជាគ្រឿងត្រាំដ៏អង្វែង នៅក្នុងខន្ធសន្តានរបស់សត្វ ក៏ធ្វើឱ្យសត្វទាំងឡាយត្រូវស្រវឹង វង្វេងវង្វាន់ ភ្លេចស្មារតី អាចធ្វើនូវអំពើដែលមិនគួរធ្វើ សភាវធម៌នេះឯង ឈ្មោះថា អាសវៈ។ **អាសវៈ** បានដល់

លោភៈ ទិដ្ឋិ មោហៈ ធម៌ទាំង ៣ នេះ ត្រាំត្រែងនៅក្នុងខន្ធសន្តាន របស់សត្វទាំងឡាយ ដែលមិនអាចរាប់ភព រាប់ជាតិបានឡើយ។ ធម៌ទាំង នេះ កាលបើមានក្នុងបុគ្គលណា ធ្វើឱ្យចិត្តសន្តានបុគ្គលនោះស្រវឹងវង្វេង ភ្លេចស្មារតី ក៏ធ្លាក់ក្នុងអំណាចនៃលោភៈខ្លះ ទិដ្ឋិខ្លះ និងមោហៈខ្លះ ជាហេតុ ធ្វើឱ្យហ៊ានធ្វើនូវអំពើទុច្ចរិតផ្សេងៗ មានកាយទុច្ចរិតជាដើម ។ តាមធម្មតា លោភៈ ទិដ្ឋិ មោហៈនេះ កើតឡើងដោយអាស្រ័យលោកិយធម៌ និងបញ្ញត្តិ-ធម៌ ស្រេចទៅហើយ ដូច្នេះដែលសម្ដែងថា កើតបានរហូតដល់ភវគ្គភូមិ ឬគោត្រភូញាណនោះ មិនមានសេចក្ដីពិសេសយ៉ាងណាទេ បានសេចក្ដីថា នេវសញ្ញានាសញ្ញាយតនភូមិក៏ដោយ គោត្រភូក៏ដោយ ឬវោទានក៏ដោយ ទាំងនេះនៅជាលោកិយធម៌ ដូច្នេះហើយទើបជាអារម្មណ៍របស់ លោភៈ ទិដ្ឋិ មោហៈ។ អាសវធម៌ ទាំង៣នេះ កើតបាន ឬហូរទៅបានរហូតដល់ភវគ្គភូមិ ឬគោត្រភូ ដូចមានវចនត្ថៈថាៈ

**ភវតោ អាភវគ្គោ ធម្មតោ អាគោត្រភូម្ហា សវន្តិ អារម្មណករណវសេន បវត្តន្តីតិ = អាសវា។** ប្រែថា ធម៌ទាំងឡាយណា ហូរទៅដល់ ឬកើតបាន កាលពោលដោយភូមិដល់ភវគ្គភូមិ កាលពោលដោយធម៌ ដល់គោត្រភូញាណ ដោយអំណាចធ្វើឱ្យជាអារម្មណ៍ ដូច្នេះធម៌ទាំងនោះ ឈ្មោះថា **អាសវៈ**។ មានចំណុចដែលគួរសង្ស័យថា លោភៈ ទិដ្ឋិ មោហៈ ឈ្មោះថាអាសវៈ ព្រោះថាជាគ្រឿងត្រាំនៅក្នុងខន្ធសន្តានរបស់សត្វទាំងឡាយ អស់កាលជាអង្វែង ឬហូរទៅបានកើតបានរហូតដល់ភវគ្គភូមិ ឬគោត្រភូតាមដែលបានសម្ដែងមកហើយនោះ ចុះដូចជា អហិរិកៈ អនោត្តប្បៈ មានៈ ជាដើម ក៏កើតនៅក្នុងខន្ធសន្តានរបស់

សត្វទាំងឡាយអស់កាលជាអង្វែងផងដែរ ហើយក៏អាចកើតបាន មានភវគ្គភូមិ ឬគោត្រភូជាអារម្មណ៍ដូចគ្នាដែរ ហេតុអ្វីព្រះសម្មាសម្ពុទ្ធ ទើបព្រះអង្គមិនទ្រង់ចាត់អកុសលចេតសិកទាំងនោះ ជាអាសវៈផងទៅ ព្រោះហេតុអ្វី? ឆ្លើយថា ទាំងនេះព្រោះលោភៈ ទិដ្ឋិ មោហៈ មានសភាពធំទូលាយ និងប្រាកដជាក់ច្បាស់ច្រើនជាងអកុសលចេតសិកដទៃៗទៀត ប្រៀបបីដូចជា ពន្លឺព្រះអាទិត្យ រមែងមានពន្លឺភ្លឺជាងពន្លឺដទៃៗ មានពន្លឺព្រះចន្ទ ឬពន្លឺភ្លើង ជាដើម។ អកុសលចេតសិកដួងដទៃៗ សូម្បីតែអាចជាគ្រឿងត្រាំនៅក្នុងខន្ធសន្តានរបស់សត្វទាំងឡាយ ឬអាចហូរទៅបានដល់ភវគ្គភូមិ ឬគោត្រភូ ដោយអំណាចធ្វើឱ្យជាអារម្មណ៍ក៏ពិតមែន ប៉ុន្តែ សភាពជាគ្រឿងត្រាំក្តី ឬសភាពហូរទៅបានក្តី ទាំងអស់នេះរមែងជាក់ច្បាស់ក្រៃលែងជាង, ប្រាកដតែក្នុងធម៌ដែលជាលោភៈ ទិដ្ឋិ មោហៈ តែម្យ៉ាងប៉ុណ្ណោះ ហេតុដូច្នោះហើយ ទើបព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គ មិនទ្រង់សម្តែងនូវអកុសលចេតសិកដួងដទៃៗទៀត ថាជា **អាសវៈ** ឡើយ។ ដូច្នេះធម៌ ដែលជាគ្រឿងត្រាំ និងហូរទៅបានដល់ភវគ្គភូមិ ឬគោត្រភូនោះ បានដល់ លោភៈ ទិដ្ឋិ មោហៈ។

## ១៨.អាសវៈ ៤ យ៉ាង

**១.កាមាសវៈ** គ្រឿងត្រាំ គឺកាម (ដែលជាកិលេសកាម)
**២.ភវាសវៈ** គ្រឿងត្រាំ គឺភព
**៣.ទិដ្ឋាសវៈ** គ្រឿងត្រាំ គឺទិដ្ឋិ
**៤.អវិជ្ជាសវៈ** គ្រឿងត្រាំ គឺអវិជ្ជា។

**១.កាមាសវៈ** ធម៌ដែលជាគ្រឿងត្រាំ ឬហូរទៅក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់លោភចេតសិក ក្នុងលោភមូលចិត្ត ៨ ដួង។

**២.ភវាសវៈ** ធម៌ដែលជាគ្រឿងត្រាំ ឬហូរទៅអាស្រ័យដោយសេចក្ដីត្រេកអរ ជាប់ចិត្តនៅក្នុងអត្តភាពនៃខ្លួនក្នុងរូបភព អរូបភព ឬក្នុងរូបឈាន និងអរូបឈាន អង្គធម៌បានដល់ លោភចេតសិក ក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង។

**៣.ទិដ្ឋាសវៈ** ធម៌ជាគ្រឿងត្រាំ ឬហូរទៅអាស្រ័យដោយសេចក្ដីយល់ខុស ឃើញខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង។

**៤.អវិជ្ជាសវៈ** ធម៌ដែលជាគ្រឿងត្រាំ ឬហូរទៅ អាស្រ័យដោយសេចក្ដីវង្វេង សេចក្ដីល្ងង់ មិនដឹងហេតុផលតាមសេចក្ដីពិត អង្គធម៌បានដល់ មោហចេតសិក ក្នុងអកុសលចិត្ត ១២ ដួង។ ដូច្នេះ អាសវធម៌ទាំង ៤ ប្រការនេះ មានអង្គធម៌ត្រឹមតែ ៣ ប៉ុណ្ណោះគឺ លោភចេតសិក ១ ទិដ្ឋិចេតសិក ១ និងមោហចេតសិក ១ ។ ក្នុងអដ្ឋកថាអដ្ឋសាលិនី សម្ដែងពន្យល់អត្ថនៃអាសវៈថាៈ

**បញ្ចកាមគុណិកោ រាគោ កាមាសវោ នាម ។**

សេចក្ដីត្រេកអរ ពេញចិត្ត នៅក្នុងកាមគុណារម្មណ៍ទាំង ៥ ឈ្មោះថា កាមាសវៈ។

**រូបារូបភវេសុ ឆន្ទរាគោ ឈាននិកន្តិ សស្សតទិដ្ឋិសហជាតោ ភវវសេន បត្ថនា ភវាសវោ នាម។**

សេចក្តីត្រេកអរពេញចិត្តក្នុងរូបភព និង អរូបភព សេចក្តីពេញចិត្តនៅក្នុងឈានសមាបត្តិ សេចក្តីត្រេកអរពេញចិត្តក្នុងអារម្មណ៍ ដែលកើតព្រមនឹងសស្សតទិដ្ឋិ សេចក្តីប្រាថ្នាដោយអំណាចភព ឈ្មោះថា ភវាសវៈ។

**ទ្វាសដ្ឋីទិដ្ឋិយោ ទិដ្ឋាសវោ នាម។**

សេចក្តីយល់ខុស គឺទិដ្ឋិ ៦២ យ៉ាង ឈ្មោះថា **ទិដ្ឋាសវៈ**។

**អដ្ឋសុ ឋានេសុ អញ្ញាណំ អវិជ្ជាសវោ នាម។**

សភាពមិនដឹងក្នុងសភាវធម៌តាមសេចក្តីពិត ៨ ប្រការគឺៈ

**១.ទុក្ខេ អញ្ញាណំ** មិនដឹងក្នុងទុក្ខសច្ចៈ

**២.ទុក្ខសមុទយេ អញ្ញាណំ** មិនដឹងក្នុងសមុទយសច្ចៈ

**៣.និរោធេ អញ្ញាណំ** មិនដឹងក្នុងនិរោធសច្ចៈ

**៤.ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ** មិនដឹងក្នុងមគ្គសច្ចៈ ដែលជាផ្លូវនាំឱ្យដល់ទីរលត់ទុក្ខ។

**៥.បុព្វន្តេ អញ្ញាណំ** មិនដឹងក្នុងខន្ធ ធាតុ អាយតនៈដែលជាអតីត។

**៦.អបរន្តេ អញ្ញាណំ** មិនដឹងក្នុងខន្ធ ធាតុ អាយតនៈដែលជាអនាគត។

**៧.បុព្វន្តាបរន្តេ អញ្ញាណំ** មិនដឹងក្នុងខន្ធ ធាតុ អាយតនៈដែលជាអតីតៈ និងអនាគត។

**៨.ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ** មិនដឹងក្នុងបដិច្ចសមុប្បាទ គឺមិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នាកើតឡើងថា«ធម៌នេះជាបច្ច័យ»។

សភាពមិនដឹងទាំងអស់នេះ ឈ្មោះថា អវិជ្ជាសវៈ។

## ១៩.ធម៌ដែលលះអាសវៈ ៤ យ៉ាង

**កាមាសវោ អនាគាមិមគ្គេន បហីយតិ ភវាសវោ អរហត្តមគ្គេន ទិដ្ឋាសវោ សោតាបត្តិមគ្គេន អវិជ្ជាសវោ អរហត្តមគ្គេន។**

១.**កាមាសវៈ** លះបង់បានដោយបញ្ញា ក្នុងអនាគាមិមគ្គចិត្ត

២.**ភវាសវៈ** លះបង់បានដោយបញ្ញា ក្នុងអរហត្តមគ្គចិត្ត

៣.**ទិដ្ឋាសវៈ** លះបង់បានដោយបញ្ញា ក្នុងសោតាបត្តិមគ្គចិត្ត

៤.**អវិជ្ជាសវៈ** លះបង់បានដោយបញ្ញាក្នុងអរហត្តមគ្គចិត្ត។

# ២០.អត្ថរបស់អនុស័យ

អនុស័យ ជាឈ្មោះរបស់កិលេសដ៏ល្អិតម្យ៉ាង ដែលដេកសំងំក្នុងខន្ធសន្តានរបស់សត្វទាំងឡាយ។ ដរាបណា នៅមិនទាន់បានសម្រេចជាព្រះអរហន្តទេ អនុស័យនេះ ក៏នឹងនៅមានជាប្រចាំក្នុងខន្ធសន្តានជារឿយៗតទៅ ព្រោះហេតុនោះ ទើបអនុស័យជាកិលេសដែលជ្រកសំងំ មិនចេញបង្ហាញដើម្បីឱ្យអ្នកណាមួយបានឃើញ បានប្រច័ក្សឡើយ វៀរតែព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ដែលព្រះអង្គទ្រង់អាចដឹងនូវអនុស័យរបស់សត្វទាំងឡាយបាន។ ធម្មតាអនុសយក្កិលេសនោះ ជាធម៌ល្អិតជ្រកសំងំនៅជាប្រចាំក្នុងខន្ធសន្តាន មិនបញ្ចេញបង្ហាញឱ្យប្រាកដទៅតាមទ្វារណាមួយឡើយ។ លុះកាលណាមានអារម្មណ៍ផ្សេងៗ មកប៉ះខ្ទប់តាមផ្លូវភ្នែក ត្រចៀក អណ្តាត កាយ និងចិត្តហើយ អនុស័យដែលដេកសំងំនៅនោះ ក៏ប្រែសភាពជាបរិយុដ្ឋានកិលេស គឺកិលេសយ៉ាងកណ្តាលប្រាកដឡើងតាមផ្លូវចិត្ត។ ហើយប្រសិនបើបរិយុដ្ឋានកិលេសនេះ មានកម្លាំងខ្លាំងឡើង ក៏នឹងជាបច្ច័យដល់វីតិក្កមកិលេស គឺកិលេសគ្រោតគ្រាតប្រាកដឡើង តាមផ្លូវកាយ តាមផ្លូវវាចា ជាទុច្ចរិតផ្សេងៗទៅ។ បរិយុដ្ឋានកិលេស និងវីតិក្កមកិលេសទាំង ២ ប្រភេទនេះ មិនហៅថា អនុសយ-ក្កិលេសទេ ប៉ុន្តែបរិយុដ្ឋានកិលេស កើតអំពីអនុស័យកិលេស និងវីតិក្កម-កិលេសកើតអំពីបរិយុដ្ឋានកិលេស ដែលជាបច្ច័យឧបត្ថម្ភដល់គ្នានឹងគ្នាយ៉ាងនេះឯង។ ដោយហេតុនេះ ទើបអនុសយក្កិលេស ជាកិលេសម្យ៉ាងដែលមានសភាពល្អិត ដេកជ្រកសំងំនៅក្នុងខន្ធសន្តាននៃសត្វទាំងឡាយ។

# អនុស័យមានវចនត្ថៈថា

**សន្តានេ អនុសេន្តីតិ = អនុសយា** ប្រែថា ធម៌ទាំងឡាយណា រមែងដេកសំងំនៅជារឿយៗក្នុងសន្តាននៃសត្វ ធម៌ទាំងឡាយនោះ ឈ្មោះថាអនុស័យ។ ធម៌ដែលដេកសំងំនោះ សំដៅយកដែលលះបង់មិនទាន់បាននៅឡើយ។ ម្យ៉ាងទៀតថាៈ **អនុរូបំ ការណំ លភិត្វា សេន្តិ ឧប្បជ្ជន្តីតិៈ អនុសយា** ប្រែថា ធម៌ទាំងឡាយណា កាលបើបានហេតុសមគួរហើយរមែងកើតឡើងបាន ធម៌ទាំងឡាយនោះឈ្មោះថា អនុស័យ។ ឧបមាអនុសយក្កិលេស បរិយុដ្ឋានកិលេស និងវីតិក្កមកិលេសដូចជាឈើគូសក្នុងប្រអប់ យកឈើគូសមួយដើម ទៅគូសត្រង់ផ្នែកចំហៀងនៃប្រអប់ ភ្លើងក៏រមែងប្រាកដឡើង។ ហើយកាលយកភ្លើងនោះទៅអុជនឹងវត្ថុណាៗដូចជា ចង្កៀងជាដើម ភ្លើងក៏ឆេះវត្ថុនោះ គឺចង្កៀងនោះៗ។

អនុសយក្កិលេស ប្រៀបបីដូចជាធាតុប្រេងដែលមាននៅត្រង់ក្បាលឈើគូសនោះ។ អារម្មណ៍ផ្សេងៗដែលមកប៉ះខ្ទប់ ត្រង់ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដូចជាការយកឈើគូសដើមណាមួយ ទៅគូសត្រង់ចំហៀងប្រអប់ដូច្នោះ។ បរិយុដ្ឋានកិលេសដូចជាភ្លើង ដែលប្រាកដឡើងត្រង់ក្បាលឈើគូសនោះ។ កាលនាំទៅអុជនឹងវត្ថុដទៃដូចជាចង្កៀងជាដើម ចង្កៀងក៏ឆេះឡើង ភ្លើងដែលឆេះនឹងចង្កៀងនោះ ប្រៀបបីដូចជាវីតិក្កមកិលេសយ៉ាងនោះឯង។

## ២១.ធម៌ដែលលះកិលេសទាំង ៣ នេះគឺៈ

**១.សីល** ប្រហារ វីតិក្កមកិលេស។

**២.សមាធិ** ប្រហារ បរិយុដ្ឋានកិលេស។

**៣.បញ្ញា** (ក្នុងមគ្គចិត្ត) ប្រហារ អនុសយកិលេស។

## ២២.អនុសយក្កិលេសមាន ៧ យ៉ាងគឺៈ

**១.កាមរាគានុស័យ** កិលេសដែលជាសេចក្ដីត្រេកអរ ជាប់ចិត្តក្នុងកាមគុណារម្មណ៍ ដែលដេកសំងំនៅក្នុងខន្ធសន្តាន។ កាលប៉ះខ្ទប់អារម្មណ៍ក៏ប្រែសភាពទៅ ជាបរិយុដ្ឋានកិលេសហើយក៏មានសភាពជាលោភចេតសិក ដែលប្រកបជាមួយលោភមូលចិត្ត ៨ ដួង ។

**២.ភវរាគានុស័យ** កិលេសដែលជាសេចក្ដីត្រេកអរ ជាប់ចិត្តក្នុងអត្តភាពរបស់ខ្លួន ជាប់ចិត្តក្នុងរូបភព អរូបភព ឬរូបឈាន អរូបឈានដែលដេកសំងំនៅក្នុងខន្ធសន្តាន។ កាលប៉ះខ្ទប់អារម្មណ៍ ក៏ប្រែសភាពទៅជាបរិយុដ្ឋានកិលេស។ បានដល់ លោភចេតសិក ដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង។

**៣.បដិឃានុស័យ** កិលេសដែលជាសេចក្តីមិនត្រេកអរ មិនពេញចិត្ត ក្នុងអារម្មណ៍ដែលដេកក្នុងខន្ធសន្តាន។ កាលប៉ះខ្ទប់អារម្មណ៍ប្រែសភាពទៅ ជាបរិយុដ្ឋានកិលេស បានដល់ទោសចេតសិក ដែលប្រកបក្នុងទោសមូលចិត្ត ២ ដួង។

**៤.មានានុស័យ** កិលេសដែលជាសេចក្តីក្រអឺត លើកកម្ពស់វាយឫក ដែលដេកសំងំក្នុងខន្ធសន្តាន។ កាលប៉ះខ្ទប់អារម្មណ៍ ក៏ប្រែសភាពទៅជាបរិយុដ្ឋានកិលេស បានដល់មានចេតសិក ដែលប្រកបក្នុងទិដ្ឋិវិប្ប-យុត្តចិត្ត ៤ ដួង។

**៥.ទិដ្ឋានុស័យ** កិលេសដែលជាគ្រឿងយល់ឃើញខុស ដែលដេកសំងំនៅក្នុងខន្ធសន្តាន។ កាលប៉ះខ្ទប់អារម្មណ៍ ប្រែសភាពទៅជាបរិយុដ្ឋានកិលេសបានដល់ទិដ្ឋិចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ។

**៦-វិចិកិច្ឆានុស័យ** កិលេសដែលជាសេចក្តីសង្ស័យ ស្ទាក់ស្ទើក្នុងវត្ថុដែលគួរជឿ ដែលដេកត្រាំសំងំក្នុងខន្ធសន្តាន។ កាលប៉ះខ្ទប់នឹងអារម្មណ៍ ក៏ប្រែជាសភាពទៅជាបរិយុដ្ឋានកិលេស បានដល់វិចិកិច្ឆាចេតសិក ដែលប្រកបក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង។

**៧.អវិជ្ជានុស័យ** កិលេសដែលជាសេចក្តីវង្វេង ល្ងង់ខ្លៅ មិនដឹងសភាវធម៌តាមសេចក្តីពិត ដែលដេកសំងំក្នុងខន្ធសន្តាន។

កាលប៉ះខ្ទប់នឹងអារម្មណ៍ ក៏ប្រែសភាពទៅជាបរិយុដ្ឋានកិលេស បានដល់មោហចេតសិក ដែលប្រកបក្នុងអកុសលចិត្ត ១២ ដួង។

អនុស័យ ៧ ប្រការ កាលប្រែសភាពជាបរិយុដ្ឋានកិលេសហើយ មាន ប្រភេទជាអង្គធម៌ ៦ គឺៈ លោភចេតសិក ទោសចេតសិក មានចេតសិក ទិដ្ឋិចេតសិក វិចិកិច្ឆាចេតសិក មោហចេតសិក។

## ២៣.សេចក្តីសង្ស័យមាន ៨ យ៉ាងគឺៈ

**១.ពុទ្ធេ កង្ខតិ** សង្ស័យក្នុងព្រះពុទ្ធ

**២.ធម្មេ កង្ខតិ** សង្ស័យក្នុងព្រះធម៌

**៣.សង្ឃេ កង្ខតិ** សង្ស័យក្នុងព្រះសង្ឃ

**៤.សិក្ខាយ កង្ខតិ** សង្ស័យក្នុងសិក្ខា

**៥.បុព្វន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ ធាតុ អាយតនៈដែលជាអតីត

**៦.អបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ ធាតុ អាយតន ដែលជាអនាគត

**៧.បុព្វន្តាបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ ធាតុ អាយតន ដែលជា អតីត និងអនាគត

**៨.បដិច្ចសមុប្បាទេ កង្ខតិ** សង្ស័យក្នុងបដិច្ចសមុប្បាទធម៌ ។

## ២៤.ធម៌ដែលលះអនុស័យ ៧ ប្រការ

**១.បញ្ញា**ក្នុងសោតាបត្តិមគ្គចិត្តលះទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ

**២.បញ្ញា**ក្នុងអនាគាមិមគ្គចិត្តលះកាមរាគានុស័យនិងបដិឃានុស័យ

**៣.បញ្ញា**ក្នុងអរហត្តមគ្គចិត្ត លះភវរាគានុស័យ មានានុស័យ និង អវិជ្ជានុស័យ ។

## ២៥.តិកមាតិកា

**១.១ កុសលា ធម្មា** ពួកធម៌ជាកុសល (បានដល់កុសលចិត្ត៣៧ និងចេតសិក ៣៨) ។

**១.២ អកុសលា ធម្មា** ពួកធម៌ជាអកុសល (បានដល់អកុសលចិត្ត ១២ និងចេតសិក ២៧ )។

**១.៣ អព្យាកតា ធម្មា** ពួកធម៌ជាអព្យក្រឹត (បានដល់វិបាកចិត្ត ៥២ កិរិយាចិត្ត ២០ ចេតសិក ៣៨ រូប ២៨ និងនិព្វាន)។

**២.១ សុខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយសុខវេទនា (បានដល់សុខសហគតចិត្ត ៦៣ និងចេតសិក ៤៦)។

**២.២ ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយទុក្ខវេទនា (បានដល់ទុក្ខសហគតចិត្ត ៣ និងចេតសិក ២១)។

**២.៣ អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ (បានដល់ឧបេក្ខាសហ-គតចិត្ត ៥៥ និងចេតសិក ៤៦)។

**៣.១ វិបាកា ធម្មា** ពួកធម៌ជាវិបាក (បានដល់វិបាកចិត្ត ៥២ និងចេតសិក ៣៨)។

**៣.២ វិបាកធម្មធម្មា** ពួកធម៌មានវិបាកជាប្រក្រតី (បានដល់កុសលចិត្ត ៣៧ អកុសលចិត្ត ១២ និងចេតសិក ៥២)។

**៣.៣ នេវវិបាកនវិបាកធម្មធម្មា** ពួកធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី (បានដល់កិរិយាចិត្ត ២០ ចេតសិក ៣៥ រូប ២៨ និងនិព្វាន)។

**៤.១ ឧបាទិន្នុបាទានិយា ធម្មា** ពួកធម៌ដែលមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន (បានដល់លោកិយវិបាកចិត្ត ៣២ និងចេតសិក ៣៥ និងកម្មជរូប ២០)។

**៤.២ អនុបាទិន្នុបាទានិយា ធម្មា** ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន (បានដល់លោកិយកុសលចិត្ត ១៧ អកុសលចិត្ត ១២ កិរិយាចិត្ត ២០ ចេតសិក ៥២ និង រូប ៣ សមុដ្ឋាន)។

**៤.៣ អនុបាទិន្នានុបាទានិយា ធម្មា** ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន (បានដល់លោកុត្តរចិត្ត ៤០ ចេតសិក ៣៦និងនិព្វាន)។

**៥.១ សង្កិលិដ្ឋសង្កិលេសិកា ធម្មា** ពួកធម៌ដែលសៅហ្មង ទាំងគួរដើម្បីដល់នូវសេចក្ដីសៅហ្មង (បានដល់អកុសលចិត្ត ១២ និងចេតសិក ២៧)។

**៥.២ អសង្កិលិដ្ឋសង្កិលេសិកា ធម្មា** ពួកធម៌ដែលមិនសៅហ្មង តែគួរដើម្បីដល់នូវសេចក្ដីសៅហ្មង (បានដល់លោកិយកុសលចិត្ត ១៧ លោកិយវិបាកចិត្ត ៣២ កិរិយាចិត្ត ២០ ចេតសិក ៣៨ និងរូប ២៨)។

**៥.៣ អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា** ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដើម្បីដល់នូវសេចក្ដីសៅហ្មង (បានដល់លោកុត្តរចិត្ត ៨ ឬ៤០ ចេតសិក ៣៦ និងនិព្វាន)។

**៦.១ សវិតក្កសវិចារា ធម្មា** ពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ (បានដល់សវិតក្កសវិចារចិត្ត ៥៥ និងចេតសិក ៥០)។

**៦.២ អវិតក្កវិចារមត្តា ធម្មា** ពួកធម៌គ្មានវិតក្កៈ មានត្រឹមតែវិចារៈ (បានដល់ទុតិយជ្ឈានចិត្ត ១១ ចេតសិក ៣៦ និងវិតក្កចេតសិកទាំងអស់ក្នុងចិត្ត ៥៥ ផង។

**៦.៣ អវិតក្កាវិចារា ធម្មា** ពួកធម៌គ្មានវិតក្កៈ ទាំងគ្មានវិចារៈ (បានដល់ទ្វិបញ្ចវិញ្ញាណ ១០ ឈានចិត្ត ៤៥ ចេតសិក ៣៦ វិចារចេតសិកក្នុងទុតិយជ្ឈានចិត្ត១១ រូប ២៨ និងនិព្វាន)។

**៧.១ បីតិសហគតា ធម្មា** ពួកធម៌ប្រកបដោយបីតិ (បានដល់បីតិសហគតចិត្ត ៥១ និងចេតសិក ៤៦)។

**៧.២ សុខសហគតា ធម្មា** ពួកធម៌ប្រកបដោយសុខ (បានដល់សុខសហគតចិត្ត ៦៣ និងចេតសិក ៤៦)។

**៧.៣ ឧបេក្ខាសហគតា ធម្មា** ពួកធម៌ប្រកបដោយឧបេក្ខា (បានដល់ឧបេក្ខាសហគតចិត្ត ៥៥ និងចេតសិក ៤៦)។

**៨.១ ទស្សនេន បហាតព្វា ធម្មា** ពួកធម៌ដែលត្រូវលះដោយទស្សនៈ (បានដល់លោភទិដ្ឋិគតសម្បយុត្តចិត្ត ៤ មោហវិចិកិច្ឆាសម្បយុត្តចិត្ត ១ និងចេតសិក ២២ និងឥស្សា មច្ឆរិយៈ និងអកុសលចិត្តប្បាទ៦ទៀតដែលនាំឲ្យកើតអបាយភូមិ )។

**៨.២ ភាវនាយ បហាតព្វា ធម្មា** ពួកធម៌ដែលត្រូវលះដោយភាវនា គឺមគ្គ៣ខាងលើ (បានដល់អកុសលចិត្ត ៧ និងចេតសិក ២៣)។

**៨.៣ នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា** ពួកធម៌ដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា

(បានដល់ កុសលចិត្ត ២១ វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ចេតសិក ៣៨ រូប ២៨ និងនិព្វាន)។

**៩.១ ទស្សនេន បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុដែលត្រូវលះដោយទស្សនៈ (បានដល់លោភទិដ្ឋិគតសម្បយុត្តចិត្ត ៤ មោហវិចិកិច្ឆាសម្បយុត្តចិត្ត ១ និងចេតសិក ២២ និងឥស្សា មច្ឆរិយៈ ព្រមទាំងអកុសលចិត្តុប្បាទ៦ ដែលនាំទៅកាន់អបាយ )។

**៩.២ ភាវនាយ បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុដែលត្រូវលះដោយភាវនា (បានដល់ អកុសលចិត្ត ៧ និងចេតសិក ២៣)។

**៩.៣ នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា (បានដល់កុសលចិត្ត ២១ វិបាកចិត្ត ៣៦ ឬ៥២ កិរិយាចិត្ត ២០ ចេតសិក ៣៨ មោហចេតសិកក្នុងមោហមូលចិត្ត ២ រូប ២៨ និងនិព្វាន)។

**១០.១ អាចយគាមិនោ ធម្មា** ពួកធម៌ដល់នូវការសន្សំកពូនឡើងដោយកម្មក្កិលេស (បានដល់លោកិយកុសលចិត្ត ១៧ ចេតសិក ៣៨ អកុសលចិត្ត ១២ ចេតសិក ២៧)។

**១០.២ អបចយគាមិនោ ធម្មា** ពួកធម៌មិនដល់នូវការសន្សំកពូនឡើងដោយកម្មក្កិលេស (បានដល់លោកុត្តរកុសលចិត្ត ៤ ឬ២០ ចេតសិក ៣៦)។

**១០.៣ នេវាចយគាមិនោ នាបចយគាមិនោ ធម្មា** ពួកធម៌មិនមែនជាដល់នូវការកពូនសន្សំឡើង មិនមែនជាមិនដល់នូវការ

សន្សំកពូនឡើង (បានដល់វិបាកចិត្ត ៣៦ ឬ៥២ កិរិយាចិត្ត ២០ ចេតសិក ៣៨ រូប ២៨ និងនិព្វាន)។

**១១.១ សេក្ខា ធម្មា** ពួកធម៌ជារបស់សេក្ខបុគ្គល (បានដល់លោកុត្តរចិត្ត ៧[10] ឬ៣៥ និងចេតសិក ៣៦)។

**១១.២ អសេក្ខា ធម្មា** ពួកធម៌ជារបស់អសេក្ខបុគ្គល (បានដល់លោកុត្តរចិត្ត ១[11] ឬ៥ និងចេតសិក ៣៦)។

**១១.៣ នេវ សេក្ខា នាសេក្ខា ធម្មា** ពួកធម៌មិនមែនជាសេក្ខធម៌ និងមិនមែនជាអសេក្ខធម៌ (បានដល់លោកិយចិត្ត ៨១ ចេតសិក ៥២ រូប ២៨ និងនិព្វាន)។

**១២.១ បរិត្តា ធម្មា** ពួកធម៌មានសភាពតូចឆ្មារ (បានដល់កាមាវចរចិត្ត ៥៤ ចេតសិក ៥២ និងរូប ២៨)។

**១២.២ មហគ្គតា ធម្មា** ពួកធម៌ដល់នូវសភាពធំ (បានដល់មហគ្គតចិត្ត[12] ២៧ និងចេតសិក ៣៥)។

**១២.៣ អប្បមាណា ធម្មា** ពួកធម៌ប្រមាណមិនបាន (បានដល់លោកុត្តរចិត្ត ៨ ឬ៤០ និងចេតសិក ៣៦ និងនិព្វាន)។

**១៣.១ បរិត្តារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍តូចឆ្មារ (បានដល់កាមាវចរវិបាកចិត្ត ២៣ កិរិយាមនោធាតុចិត្ត ១ ហសិតុប្បាទចិត្ត ១ និងចេតសិក ៣៣ជាឯកន្តៈ[13] ។

---

[10] រាប់ចាប់តាំងពីសោតាបត្តិមគ្គ ដរាបដល់អរហត្តមគ្គ រួមជា ៧ ។

[11] អរហត្តផល ។

[12] មហគ្គត បានដល់ រូបាវចរភូមិ ១៥ និងអរូបាវចរភូមិ ១២ ។

កាមាវចរចិត្ត ២៩ ទៀត អភិញ្ញា ២ ចេតសិក ៥០ ជាអនេកន្តៈ )។

**១៣.២ មហគ្គតារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ (បានដល់វិញ្ញាណញ្ចាយតនចិត្ត៣ នេវសញ្ញានាសញ្ញាយតនចិត្ត ៣ និងចេតសិក ៣០ ជាឯកន្តៈ ។

កាមាវចរចិត្ត ២៩ ទៀត អភិញ្ញា ២ ចេតសិក ៤៧ ជាអនេកន្តៈ )។

**១៣.៣ អប្បមាណារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន (បានដល់លោកុត្តរចិត្ត ៨ ឬ៤០ ចេតសិក ៣៦ ជាឯកន្តៈ

មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត និងមហាកិរិយា ញាណសម្បយុត្ត សរុប ៨ដួង អភិញ្ញា ២ ចេតសិក ៣៣ ជាអនេកន្តៈ )។

**១៤.១ ហីនា ធម្មា** ពួកធម៌ដ៏ថោកទាប (បានដល់អកុសលចិត្ត ១២ និងចេតសិក ២៧)។

**១៤.២ មជ្ឈិមា ធម្មា** ពួកធម៌យ៉ាងកណ្ដាល (បានដល់លោកិយកុសលចិត្ត ១៧ លោកិយវិបាកចិត្ត ៣២ កិរិយាចិត្ត ២០ ចេតសិក ៣៨ និងរូប ២៨)។

**១៤.៣ បណីតា ធម្មា** ពួកធម៌ដ៏ឧត្តម (បានដល់លោកុត្តរចិត្ត ៨ ឬ ៤០ ចេតសិក ៣៦ និងនិព្វាន)។

---

[13] ឯកន្តៈ ប្រែថា ដោយចំណែកមួយ សេចក្ដីថា ចិត្តនេះមានតែកាមាវចរជាអារម្មណ៍តែម្យ៉ាង មិនមានធម៌ដទៃជាអារម្មណ៍ឡើយ ។ ឯម្យ៉ាងទៀតគឺ អនេកន្តៈ ប្រែថា មិនដោយចំណែក១ សេចក្ដីថា ចិត្តប្រភេទអនេកន្តៈនេះ អាចដឹងអារម្មណ៍ជាកាមាវចរផង ជាបញ្ញត្តិផង ជាភូមិថ្នាក់លើៗផង ជានិព្វានផង តាមសមគួរ, ជាសរុបគឺមិនមែនដឹងតែកាមាវចរតែម្យ៉ាងទេ។ នេះពោលដោយបរិត្តារម្មណធម៌ សូម្បីក្នុងទីដទៃ ក៏គប្បីជ្រាបតាមសមគួរ ។

**១៥.១ មិច្ឆត្តនិយតា ធម្មា** ពួកធម៌មានសភាពខុសនិងទៀង[14] (បានដល់លោភទិដ្ឋិគតសម្បយុត្តចិត្ត ៤ ចេតសិក ២១ ដែលប្រព្រឹត្តនៅក្នុងនិយតមិច្ឆាទិដ្ឋិ ទោសមូលចិត្ត ២ ចេតសិក ២២ ដែលប្រព្រឹត្តនៅក្នុងអនន្តរិយកម្ម ៥)។

**១៥.២ សម្មត្តនិយតា ធម្មា** ពួកធម៌មានសភាពត្រូវនិងទៀង (បានដល់លោកុត្តរកុសលចិត្ត ៤ ឬ ២០ និងចេតសិក ៣៦)។

**១៥.៣ អនិយតា ធម្មា** ពួកធម៌មិនមែនជាធម៌ទៀង (បានដល់អកុសលចិត្តុប្បាទ ១២ ចេតសិក២៧ «វៀរនិយតមិច្ឆាទិដ្ឋិ និងអនន្តរិយកម្ម ៥»

លោកិយកុសលចិត្តុប្បាទ ១៧ ចេតសិក ៣៨

និងអព្យាកតធម៌ទាំងអស់ )។

**១៦.១ មគ្គារម្មណា ធម្មា** ពួកធម៌មានមគ្គជាអារម្មណ៍ (បានដល់ចិត្ត ១១ និងចេតសិក ៣៣ ជាអនេកន្តៈ )។

**១៦.២ មគ្គហេតុកា ធម្មា** ពួកធម៌មានមគ្គជាហេតុ (បានដល់

ន័យទី១ លោកុត្តរកុសលចិត្ត ៤ ចេតសិក ២៨ ឬ ៣៦[15]

ន័យទី២ លោកុត្តរកុសលចិត្ត ៤ ចេតសិក ៣៤ ឬ ៣៦[16]

---

[14] ដែលហៅថា **មានសភាពខុស** ព្រោះជាផ្នែកអកុសលធម៌ ដែលហៅថា **ទៀង** ព្រោះទៀងតែឲ្យបដិសន្ធិក្នុងនរក ក្នុងជាតិបន្ទាប់ ។

[15] ន័យទី១នេះ មគ្គចិត្តុប្បាទ គឺមគ្គចិត្ត និងមគ្គចេតសិក មានអង្គមគ្គ៨ជាហេតុ ។ ដែលរាប់ចេតសិក២៨ ព្រោះចេតសិកសម្បយុត្ត៣៦ ដកអង្គមគ្គ៨ ឯការរាប់ចេតសិក៣៦ ព្រោះអង្គមគ្គនីមួយៗសុទ្ធតែមានអង្គមគ្គដទៃជាហេតុដូចគ្នា ហេតុនេះទើបចេតសិកសល់ទាំង៣៦ ។

ន័យទី៣ លោកុត្តរកុសលចិត្ត ៤ ចេតសិក ៣៥[17])។

**១៦.៣ មគ្គាធិបតិនោ ធម្មា** ពួកធម៌មានមគ្គជាអធិបតី (បានដល់មហាកុសលញាណសម្បយុត្ត ៤ មហាកិរិយាញាណសម្បយុត្ត ៤ ចេតសិក ៣៣ ជាអនេកន្តៈ

លោកុត្តរកុសលចិត្ត ៤ ឬ ២០ និងចេតសិក ៣៥ ជាឯកន្តៈ )។

**១៧.១ ឧប្បន្នា ធម្មា** ពួកធម៌កើតឡើងហើយ (បានដល់ចិត្ត ១២១ ចេតសិក ៥២ និងរូប ២៨ ដែលកំពុងកើតឡើង ជាបច្ចុប្បន្ន )។

**១៧.២ អនុប្បន្នា ធម្មា** ពួកធម៌មិនទាន់កើតឡើង (បានដល់អកុសលចិត្ត ១២ កុសលចិត្ត២១ កិរិយាចិត្ត ២០ ចេតសិក ៥២ ចិត្តជរូប ១៧ ឧតុជរូប ១៥ និងអាហារជរូប ១៤ ជាអនាគត )។

**១៧.៣ ឧប្បាទិនោ ធម្មា** ពួកធម៌ដែលប្រុងនឹងកើតឡើង (បានដល់វិបាកចិត្ត ៣៦[18] ចេតសិក ៣៨ និងកម្មជរូប ២០)។

**១៨.១ អតីតា ធម្មា** ពួកធម៌ជាអតីតៈ (បានដល់ចិត្ត ៨៩ ឬ ១២១ ចេតសិក ៥២ និងរូប ២៨ ដែលជាអតីតៈ)។

---

[16] ន័យទី២នេះ មគ្គចិត្តុប្បាទ មាន អលោភៈ អទោសៈ អមោហៈ ជាហេតុ ដោយអំណាចហេតុប្បច្ច័យ ។ ដែលរាប់ចេតសិក ៣៣ ព្រោះដកចេតសិកដែលជាតួហេតុចេញអស់៣ ដែលរាប់៣៦ដដែល ព្រោះហេតុនីមួយៗ សុទ្ធតែមានគ្នានឹងគ្នាជាហេតុ ។

[17] ន័យទី៣នេះ មគ្គចិត្តុប្បាទ មានបញ្ញាជាហេតុ គឺជាហេតុដោយភាពជាអង្គមគ្គផង ជាហេតុបច្ច័យផង ។ ហេតុនេះទើបចេតសិករាប់៣៥ តែម្យ៉ាង ព្រោះបញ្ញាមិនមានធម៌ដទៃជាហេតុទេ ក្នុងន័យទី៣នេះ ។

[18] វិបាក លោកហៅថា ធម៌ដែលប្រុងនឹងកើតឡើង ព្រោះមានកម្មដែលជាហេតុស្រេចហើយ នៅឡើយតែឱកាសសម្រាប់កើត ឯធម៌ជាអនាគតផ្សេងទៀត លោកហៅថា ធម៌ដែលនឹងកើតឡើង ព្រោះមិនមានកម្មកើតឡើងជាហេតុទេ ។

**១៨.២ អនាគតា ធម្មា** ពួកធម៌ជាអនាគត (បានដល់ចិត្ត ៨៩ ឬ ១២១ ចេតសិក ៥២ និងរូប ២៨ ដែលជាអនាគត)។

**១៨.៣ បច្ចុប្បន្នា ធម្មា** ពួកធម៌ជាបច្ចុប្បន្ន (បានដល់ចិត្ត ៨៩ ចេតសិក ៥២ និងរូប ២៨ ដែលជាបច្ចុប្បន្ន)។

**១៩.១ អតីតារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាអតីតៈ (បានដល់វិញ្ញាណញ្ចាយតចិត្ត ៣ នេវសញ្ញានាសញ្ញាយតនចិត្ត ៣ និង ចេតសិក ៣០ ជាឯកន្តៈ

មនោទ្វារាវជ្ជនចិត្ត១ កាមជវនចិត្ត ២៩ តទាលម្ពណចិត្ត១១ អភិញ្ញា ២ ចេតសិក ៤៧ ជាអនេកន្តៈ)។

**១៩.២ អនាគតារម្មណា ធម្មា**ពួកធម៌មានអារម្មណ៍ជាអនាគត (បានដល់ កាមាវចរចិត្តក្នុងមនោទ្វារ៤១ អភិញ្ញា ២ ចេតសិក៥០ ជាអនេកន្តៈ) ។

**១៩.៣ បច្ចុប្បន្នារម្មណាធម្មា** ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន (បានដល់ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣ និងចេតសិក ១០ ជាឯកន្តៈ កាមាវចរចិត្តក្នុងមនោទ្វារ៤១ អភិញ្ញា ២ ចេតសិក ៥០ ជាអនេកន្តៈ)។

**២០.១ អជ្ឈត្តា ធម្មា** ពួកធម៌ជាខាងក្នុង (បានដល់ចិត្ត ៨៩ ឬ ១២១ ចេតសិក ៥២ និងរូប ២៨ ដែលសន្មតថាជារបស់ខ្លួន )។

**២០.២ ពហិទ្ធា ធម្មា** ពួកធម៌ជាខាងក្រៅ (បានដល់ចិត្ត ៨៩ ឬ ១២១ ចេតសិក ៥២ រូប ២៨ ដែលជារបស់អ្នកដទៃ, រូបជាអនិន្ទ្រិយពទ្ធ និងនិព្វាន)។

**២០.៣ អជ្ឈត្តពហិទ្ធា ធម្មា** ពួកធម៌ជាខាងក្នុងនិងខាងក្រៅ (បានដល់ចិត្ត ៨៩ ឬ ១២១ ចេតសិក ៥២ និងរូប ២៨ ជារបស់ខ្លួនឯង និងជារបស់អ្នកដទៃ )។

**២១.១ អជ្ឈត្តារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ខាងក្នុង (បានដល់វិញ្ញាណញ្ចាយតនចិត្ត ៣ នេវសញ្ញានាសញ្ញាយតនចិត្ត ៣ និងចេតសិក ៣០ ជាឯកន្តៈ

កាមាវចរចិត្ត៥៤ អភិញ្ញា ២ ចេតសិក ៤៩ ជាអនេកន្តៈ)។

**២១.២ ពហិទ្ធារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ខាងក្រៅ (បានដល់រូបាវចរចិត្ត១៥ អាកាសានញ្ចាយតនចិត្ត៣ លោកុត្តរចិត្ត ៨ ឬ ៤០ ចេតសិក៣៨ ជាឯកន្តៈ

កាមាវចរចិត្ត ៥៤ អភិញ្ញា ២ ចេតសិកសម្បយុត្ត៤៩ ជាអនេកន្តៈ និងចេតសិកសម្បយុត្ត៣ គឺឥស្សា និងអប្បមញ្ញា២ ជាឯកន្តៈ )។

**២១.៣ អជ្ឈត្តពហិទ្ធារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ខាងក្នុងក៏បាន និងខាងក្រៅក៏បាន (បានដល់កាមាវចរចិត្ត ៥៤ អភិញ្ញាចិត្ត ២ ចេតសិក ៤៩ ជាឯកន្តៈខ្លះ ជាអនេកន្តៈខ្លះ)។

**២២.១ សនិទស្សនសប្បដិឃា ធម្មា** ពួកធម៌ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ (បានដល់ វណ្ណរូប )។

**២២.២អនិទស្សនសប្បដិឃា ធម្មា** ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ (បានដល់ឱឡារិករូប ១១)។

**២២.៣ អនិទស្សនាប្បដិឃា ធម្មា** ពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ (បានដល់ចិត្ត ៨៩ ឬ ១២១ ចេតសិក ៥២ សុខុមរូប ១៦ និងនិព្វាន)។ (ចប់តិកមាតិកា ២២)

## ២៦.អក្ខណា អសម័យ ៨យ៉ាង

១.កើតក្នុងនរក

២.កើតក្នុងកំណើតតិរច្ឆាន

៣.កើតក្នុងប្រេតវិស័យ

៤.កើតជាព្រហ្មមានអាយុវែង

៥.កើតជាមនុស្សក្នុងបច្ចន្តប្រទេស

៦.កើតជាមនុស្សក្នុងមជ្ឈិមប្រទេស តែជាមនុស្សលីលា

៧.កើតជាមនុស្សក្នុងមជ្ឈិមប្រទេស តែជាមិច្ឆាទិដ្ឋិ

៨.កើតខាងក្រៅពុទ្ធកាល

(បិដកលេខ៤៨ទំព័រ១៣៨)

( **ការសន្សំបុណ្យនាំមកនូវសេចក្តីសុខ** )

## ២៧.មនុស្សឆ្គួត៨ពួក

**១.កាមុម្មត្តកោ** ឆ្គួតព្រោះកាម

**២.កោធុម្មត្តកោ** ឆ្គួតព្រោះសេចក្តីក្រោធ

**៣.ទិដ្ឋុម្មត្តកោ** ឆ្គួតព្រោះសេចក្តីយល់ឃើញខុស

**៤.មោហុម្មត្តកោ** ឆ្គួតព្រោះសេចក្តីវង្វេង

**៥.យក្ខុម្មត្តកោ** ឆ្គួតព្រោះយក្សចូល (ចូលបៀតបៀន)

**៦.បិត្តុម្មត្តកោ** ឆ្គួតព្រោះប្រមាត់កម្រើក

**៧.សុរុម្មត្តកោ** ឆ្គួតព្រោះសុរា

**៨.ព្យសនុម្មត្តកោ** ឆ្គួតព្រោះជួបប្រទះនឹងសេចក្តីវិនាស

## ២៨.លោកធម៌៨យ៉ាង

**១.លាភោ** មានលាភ
**២.អលាភោ** មិនមានលាភ

**៣.យសោ** មានយស
**៤.អយសោ** មិនមានយស

**៥.និន្ទា** ការតិះដៀល
**៦.បសំសា** សេចក្តីសរសើរ

**៧.សុខំ** សេចក្តីសុខ
**៨.ទុក្ខំ** សេចក្តីទុក្ខ

## ២៩.មហានរក ៨ រណ្ដៅ

| | | | |
|---|---|---|---|
| ១.សញ្ជីវៈ | ២.កាលសុត្តៈ | ៣.សង្ឃាដៈ | ៤.រោរុវៈ |
| ៥.មហារោរុវៈ | ៦.តាបន | ៧.មហាតាបន | ៨.អវីចិ[19] |

## ៣០.កិលេសវត្ថុ ៨យ៉ាង

| | | | |
|---|---|---|---|
| ១.លោភៈ | ២.ទោសៈ | ៣.មោហៈ | ៤.មានះ[20] |
| ៥.ទិដ្ឋិ | ៦.វិចិកិច្ឆា | ៧.ថីនៈ | ៨.ឧទ្ធច្ចៈ |

[19] អវីចិ ជាសព្ទបាលីសុទ្ធ ឯខ្មែរយើងហៅត្រឡប់ជា អវិចី ក៏ដូចគ្នានឹងពាក្យថា វីចិ ជាភាសាបាលី ឯខ្មែរប្រើជា វិចី ដូចវិថីចិត្ត ឬដងវិថី ជាដើម ។

[20] ជាធម្មតា ស័ព្ទដែលក្លាយពីបាលីកាលអានសម្លេងអៈ គេប្រើយុគ្គលពិន្ទុ សញ្ញាចុចពីរ (ៈ)ដូចទោសៈ រាគៈ ជាដើម ឯពាក្យថា មានះ គេប្រើស្រះ អះ (ះ) វិញ តែក្នុងករណីប្រើជាបទសមាស គឺបទភ្ជាប់គ្នា គេមិនប្រើសញ្ញាយុគ្គលពិន្ទុ (ៈ) ឬស្រះអះ (ះ) ទេ ដូចពាក្យទោសចេតសិក មោហចេតសិក ឬមានចេតសិក ។

## ៣១.អានិសង្សរបស់អ្នកចម្រើនមេត្តា១១យ៉ាង

១.**សុខំ សុបតិ** ដេកលក់ស្រួល ។

២.**សុខំ បដិពុជ្ឈតិ** ភ្ញាក់ឡើងស្រួល ។

៣.**ន បាបកំ សុបិនំ បស្សតិ** មិនឃើញសុបិនអាក្រក់ ។

៤.**មនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ ។

៥.**អមនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ ។

៦.**ទេវតា រក្ខន្តិ** ទេវតាទាំងឡាយតែងរក្សា ។

៧.**នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** ភ្លើង ឬថ្នាំពិស ឬគ្រឿងសស្ត្រាវមែងមិនធ្លាក់ត្រូវអ្នកចម្រើនមេត្តានោះ។

៨.**តុវដំ ចិត្តំ សមាធិយតិ** ចិត្តអ្នកចម្រើនមេត្តានោះតែងតាំងមាំ ជាសមាធិយ៉ាងរហ័ស។

៩.**មុខវណ្ណោ វិប្បសីទតិ** សម្បុរមុខអ្នកចម្រើនមេត្តានោះស្រស់បស់ ។

១០.**អសម្មុឡ្ហោ កាលំ ករោតិ** វេលាធ្វើមរណកាល តែងមានសតិមិនវង្វេង។

១១.**ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ** កាលបើមិនបានសម្រេច

គុណធម៌ដ៏ខ្ពស់ជាង គឺអរហត្តផលទេ ក៏គង់ទៅកើតក្នុងព្រហ្មលោក មិនខាន។

**(បិដកលេខ៥១ទំព័រទី២៩៧)**

## ៣២.សេចក្តីសុខរបស់អ្នកបួស ឬសមណៈ ៨យ៉ាង

១.មិនមានការហួងហែង រក្សាទុកនូវសម្បត្តិទាំងឡាយ

២.ស្វែងរកតែបិណ្ឌបាតដែលឥតទោស

៣.បរិភោគតែអាហារដែលឆ្អិនស្រាប់

៤.មិនមានសេចក្តីលំបាកដោយការបៀតបៀនអំពីដែន គឺមិនត្រូវបង់ពន្ធដារជាដើម

៥.មិនមានឆន្ទរាគៈចំពោះគ្រឿងឧបករណ៍

៦.មិនមានភ័យព្រោះចោរប្លន់

៧.មិនជាប់ជំពាក់ដោយស្តេច និងអាមាត្យស្តេច

៨.ឥតមានអ្នកណារារាំង ឃាត់ឃាំងក្នុងទិសទាំង៤

(គ្មានសេចក្តីសុខណា ស្មើដោយសេចក្តីស្ងប់ឡើយ)

## ៣៣.ទោសរបស់កាមគុណ១០យ៉ាង

**១.អដ្ឋិកង្ខលូបមា** ឧបមាដូចរាងឆ្អឹង

**២.មំសបេសូបមា** ឧបមាដូចដុំសាច់ដែលខ្លែងឬក្អែកប្រជែងគ្នាស៊ី

**៣.តិណុក្កូបមា** ឧបមាដូចគប់ភ្លើងដែលបុគ្គលកាន់ច្រាសខ្យល់

**៤.អង្គារកាសូបមា** ឧបមាដូចរណ្ដៅពេញដោយរងើកភ្លើង

**៥.សុបិនកូបមា** ឧបមាដូចសុបិននិមិត្ត

**៦.យាចិតកូបមា** ឧបមាដូចរបស់ខ្ចីគេ

**៧.រុក្ខផលូបមា** ឧបមាដូចឈើមានផ្លែ

**៨.សត្តិសូលូបមា** ឧបមាដូចមុខលំពែងដ៏ស្រួច

**៩.អសិសូនូបមា** ឧបមាដូចជ្រញ់សម្រាប់ចិញ្ច្រាំសាច់

**១០.សប្បសិរូបមា** ឧបមាដូចក្បាលនៃពស់

(បិដកលេខ២៤ ទំព័រ២៧៧)

## ៣៤.ហេតុដែលនាំឲ្យកើតបីតិ ១១យ៉ាង

១.រឭកដល់គុណព្រះពុទ្ធ

២.រឭកដល់គុណព្រះធម៌

៣.រឭកដល់គុណព្រះសង្ឃ

៤.រឭកដល់គុណសីលដែលខ្លួនរក្សា

៥.រឭកដល់ទានដែលខ្លួនបរិច្ចាគហើយ

៦.រឭកដល់ធម៌ដែលធ្វើមនុស្សឲ្យទៅជាទេវតា

៧.រឭកដល់ធម៌ស្ងប់

៨.មិនសេពគប់មនុស្សដែលមិនជ្រះថ្លាក្នុងព្រះរតនត្រ័យ

៩.សេពគប់តែនឹងមនុស្សដែលជ្រះថ្លាក្នុងព្រះរតនត្រ័យ

១០.ពិចារណាព្រះសូត្រដែលអាចឲ្យកើតសេចក្តីជ្រះថ្លាបាន

១១.បង្អោនចិត្តឲ្យទន់ទោរទៅក្នុងផ្លូវដែល នឹងឲ្យកើតបីតិសម្ពោជ្ឈង្គ គ្រប់ខណៈចិត្ត។

## ៣៥.អនុត្តរិយ(ធម៌ដែលគ្មានធម៌ដទៃប្រសើរជាង)

១.**ទស្សនានុត្តរិយ**   ការឃើញដ៏ប្រសើរ

២.**សវនានុត្តរិយ**  ការស្តាប់ដ៏ប្រសើរ

៣.**លាភានុត្តរិយ**   ការបានដ៏ប្រសើរគឺការបាននូវអរិយទ្រព្យនាំឲ្យយើងបាននូវលោកុត្តរធម៌

៤.**សិក្ខានុត្តរិយ**  ការសិក្សាដ៏ប្រសើរ គឺការបំពេញក្នុងសិក្ខាទាំង៣

៥.**បារិចរិយានុត្តរិយ**  ការបំរើដ៏ប្រសើរ គឺការបំរើព្រះរតនត្រ័យ

៦.**អនុស្សតានុត្តរិយ**  ការរឭកដ៏ប្រសើរ  គឺរឭកគុណព្រះរតនត្រ័យ

(សង្គីតិសុត្តវណ្ណនា អដ្ឋកថា ១៩)

## ៣៦.ចេតសិក ៥២ដួង

១.<u>អញ្ញសមានាចេតសិក</u>        ១៣

២.<u>អកុសលចេតសិក</u>        ១៤

៣.<u>សោភណចេតសិក</u>        ២៥

## ១.<u>អញ្ញសមានាចេតសិក ១៣</u> គឺ

១.**ផស្សោ** ប៉ះអារម្មណ៍

២.**វេទនា** សោយអារម្មណ៍

៣.**សញ្ញា** សម្គាល់អារម្មណ៍

៤.**ចេតនា** គិតចាត់ចែងសម្បយុត្តធម៌

៥.**ឯកគ្គតា** ផ្គងចិត្តឲ្យមានអារម្មណ៍តែមួយ

៦.**ជីវិតិន្ទ្រិយំ** ញុំាំងសហជាតធម៌ឲ្យរស់នៅ

៧.**មនសិការោ** ធ្វើទុកក្នុងចិត្ត

ចំណាំ ចេតសិកទាំង៧នេះជា**សព្វចិត្តសាធារណចេតសិក**

<u>**នៅសល់ ៦ ទៀត គឺ**</u>

១.**វិតក្កោ** ត្រិះរិះនូវអារម្មណ៍

២.**វិចារោ** ពិចារណានូវអារម្មណ៍

៣.**អធិមោក្ខោ** ចុះស៊ប់ក្នុងអារម្មណ៍

៤.**វីរិយំ** ព្យាយាម

**៥.បីតិ** ឆ្អែតក្នុងកាយ ក្នុងចិត្ត

**៦.ឆន្ទោ** បំណងក្នុងអារម្មណ៍

ចេតសិក៦នេះជា **បកិណ្ណកចេតសិក** រួមជាអញ្ញសមានាចេតសិក១៣។

## ២.<u>អកុសលចេតសិក</u> ១៤គឺ

**១.មោហោ** វង្វេងក្នុងអារម្មណ៍

**២.អហិរិកំ** មិនខ្មាសបាប

**៣.អនោត្តប្បំ** មិនតក់ស្លុតក្នុងបាប

**៤.ឧទ្ធច្ចំ** រវើរវាយក្នុងអារម្មណ៍

ទាំង៤នេះ ហៅថា មោចតុក្កៈ ។

**៥.លោភោ** ជាប់ជំពាក់ក្នុងអារម្មណ៍

**៦.ទិដ្ឋិ** ការយល់ខុស

**៧.មានោ** រឹងត្អឹង

ទាំង៣នេះ ហៅថា លោតិកៈ ។

**៨.ទោសោ** ប្រទូស្តក្នុងអារម្មណ៍

៩.**ឥស្សា** ច្រណែន

១០.**មច្ឆរិយំ** កំណាញ់

១១.**កុក្កុច្ចំ** ក្តៅក្រហាយ ស្តាយក្រោយ

ទាំង៤នេះ ហៅថា ទោចតុក្កៈ ។

១២.**ថីនំ** រួញរាចំពោះកុសល

១៣.**មិទ្ធំ** ងងុយ ងោកងក់

ទាំង២នេះ ហៅថា ថីទុក្កៈ ។

១៤.**វិចិកិច្ឆា** សង្ស័យ ។

***៣.<u>សោភណចេតសិក</u> ២៥ គឺ***

១.**សទ្ធា** ជឿកម្មផល

២.**សតិ** រលឹកដឹងខុសត្រូវ

៣.**ហិរិ** ខ្មាសបាប

៤.**ឱត្តប្ប** តក់ស្លុតក្នុងអំពើបាប

៥.**អលោភោ** មិនជាប់ជំពាក់

៦.**អទោសោ** មិនប្រទូស្ត

៧.**តត្រមជ្ឈត្តតា** សម្លឹងកណ្តាល

៨.**កាយបស្សទ្ធិ** ស្ងប់កាយ

៩.**ចិត្តបស្សទ្ធិ** ស្ងប់ចិត្ត

១០.**កាយលហុតា** ស្រាលកាយ

១១.**ចិត្តលហុតា** ស្រាលចិត្ត

១២.**កាយមុទុតា** ទន់ភ្លន់កាយ

១៣.**ចិត្តមុទុតា** ទន់ភ្លន់ចិត្ត

១៤.**កាយកម្មញ្ញតា** កាយគួរដល់ការងារ

១៥.**ចិត្តកម្មញ្ញតា** ចិត្តគួរដល់ការងារ

១៦.**កាយបាគុញ្ញតា** កាយស្ទាត់ជំនាញ

១៧.**ចិត្តបាគុញ្ញតា** ចិត្តស្ទាត់ជំនាញ

១៨.**កាយុជុកតា** កាយត្រឹមត្រូវ

១៩.**ចិត្តុជុកតា** ភាវៈនៃចិត្តត្រង់

ចំណាំទាំង ១៩ នេះ ឈ្មោះថា**សោភណសាធារណចេតសិក ។**

២០.**សម្មាវាចា** សម្តីប្រពៃ

២១.**សម្មាកម្មន្តោ** ការងារប្រពៃ

២២.**សម្មាអាជីវោ** អាជីវៈប្រពៃ

ទាំង៣នេះ ហៅថា **វិរតិចេតសិក ។**

២៣.**ករុណា** អាណិត

២៤.**មុទិតា** ទន់ភ្លន់

ទាំង២នេះ ហៅថា **អប្បមញ្ញាចេតសិក ។**

២៥.**បញ្ញិន្ទ្រិយំ** ភាវៈជាធំក្នុងការចេះដឹងគឺបញ្ញា។

## ៣៧.ចិត្ត ៤ ប្រការ

**១.កាមាវចរចិត្ត**

**២.រូបាវចរចិត្ត**

**៣.អរូបាវចរចិត្ត**

## ៤.លោកុត្តរចិត្ត

### ៣៨. រតនបុគ្គល ៥ យ៉ាង

(រកបានដោយកម្រក្នុងលោក)

១.ការកើតឡើងនៃព្រះអរហន្តសម្មាសម្ពុទ្ធ

២.បុគ្គលអ្នកសម្ដែងធម៌វិន័យ

៣.បុគ្គលអ្នកចេះធម៌វិន័យ

៤.បុគ្គលអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌

៥.បុគ្គលជាកតញ្ញូកតវេទី ។

### ៣៩.ភាមាវចរស្ឋគ៌ ៦ ជាន់

១.ចាតុម្មហារាជិកា ២.តាវត្តឹស

៣.យាមា ៤.តុសិត

៥.និម្មានរតី ៦.បរនិម្មិតវសវត្តី

## ៤០.ចរិត ប្រែថា ការប្រព្រឹត្តិ ៦យ៉ាង

១.**រាគចរិត** ការប្រព្រឹត្តច្រើនដោយរាគៈ

២.**ទោសចរិត** ការប្រព្រឹត្តច្រើនដោយទោសៈ

៣.**មោហចរិត** ការប្រព្រឹត្តច្រើនដោយមោហៈ

៤.**វិតក្កចរិត** ការប្រព្រឹត្តច្រើនដោយវិតក្កៈ

៥.**សទ្ធាចរិត** ការប្រព្រឹត្តច្រើនដោយសទ្ធា

៦.**ពុទ្ធិចរិត** ការប្រព្រឹត្តច្រើនដោយប្រាជ្ញា

## ៤១.ឧបក្កិលេសរបស់សមណព្រាហ្មណ៍៤យ៉ាង

១.ផឹកសុរាមេរ័យ

២.សេពមេថុនធម្ម

៣.ត្រេកអរនឹងរូបិយ

៤.ជាអ្នកមាននូវមិច្ឆាទិដ្ឋិ

# ៤២.គោតមប្រវត្តិ

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ

និងសូមគោរពគុណ ក្រាព្រះអង្គចុះចាកឋាន ។

មកចាប់ផ្ទៃមាតា ស្រីស្រស់ក្រអូប…

កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។

ក្នុងថ្ងៃព្រហស្បតិ៍អា- សាធមាសាពេញបូរមី

រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។

កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ

នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។

កក្រើកផែនពសុធា មានទេវតារាប់រយពាន់

ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។

ឆ្នាំចពិសាខនា ថ្ងៃសុក្រជាពេញបូរណមី

ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។

កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ

បិតាបានលើកស្នួយ អភិសេកនឹងស្រីង្គារ ។

នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា

ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។

កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី

អាសាធពេញបូណ៌មី ក្សត្រាថ្លៃបានសុខា ។

ស្ដេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លា

គួរឱ្យព្រះរាជា ស្ដេចជំពាក់ចិត្តពេកក្រៃ ។

តែទ្រង់បានកាត់ផ្ដាច់ ទ្រង់សម្រេចព្រះហឫទ័យ

ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។

បើបិតាបានត្រាស់ វិលរហ័សរកបុត្រា

មកប្រោសស្នួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។
កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា ។
កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្រកិរិយា គ្មាននរណាធ្វើដូចអី ។
បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
ជាថ្ងៃព្រះជិនស្រី មានសិរីឈ្នះក្រុងមារ ។
ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្នេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្ដាលដងព្រឹក្សព្រៃ ។
គឺក្នុងឆ្នាំរកា អាសាធមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្ដើមពោលស្ដីធម៌ទេសនា ។

ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្តា មានរហូតដល់សព្វថ្ងៃ ។
នាថ្ងៃមួយនោះណា គួរសោកាណាម្ចាស់ថ្ងៃ
គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ ។
គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ ។
បីខែកន្លងទៅ មិនឈប់នៅយឺតយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។
គឺក្នុងឆ្នាំនោះឯង មានការផ្សេងតែមាសា
គឺខែពិសាខនា ថ្ងៃអង្គារពេញបូណ៌មី ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទិយ៍

នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្តា ។

សូមឱ្យសម្រេចបុណ្យ ដែលជាគុណដ៏ថ្លៃថ្លា

អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។

សូមជួបព្រះសិរីអារ្យ ជាសាស្តាដ៏ពិសិដ្ឋ

សូមចាក់ធ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

(**ក្រាបថ្វាយបង្គំ**)

**បុណ្យទាំងឡាយគួរធ្វើ ទានទាំងឡាយគួរឲ្យ**

**តាមគុណកុំបណ្ដោយ កម្មស្តាយក្រោយកុំធ្វើ**

# ៤៣.ករណីយមេត្តសូត្រ

**ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច** កិច្ចឯណា (ដែលព្រះអរិយ) បានត្រាស់ដឹងនូវកោដ្ឋាសនៃធម៌ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ គឺកុលបុត្រអ្នកឆ្លាសក្នុងប្រយោជន៍គួរធ្វើ

**សក្កោ ឧជូ ច សុហុជូ ច** (កុលបុត្រនោះ) ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និងវាចាផង ត្រង់ល្អដោយចិត្តផង

**សុវចោ ចស្ស មុទុ អនតិមានី** ជាអ្នកប្រដៅងាយផង សុភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង

**សន្តុស្សកោ ច សុភរោ ច** ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង

**អប្បកិច្ចោ ច សល្លហុកវុត្តិ** ជាអ្នកមានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាល (ក្នុងកាយ និងចិត្តផង)

**សន្តិន្ទ្រិយោ ច និបកោ ច** ជាអ្នកមានឥន្ទ្រិយ៍ស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង។

**អប្បគព្ភោ កុលេសុ អននុគិទ្ធោ** ជាអ្នកមិនឆ្គងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង

**ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ** វិញ្ញូជនទាំងឡាយ គួរតិះដៀលនូវជនទាំងឡាយដទៃដោយកម្មឯណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមកសូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្តចំពោះពពួកនៃសត្វថា)

**សុខិនោ វា ខេមិនោ ហោន្តុ សព្វេ សត្តា ភវន្តុ សុខិតត្តា** សត្វទាំងឡាយទាំងពួង សូមឲ្យមានសេចក្ដីសុខ ឲ្យមានសេចក្ដីក្សេម ឲ្យមានខ្លួនដល់នូវសេចក្ដីសុខចុះ

**យេកេចិ បាណភូតត្ថិ តសា វា ថាវរា វា អនវសេសា** សត្វមានជីវិតទាំងឡាយឯណា ឥតមានសេសសល់ ទោះសត្វដែលជាអ្នកមានសេចក្ដីតក់ស្លុត គឺនៅមានតណ្ហាក្ដី ជាអ្នកមាំមួន គឺឥតមានតណ្ហាក្ដី

**ទីឃា វា យេ មហន្តា វា** សត្វទាំងឡាយឯណា មានកាយវែងក្ដី ធំក្ដី

**មជ្ឈិមា រស្សកា អណុកថូលា** មានកាយយ៉ាងកណ្ដាលក្ដី ខ្លីក្ដី មានកាយដ៏ស្ដួម ឬ ធាត់ក្ដី

**ទិដ្ឋា វា យេ ច អទិដ្ឋា** សត្វទាំងឡាយឯណា ដែលយើងឃើញហើយក្ដី មិនឃើញក្ដី

**យេ ច ទូរេ វសន្តិ អវិទូរេ** សត្វទាំងឡាយឯណា នៅក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី

**ភូតា វា សម្ភវេសី វា** ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី

**សព្វេ សត្តា ភវន្តុ សុខិតត្តា** សត្វទាំងឡាយទាំងពួងសូមឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ

**ន បរោ បរំ និកុព្វេថ** សត្វដទៃមិនគួរកំហែងបៀតបៀននូវសត្វដទៃឡើយ

**នាតិមញ្ញេថ កត្ថចិ នំ កិញ្ចិ** មិនគួរមើលងាយគេតិចតួចក្នុងទីឯណាមួយឡើយ

**ព្យារោសនា បដិឃសញ្ញា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ** មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នា និងគ្នា ដោយសេចក្តីក្រេវក្រោធ និងដោយបដិឃសញ្ញា គឺសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ

**មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ** មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយ ដោយអាយុ គឺថាសូម្បីជីវិតក៏ហ៊ានលះបង់ក្នុងការរក្សានូវបុត្របាន យ៉ាងណាមិញ

**ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ** បុគ្គលគួរចំរើននូវមេត្តាចិត្ត មិនមានប្រមាណ ចំពោះទៅរកសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង

**មេត្តញ្ច សព្វលោកស្មឹ មានសម្ពាទយេ អបរិមាណំ ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ** បុគ្គលគួរចំរើននូវមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ គឺក្នុងខាងលើផង ខាងក្រោមផង ខាងទទឹងគឺត្រង់កណ្តាលផង

**តិដ្ឋញ្ចរំ និសិន្នោ វា សយានោ វា យាវតស្សវិគតមិទ្ធោ** (បុគ្គលអ្នកចំរើននូវមេត្តាចិត្តនោះ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាសហើយ គឺថាជាអ្នកមិនដេកលក់ អស់កាលត្រឹមណា

**ឯតំ សតឹ អធិដ្ឋេយ្យ** គួរតម្កល់នូវមេត្តានុស្សតិនុះ(អស់កាលត្រឹមនោះ)

**ព្រហ្មមេតំ វិហារំ ឥធមាហុ** បណ្ឌិតទាំងឡាយពោលនូវកិរិយានុះថាជាព្រហ្មវិហារ ក្នុងសាសនានេះ

**ទិដ្ឋញ្ច អនុបគម្ម សីលវា ទស្សនេន សម្បន្នោ កាមេសុ វិនេយ្យ គេធំ ន ហិ ជាតុ គព្ភសេយ្យំ បុនរេតីតិ** (បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនដល់ស៊ប់នូវទិដ្ឋិ ជាអ្នកមានសីល ប្រកបដោយទស្សនសម្ប័ទគឺសោតាបត្តិមគ្គ បន្ទោបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយហើយ រមែងមិនកាន់គព្ភសេយ្យាស គឺថាមិនកើតក្នុងគភ៌ទៀតឡើយ។

## ៤៤.ឧបមាគុណត្រៃរ័ត្ន (២២) ប្រការ

រីគុណព្រះត្រៃរ័ត្ន　　បរិសុទ្ធប្រសើរក្រៃ
លោកបានឧបមេយ្យ　　មានម្ភៃពីរប្រការ
ទីមួយគឺព្រះពុទ្ធ　　ប្រសើរផុតត្រៃលោកា
ប្រៀបដូចព្រះចន្ទ្រា　　រះនាថ្ងៃពេញបូរមី។
រីឯព្រះធម្មា　　ប្រៀបដូចជាកាំរស្មី
នៃដួងព្រះច័ន្ទថ្លៃ　　ចាំងរស្មីភ្លឺលោកា។
ព្រះសង្ឃដូចលោកហ្នឹង　　បានទីពឹងព្រោះចន្ទ្រា
ចាំងចែងរស្មីថ្លា　　ឲ្យលោកាល្អពេកក្រៃ។
ទីពីរព្រះភគវា　　ប្រៀបដូចជាអាទិត្យថ្ងៃ
រះឡើងនៅពេលថ្ងៃ　　មានរស្មីខ្លាំងមហិមា
ព្រះធម៌នៃព្រះអង្គ　　ផូរផង់ដូចអាភា
ចេញពីអាទិត្យថ្លា　　ដេញអន្ធការឲ្យខ្ចាត់ទៅ។
ព្រះសង្ឃអង្គសាវ័ក　　មានសំវរល្អពេកកូវ

ដូចទីបលោកដែលត្រូវ អាទិត្យក្ដៅឲ្យភ្លឺថ្លា។
ទីបីព្រះមុនី ឥតមានពីរក្នុងលោកា
ព្រះអង្គប្រៀបដូចជា អ្នកអុចភ្លើងឆួលដុតព្រៃ។
រីអង្គព្រះធម្មា ប្រៀបដូចជាភ្លើងក្ដៅក្រៃ
ដុតព្រៃស្មៅចង្រៃ ជាសត្រូវនឹងស្រូវស្រែ។
ព្រះសង្ឃនោះឯងនៃ ឧបមេយ្យដូចដីស្រែ
ដែលម្ចាស់ខិតខំថែ ក្លាយជាស្រែដ៏ឧត្ដម។
ទីបួនព្រះភគវា ប្រៀបដូចជាភ្លើងយ៉ាងធំ
ប្រយោជន៍ដ៏ឧត្ដម តែងកើតមានដល់លោកា។
ព្រះធម៌ព្រះទ្រង់ញាណ ដែលទ្រង់បានប្រោសទេសនា
ដូចដំណក់ទឹកថ្លា ស្រោចដណ្ដប់លើផែនដី។
សាវ័កអ្នកហ្មត់ចត់ ដូចជនបទពណ៌ខៀវខ្ចី
ដែលភ្លៀងទើបធ្លាក់ថ្មី គួរប្រុសស្រីទាក់នេត្រា។
ទីប្រាំព្រះសម្ពុទ្ធ ប្រសើរផុតជននានា

ព្រះអង្គប្រៀបដូចជា សារថីដ៏ចំណាប់។
រីឯព្រះធម៌ថ្លៃ មានឧបមេយ្យដូចជាច្បាប់
ឧបាយជាគ្រឿងចាប់ បង្ហឹកសេះអាជានេយ្យ។
ព្រះសង្ឃដ៏សោភា ប្រៀបដូចជាអាជានេយ្យ
ហ្វឹកហាត់ល្អប្រពៃ អាចលៃប្រើទាន់ចិន្តា។
ប្រាំមួយនោះឯងនៃ ល្អពេកក្រៃព្រះសាស្តា
ព្រះអង្គប្រៀបដូចជា សល្លពេទ្យសម្រាប់ដកសរ។
ព្រះធម៌នៃព្រះអង្គ មានបែបទ្រង់សៃនបវរ
ដូចឧបាយដកសរ គឺទិដ្ឋិសត្វគ្រប់គ្នា។
សង្ឃសាវ័កកល្យាណ លោកប្រៀបបាននឹងអ្នកណា
ដែលសរមុតកាយា ត្រូវគ្រូពេទ្យដកចេញបាន។
ប្រាំពីរព្រះសម្ពុទ្ធ បរិសុទ្ធប្រៀបស្មើបាន
ចក្ខុពេទ្យចំណាន ចេះឧបាយបកនេត្រា។
ព្រះធម៌វិសេសថ្លៃ ឧបមេយ្យឧបាយា

បកភ្នែកជននានា ឲ្យភ្លឺថ្លាផុតជម្ងឺ។
រីឯព្រះសង្ឃា ប្រៀបដូចជាអ្នកភ្នែកឈឺ
ត្រូវពេទ្យបកឲ្យភ្លឺ ចាកងងឹតគឺមោហា។
ប្រាំបីព្រះភគវ័ន្ត អរហន្តជាសាស្ដា
ព្រះអង្គប្រៀបដូចជា ពេទ្យមានប្រាជ្ញាឈ្លាសវៃ។
ព្រះធម៌ដ៏កល្យាណ ប្រៀបស្មើបានឱសថថ្លៃ
ដែលពេទ្យមានស្នាដៃ ឆ្នៃផ្សំត្រូវយ៉ាងចំណាន។
ព្រះសង្ឃរ័ត្នថ្លៃ ឧបមេយ្យអ្នកដែលបាន
សះស្បើយរោគសាមាន្យ គឺកិលេសគ្រប់ប្រការ។
ប្រាំបួនព្រះទ្រង់ញាណ ប្រៀបអ្នកបានស្គាល់មាគ៌ា
បង្ហាញសត្វគ្រប់គ្នា ឲ្យទៅរកទីផុតភ័យ។
រីឯព្រះធម្មា ដែលសាស្ដាទ្រង់លកលៃ
ត្រាស់ទុកដល់សព្វថ្ងៃ ឧបមេយ្យផ្លូវសុខា។
ចំពោះព្រះសង្ឃរ័ត្ន បរិសុទ្ធឥតមាយា

ប្រៀបដូចប្រុសស្រីណា ដើរដល់ទីដ៏ក្សេមក្សាន្ត។
ទី១០ព្រះសាស្តា មានបញ្ញារុងរឿងថ្កាន
ប្រៀបដូចព្រៃហេមពាន្ត ពេញទៅដោយដើមរុក្ខា។
ព្រះធម៌ដូចដើមថ្នាំ ជុះប្រចាំគ្រប់វេលា
គុណភាពល្អអស្ចារ្យ នៅក្នុងទីព្រៃហេមពាន្ត
ព្រះសង្ឃល្អសោភា ប្រៀបដូចជាអ្នកដែលបាន
ឱសថព្រៃហេមពាន្ត ផឹករួចហើយស្បើយរោគា។
១១ព្រះមានជោគ ដូចនាយទូកក្នុងជលសា
តែងមានចិត្តករុណា ដល់សព្វសត្វក្នុងភពត្រៃ។
ព្រះធម៌ពាក្យទូន្មាន ប្រៀបស្មើបានទូកចរណៃ
ចម្លងផុតលោកត្រៃ ឲ្យដល់ត្រើយបានសុខា។
ព្រះសង្ឃដ៏និមល ដូចអ្នកដល់ត្រើយហើយណា
ត្រើយនោះមានឈ្មោះថា ព្រះនិព្វានសែនសុខក្រៃ។
១២ព្រះភគវា ជាសាស្តាបញ្ញាវៃ

ព្រះអង្គឧបមេយ្យ អ្នកឲ្យទ្រព្យគាប់ចិន្តា។
ព្រះធម៌ទាំងប៉ុន្មាន ប្រៀបស្មើបានទ្រព្យនោះណា
ដែលជនផងនានា តែងប្រាថ្នារៀងរាល់ថ្ងៃ។
សង្ឃសាវ័កកល្យាណ ដូចអ្នកបានចាយទ្រព្យថ្លៃ
គុណភាពល្អពេកក្រៃ ចាយរួចបានសុខគួរគាប់។
១៣ព្រះនិរភ័យ ឧបមេយ្យអ្នកមានភ័ព្វ
បង្ហាញរណ្តៅទ្រព្យ ឲ្យដល់អ្នកដែលត្រូវការ។
ព្រះធម៌ពាក្យប្រដៅ ដូចរណ្តៅទ្រព្យនោះណា
ពេញដោយទ្រព្យនានា មានតម្លៃហួសការស្មាន។
ព្រះសង្ឃអ្នកស្តាប់ទ្រង់ ផ្លូវផង់រុងរឿងថ្កាន
ប្រៀបដូចជាអ្នកបាន រណ្តៅទ្រព្យរីករាយក្រៃ។
១៤ព្រះចោមភព ល្អសព្វគ្រប់គ្មានទោសពៃរ៍
ព្រះអង្គប្រសើរក្រៃ ដូចជាវីរបុរស។
ព្រះធម៌ពាក្យបង្រៀន ប្រៀបស្មើបានក្តីផុតគ្រោះ

ក្សេមក្សាន្តឥតមានមោះ　　មានតែសុខគ្រប់ប្រការ។
ព្រះសង្ឃដ៏សមទ្រង់　　វិសុទ្ធិវង្សចិញ្ចែងថ្លា
ដូចអ្នកបានសុខា　　ដោយសារវីរបុរស។
១៥ព្រះសម្ពុទ្ធ　　បរិសុទ្ធសមទាំងអស់
ប្រៀបដូចសប្បុរស　　អ្នកលួងលោមឲ្យបានស្បើយ។
រីព្រះសទ្ធម្មា　　ប្រៀបដូចការលួងនោះហើយ
លួងលោមឲ្យបានល្ហើយ　　ស្បើយក្តីសោករោគចង្រៃ។
ព្រះសង្ឃសាវ័កពុទ្ធ　　ដូចអ្នកផុតរួចចាកភ័យ
ឧបទ្រពកំណាចក្រៃ　　ព្រោះស្នាដៃនៃព្រះអង្គ។
ដប់ប្រាំមួយនោះណា　　ព្រះសាស្តាវិសុទ្ធិវង្ស
ព្រះទ័យស្អាតស្មោះត្រង់　　ប្រៀបប្រដូចនឹងមិត្តល្អ។
រីឯពាក្យទេសនា　　រចនាជាបទធម៌
ដូចពាក្យមិត្តបវរ　　ប្រាប់ប្រយោជន៍ដល់មិត្តភ្វា។
ព្រះសង្ឃឧត្តមពិត　　អ្នកនៃបនិត្យព្រះធម្មា

ប្រៀបដូចនឹងអ្នកណា បានប្រយោជន៍គាប់ហឫទ័យ។
ដប់ប្រាំពីរព្រះនិរទុក្ខ ល្អគ្រប់មុខហួសវិស័យ
ព្រះអង្គឧបមេយ្យ បឹងកើតទ្រព្យច្រើនប្រការ។
ព្រះធម៌ល្អគួរគាប់ ដូចជាទ្រព្យមានខ្លឹមសារ
កើតក្នុងបឹងនោះណា ជនត្រូវការកើបយកបាន។
ព្រះសង្ឃស្វាមីភ័ក្តិ ប្រៀបដូចអ្នកសំណាងមាន
ជួបទ្រព្យបឹងកល្យាណ រមែងបានក្តីរីករាយ។
ដប់ប្រាំបីព្រះសុគត ល្អវិសុទ្ធមិនទន់ជ្រាយ
ប្រៀបធៀបអធិប្បាយ អ្នកភ្ញូតទឹករាជកុមារ។
បណ្តាំនៃព្រះអង្គ សមបែបទ្រង់គ្រប់ប្រការ
ប្រៀបដូចនឹងទឹកថ្លា សម្រាប់ងូតជម្រះកាយ។
ព្រះសង្ឃប្រៀបដូចជា រាជកុមារបានសប្បាយ
ងូតទឹកត្រជាក់សាយ ជ្រះអស់ក្អែលពីកាយា។
ដប់ប្រាំបួនព្រះជិនស្រី មានសិរីឈ្នះក្រុងមារ

ព្រះអង្គប្រៀបដូចជា អ្នកធ្វើគ្រឿងប្រដាប់កាយ។
ព្រះធម៌ពាក្យបណ្តាំ ពីរពាន់ប្រាំរយឆ្នាំប្លាយ
ដូចគ្រឿងប្រដាប់កាយ ពេញនិយមគ្រប់វេលា។
សាវ័កព្រះទ្រង់ញាណ ដែលលោកបានស្តាប់ទេសនា
ដូចអ្នកល្អសោភា ព្រោះអលង្ការធម្មក្ខន្ធ។
ទីម្ភៃនោះឯងណា ឧបមាព្រះភគវ័ន្ត
ដូចគ្នានឹងដើមចន្ទន៍ ប្រកបក្លិនមានតម្លៃ។
រីឯព្រះសទ្ធម្ម ដ៏ឧត្តមសមប្រពៃ
ដូចក្លិនចន្ទន៍ចរណៃ ដែលប្រុសស្រីគួចប្រាថ្នា។
សាវ័កអ្នកស្មោះត្រង់ អ្នកទ្រទ្រង់សីលសិក្ខា
ដូចជានរជនណា ស្រង់ក្លិនចន្ទន៍ឈ្ងុយពេកពិត។
ម្ភៃមួយព្រះបិតា ជាសាស្តាទ្រង់មានឫទ្ធិ
ដូចផ្តល់ទឹកអម្រឹត ដល់កូនស្ងួនទាំងប្រុសស្រី។
រីព្រះសទ្ធម្មណា ដែលសាស្តាពោលស្រដី

ទេសនាយ៉ាងឃ្មាតខ្មី ប្រៀបដូចទឹកអម្រឹតហ្នឹង។
ព្រះសង្ឃប្រៀបដូចជា អ្នកកំព្រាឥតទីពឹង
បានទឹកអម្រឹតហ្នឹង មានពំនឹងរួចមរណា។
ម្តេពីរព្រះគោតម ដូចបទុមក្នុងជលសា
សូរ្យសែងរះកាលណា រីកសាខាស្រស់ឆើតឆាយ។
ព្រះធម៌ប្រៀបដូចជា ទឹកដមផ្កាឈូកទាំងឡាយ
គួរស្រូបឥតជិនណាយ មាននៅក្នុងបទុមផ្កា។
ព្រះសង្ឃអង្គសាវ័ក អ្នកជឿជាក់ត្រៃសិក្ខា
ប្រដូចនឹងភមរា បានក្រេបផ្កាក្នុងវារី។
ឧបមាគុណត្រៃរ័ត្ន មានប្រាកដម្តេពីរ
ដែលខ្ញុំខំសំភី សូត្រវន្ទីយ៍នមស្ការ។
សូមឲ្យសម្រេចបុណ្យ ដែលជាគុណដ៏ថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត។
សូមជួបព្រះសិអារ្យ ជាសាស្តាដ៏ពិសិដ្ឋ

សូមចាក់ផ្លុះធម៌ពិត		សមដូចចិត្តប្រាថ្នាហោង។

## ៤៥.គុណនាមរបស់ព្រះនិព្វាន

**១–អសេសវិរាគនិរោធោ** ជាធម៌ដែលរំលត់ទុក្ខដោយប្រាសចាករាគៈ មិនមានសេសសល់ ។

**២–អសេសភវនិរោធោ** ជាធម៌ដែលរំលត់ភព មិនមានសេសសល់ ។

**៣–ចាគោ** ជាធម៌ដែលលះលាស់ពីតណ្ហាទាំងពួង។

**៤–បដិនិស្សគ្គោ** ជាធម៌ដែលរួចផុតចាកភព។

**៥–មុត្តិ** ជាធម៌ដែលរួចផុតចាកកិលេស ។

**៦–អនាលយោ** ជាធម៌ដែលមិនមានសេចក្តី អាល័យ ។

**៧–រាគក្ខយោ** ជាធម៌ដែលអស់ទៅ រាគៈ ។

**៨–ទោសក្ខយោ** ជាធម៌ដែលអស់ទៅ ទោសៈ ។

**៩–មោហក្ខយោ** ជាធម៌ដែលអស់ទៅ មោហៈ ។

**១០–តណ្ហក្ខយោ** ជាធម៌ដែលអស់ទៅ តណ្ហា ។

**១១–អនុប្បាទ** ជាធម៌ដែលរំលត់ខន្ធទាំង៥ ។

**១២–អបវត្តំ** ជាធម៌ដែលរំលត់នាមរូប ។

**១៣–អនិមិត្តំ** ជាធម៌ដែលប្រាសចាកសង្ខារ-និមិត្ត ។

១៤–អប្បណិហិតំ ជាធម៌ដែលប្រាសចាកសេចក្ដីត្រូវការ ។

១៥–សុញ្ញតំ ជាធម៌ដែលសូន្យចាកទុក្ខបានពិតមែន ។

១៦–អប្បដិសន្ធិ ជាធម៌ដែលមិនមានការកើត បន្ត ។

១៧–អនុប្បត្តិ ជាធម៌ដែលមិនមានទីទៅ ។

១៨–អនាយូហនំ ជាធម៌ដែលមិនមានការព្យាយាម ។

១៩–អជាតំ ជាធម៌ដែលមិនមានការកើត ។

២០–អជរំ ជាធម៌ដែលមិនមានការចាស់ ។

២១–អព្យាធិ ជាធម៌ដែលមិនមានការឈឺចាប់ ។

២២–អគតិ ជាធម៌ដែលមិនមានគតិ ។

២៣–អមតំ ជាធម៌ដែលមិនមានការស្លាប់ ។

២៤–អសោកំ ជាធម៌ដែលមិនមានសេចក្ដី សោក។

២៥–អបរិទេវំ ជាធម៌ដែលមិនមានសេចក្ដីខ្សឹកខ្សួល ។

២៦–អនុបាយាសោ ជាធម៌ដែលមិនមានសេចក្ដីចង្អៀតចង្អល់ចិត្ត ។

២៧–អសង្កិលិដ្ឋំ ជាធម៌ដែលមិនមានសេចក្ដីសៅហ្មង ។

២៨–អសង្ខតំ ជាធម៌ដែលមិនមានបច្ច័យតាក់តែង ។

២៩–និព្វានំ ជាធម៌ដែលផុតចាកគ្រឿងដោត ក្រង ។

៣០–សន្តិ ជាធម៌ដែលស្ងប់ចាកទុក្ខទាំងពួង ។

គុណនាមរបស់ព្រះនិព្វានដោយសង្ខេបទាំងនេះ អាស្រ័យគុណធម៌របស់លោកអ្នក ដែលបានសំរេចដល់ព្រះនិព្វានហើយទើបថាព្រះនិព្វានមានពិតមែន ។

ព្រះនិព្វាន សង្គ្រោះក្នុងនាមធម៌ ប៉ុន្តែមិនមែនជានាមក្ខន្ធ ព្រោះព្រះនិព្វានផុតចាកការរាប់ថា ជាខន្ធ ព្រោះជា **អសង្ខតធម៌** ។ ប៉ុន្តែព្រះនិព្វានជាអាយតនៈ គឺ**ធម្មាយតនៈ** ព្រោះហេតុថា ជាអារម្មណ៍របស់មគ្គចិត្ត និងផលចិត្ត។ មគ្គចិត្ត និងផលចិត្តនោះជា**មនាយតនៈ**។

ព្រះនិព្វានជា **ធម្មធាតុ** ព្រោះហេតុថា ជាអារម្មណ៍របស់មនោវិញ្ញាណធាតុ ។ មគ្គចិត្ត និងផលចិត្តជា **មនោវិញ្ញាណធាតុ** ។

ព្រះនិព្វានជាអរិយសច្ច គឺ **និរោធសច្ច** ព្រោះហេតុថា ព្រះនិព្វានជាធម៌ ដែលរំលត់នូវទុក្ខសច្ច និងសមុទយសច្ច ។

ព្រះនិព្វានជាធម្មារម្មណ៍ គឺជាអារម្មណ៍របស់មគ្គចិត្ត និងផលចិត្ត ដូច្នោះព្រះនិព្វានទើបជាបរមត្ថធម៌ ដែលមានពិតមែន ។

## សេចក្តីប្រាថ្នាព្រះនិព្វាន ចាត់ជាវិភវតណ្ហា

អ្នកដែលមិនយល់ក្នុងសភាវៈរបស់ព្រះនិព្វាន បានល្អិតល្អន់ល្អទេ កាលបានឮថា ព្រះនិព្វាននោះ មិនមានសេចក្តីទុក្ខតាមផ្លូវកាយ និងទុក្ខតាមផ្លូវចិត្ត ពីប្រការណាៗ មានតែសេចក្តីសុខសុទ្ធសាធ ព្រោះជាធម៌រួចផុតចាកលោក យ៉ាងដូច្នោះហើយក៏កើតចំណង់ចង់បានព្រះនិព្វាន ព្រោះត្រូវការសុខកាយ សប្បាយចិត្ត ដែលមិនជំពាក់ជំពិននឹងលោក និងមិនត្រូវការ ការកើត ចាស់ឈឺ ស្លាប់ផង។ ប៉ុន្តែគិតមិនដល់ថា តើសភាពការមិនកើតរបស់ព្រះនិព្វាននោះ គឺអ្វី? ជាធម្មតាសេចក្តីសុខកាយ សប្បាយចិត្តនឹងកើតឡើង ដោយមិនទាក់ទិននឹងការកើតជាមនុស្ស ជាទេវតាជាព្រហ្ម ដែលនៅក្នុងលោកនោះ មិនមានឡើយ ។

ដូច្នោះសេចក្តីប្រាថ្នាព្រះនិព្វាន របស់បុគ្គលពួកនេះចាត់ជា**វិភវតណ្ហា** ។

## ៤៦.អន្តធម៌របស់រូប ២៨ គឺ៖

**១–បឋវីធាតុ** បានដល់រូបរឹង ឬទន់ ។

**២–អបោធាតុ** បានដល់រូបជ្រាបហូរ ឬកកខន់ ។

**៣–តេជោធាតុ** បានដល់រូបក្តៅ ឬត្រជាក់ ។

**៤–វាយោធាតុ** បានដល់រូបកំរើក តឹង ញ័រ ។

**៥–ចក្ខុបសាទរូប** បានដល់ភាពថ្លានៃភូតដែលអាចទទួលរូបារម្មណ៍បាន ។

**៦–សោតបសាទរូប** បានដល់ភាពថ្លានៃភូតដែលអាចទទួលសទ្ទារម្មណ៍បាន ។

**៧–ឃានបសាទរូប** បានដល់ភាពថ្លានៃភូតដែលអាចទទួលគន្ធារម្មណ៍បាន ។

**៨–ជិវ្ហាបសាទរូប** បានដល់ភាពថ្លានៃភូតដែលអាចទទួលរសារម្មណ៍បាន ។

**៩–កាយបសាទរូប** បានដល់ភាពថ្លានៃកូតដែលអាចទទួលផោដ្ឋព្វារម្មណ៍បាន។

**១០–រូបារម្មណ៍** បានដល់ ពណ៌ ។

**១១–សទ្ទារម្មណ៍** បានដល់ សំឡេង ។

**១២–គន្ធារម្មណ៍** បានដល់ ក្លិន ។

**១៣–រសារម្មណ៍** បានដល់ រស ។

**១៤–ផោដ្ឋព្វារម្មណ៍** បានដល់រឹង ទន់ ក្តៅ ត្រជាក់ តឹង ញ័រ ។

**១៥–ឥត្ថីភាវរូប** បានដល់រូបដែលជាហេតុនៃភាពជាស្រី ។

**១៦–បុរិសភាវរូប** បានដល់រូបដែលជាហេតុនៃភាពជាប្រុស

**១៧–ហទយវត្ថុរូប** បានដល់រូបដែលកើតតាំងនៅក្នុងបេះដូង និងជាទីអាស្រ័យកើតរបស់ចិត្ត និងចេតសិក ។

**១៨–ជីវិតរូប** បានដល់ រូបដែលរក្សាកម្មជរូប ។

**១៩–អាហាររូប** បានដល់រូបដែលនាំឲ្យអាហារជរូបកើត ។

**២០–បរិច្ឆេទរូប** *បានដល់ អាកាសធាតុដែលឃាំង រាំង រវាងរូបកលាបៈ និងរូបកលាបៈ ។*

**២១–កាយវិញ្ញត្តិរូប** *បានដល់ ចលនាផ្សេងៗនៃរាងកាយ*

**២២–វចីវិញ្ញត្តិរូប** *បានដល់ ចលនាផ្សេងៗនៃវាចា ។*

**២៣–រូបលហុតា** *បានដល់ សភាពស្រាលនៃនិប្ផន្នរូប*

**២៤–រូបមុទុតា** *បានដល់ សភាពទន់នៃនិប្ផន្នរូប ។*

**២៥–រូបកម្មញ្ញតា** *បានដល់សភាពគួរដល់ការងាររបស់ និប្ផន្នរូប ។*

**២៦–ឧបចយរូប** *បានដល់ការកើតឡើងគ្រាដំបូងនិងគ្រាក្រោយៗ នៃនិប្ផន្នរូប ។*

**២៧–សន្តតិរូប** *បានដល់ការកើតបន្តគ្នារបស់និប្ផន្នរូប រហូតដល់អស់អាយុ ។*

**២៨–ជរតារូប** *បានដល់ ភាពចាស់ជរា របស់និប្ផន្នរូប ។*

២៩–អនិច្ចតារូប   បានដល់   ការរលត់របស់និប្ផន្នរូប ។

## ៤៧.ទីកើតនៃរូប២១ ក្នុងរាងកាយសត្វ

ក្នុងរាងកាយរបស់សត្វទាំងឡាយ អាចពិចារណារកទីកន្លែងកើតរបស់រូបនីមួយៗ ក្នុងរូបទាំង២៨បានដូចតទៅនេះ ៖

១–មហាភូតរូប៤ កើតនៅក្នុងសព៌ាង្គកាយ ។
២–ចក្ខុបសាទ កើតនៅក្នុងគ្រាប់ភ្នែក ។
៣–សោតបសាទ កើតនៅក្នុងរន្ធត្រចៀក ។
៤–ឃានបសាទ កើតនៅក្នុងរន្ធច្រមុះ ។
៥–ជីវ្ហាបសាទ កើតនៅក្នុងអណ្ដាត ។
៦–កាយបសាទ កើតនៅក្នុងសព៌ាង្គកាយ ។
៧–រូបារម្មណ៍ កើតនៅក្នុងសព៌ាង្គកាយ
៨–សទ្ទារម្មណ៍ កើតបានក្នុងសព៌ាង្គកាយ
៩–គន្ធារម្មណ៍ កើតនៅក្នុងសព៌ាង្គកាយ ។
១០–រសារម្មណ៍ កើតនៅក្នុងសព៌ាង្គកាយ ។
១១–ផោដ្ឋព្វារម្មណ៍ កើតនៅក្នុងសព៌ាង្គកាយ ។
១២–ឥត្ថីភាវ កើតនៅក្នុងសព៌ាង្គកាយស្រ្តី ។
១៣–បុរិសភាវ កើតនៅក្នុងសព៌ាង្គកាយបុរស ។

**១៤–ហទយវត្ថុ** កើតនៅត្រង់បេះដូង ។
**១៥–ជីវិតិន្ទ្រិយ** កើតនៅក្នុងសព៌ាង្គកាយ ។
**១៦–អាហាររូប** កើតនៅក្នុងសព៌ាង្គកាយ ។
**១៧–អាកាសរូប** កើតនៅក្នុងសព៌ាង្គកាយ ។
**១៨–កាយវិញ្ញត្តិ** កើតនៅក្នុងសព៌ាង្គកាយ ។
**១៩–វចីវិញ្ញត្តិ** កើតបានត្រង់មាត់ ។
**២០–វិការរូប៣** កើតនៅក្នុងសព៌ាង្គកាយ ។
**២១–លក្ខណរូប៤** កើតនៅក្នុងសព៌ាង្គកាយ ។

## ៤៨.រូបសម្មុទ្ទេសន័យ

**រូបមាន ២៨** គឺ **និប្ផន្នរូប ១៨** និង **អនិប្ផន្នរូប ១០** ។

**និប្ផន្នរូប១៨** គឺ មហាភូតរូប ៤, បសាទរូប ៥, វិសយរូប ៤, ភាវរូប ២, ហទយរូប ១, ជីវិតរូប ១ និង អាហាររូប ១ ។

**អនិប្ផន្នរូប ១០** គឺ បរិច្ឆេទរូប ១, វិញ្ញត្តិរូប ២, វិការរូប ៣ និងលក្ខណរូប ៤ ។

រូបទាំង២៨នេះ កាលបើបែងចេញជាប្រភេទធំៗ មាន២ប្រភេទ គឺ **មហាភូតរូប ៤** និង **ឧបាទាយរូប ២៤** ។

**មហាភូតរូប** គឺរូបដែលជាធំ ហើយនិងប្រាកដជាក់ច្បាស់ ដោយលក្ខណៈរបស់ខ្លួន និងដោយសណ្ឋានរបស់ខ្លួន ក្នុងសន្តាន នៃរបស់មានជីវិត និងមិនមាន ជីវិត ។

**ឧបាទាយរូប** គឺរូបដែលកើតឡើងដោយអាស្រ័យមហាភូតរូប

ប៉ុន្តែបើចែករូបទាំង២៨នេះ ចេញជាប្រភេទតូចៗ មានរូប ១១ប្រភេទ គឺ ៖

**១–មហាភូតរូប៤** បានដល់ បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ ។

**២–បសាទរូប៥** បានដល់ ចក្ខុបសាទរូប, សោតបសាទរូប, ឃានបសាទរូប, ជីវ្ហាបសាទរូប កាយបសាទរូប ។

**៣–វិសយរូប ៤** បានដល់ រូបារម្មណ៍,សទ្ទារម្មណ៍, គន្ធារម្មណ៍, រសារម្មណ៍ ។

**៤–ភាវរូប២** បានដល់ ឥត្ថីភាវរូប បុរិសភាវរូប។

**៥–ហទយរូប ១** បានដល់ ហទយវត្ថុរូប ។

**៦–ជីវិតរូប ១** បានដល់ ជីវិតិន្ទ្រិយរូប ។

**៧–អាហាររូប ១** បានដល់ កវឡិង្ការាហារ ។

**៨–បរិច្ឆេទរូប ១** បានដល់ អាកាសធាតុ ។

**៩–វិញ្ញត្តិរូប ២** បានដល់ កាយវិញ្ញត្តិរូប, វចីវិញ្ញត្តិរូប ។

**១០–វិការរូប ៣** *បានដល់ **រូបលហុតា, រូបមុទុតា, រូបកម្មញ្ញតា** ។*

**១១–លក្ខណរូប ៤** *បានដល់* **ឧបចយរូប សន្តតិរូប ជរតារូប អនិច្ចតារូប ។**

*ក្នុងបណ្តារូបទាំង២៨នេះ ក្នុងបាឡីចែកចេញជា២ពួកគឺ **សភាវរូប** និង **អសភាវរូប** ។*

**សភាវរូប** *បានដល់* **មហាភូតរូប ៤, បសាទរូប ៥, វិសយរូប ៤, *ភាវរូប ២, ហទយរូប ១, ជីវិតរូប ១ អាហាររូប ១* ។**

*រូប១៨ នេះមានឈ្មោះហៅបាន ៥ យ៉ាង គឺ ៖*

**១–សភាវរូប** *គឺជារូបដែលមានភាវៈរបស់ខ្លួនចំពោះខ្លួនផ្ទាល់ មិនប្រទ្បំគ្នា ។*

**២–សលក្ខណរូប** *គឺជារូបដែលមានលក្ខណៈ គឺ អនិច្ចំ ទុក្ខំ អនត្តា*[21] *។*

**៣–និប្ផន្នរូប** *គឺជារូបដែលកើតឡើងសំរេចហើយ ចាកពីសមុដ្ឋាន គឺ**កម្ម ចិត្ត ឧតុ អាហារ** ។*

---

[21] ពាក្យថា សលក្ខណៈនេះ ចង់បង្ហាញថា ជារូបមានលក្ខណៈផ្ទាល់ៗខ្លួន សេចក្តីថា មានវិសេសលក្ខណៈ គឺគ្រឿងសំគាល់ផ្សេងៗគ្នានីមួយៗ ។

**៤–រូបរូប** *គឺជារូបដែលមានការប្រែប្រួល វិនាស បែកធ្លាយជាធម្មតា ព្រោះបច្ច័យ ។*

**៥–សម្មសនរូប** *គឺជារូបដែលគួរដល់ការពិចារណា ដោយសភាពជា អនិច្ចំ ទុក្ខំ អនត្តា ។*

*ចំណែក* **អសភាវរូប ១០** *ទៀត បានដល់* ***បរិច្ឆេទរូប១, វិញ្ញត្តិរូប២, វិការរូប៣, លក្ខណរូប៤*** ; *ទាំងអស់នេះ ក៏មានឈ្មោះហៅបាន ៥យ៉ាងដូចគ្នា គឺ* ***អសភាវរូប១, អសលក្ខណរូប១, អនិប្ផន្នរូប១, អរូបរូប១*** *និង* ***អសម្មសនរូប១*** *។*

**ចប់ដោយបរិបូណ៌**

**សូមតាមដានភាគខាងក្រោយៗទៀត**

**សូមអរគុណនិងអរព្រះគុណ។**

## ២៧.ឯកសារពិគ្រោះ

១.វចនានុក្រមខ្មែរសម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ **ជួន ណាត**
២.សៀវភៅលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស**
៣.បាវចនាសង្ខេបនៃព្រះពុទ្ធសាសនា ធម្មានន្ទ **ទ៉ាន់ ចាន់សារ៉ែន**
៤.អដ្ឋកថាគាថាធម្មបទ
៥.អភិធម្មត្ថសង្គហៈ(៩បរិច្ឆេទ)
៦.បិដកលេខ (អង្គុ.នវ.សត្តាវាសវគ្គ.៤៩.)
៧.មាននៅក្នុង (អដ្ឋកថាទុតិយវគ្គ ឯកនិបាតអង្គុត្តរនិកាយ)

# រាយនាមពុទ្ធបរិស័ទមានសទ្ធា

## ( ស្រុកមង្គលបូរី )

១. លោក ស្រី ចាន់រី អ្នកស្រី វ៉ែនសុភាវត្តី ព្រមទាំងបុត្រ

២. ឯកឧត្តមចាន់ រដ្ឋាលោកជំទាវ ស្រីទេពសារ៉ាតព្រមទាំងបុត្រ៥0$

៣ .ចំណូលបុណ្យទក្ខិណានុប្បទានជូនលោកតាគីយកអៀង ៣៨.0000 រ

៤. លោក គី យក់ អៀង ១0ក

៥ .លោកយាយ យូយ នៀម ១0ក

៦. លោកតា នេត ឈន ១0ក

៧. លោកយាយ យិន យន់ ១0ក

៨. លោកយាយ មាស គិមយី និង បុត្រ ១0ក

៩. ស្រីពេជ្រ និង ស្រីកែវ ១0ក

១0. លោកគ្រូចិត្ត និង នាងនី និង បុត្រ ៥ក

១១. លោកឱកាណល់ និង អ្នកស្រីកែវគឹមថៃ ៤0000រ

១២ . ឧ. ស. ធួន ប៊ុនធឿន និង ភរិយា និង បុត្រ ១0ក

១៣ .ឧ.ស. ធួន សាអួន ឧ.សិ. ស៊ីម និង បុត្រ ១0ក

១៤. លោក ចេង វ៉ា មុនី និងអ្នកស្រី វ៉ែនសុមិនានិងបុត្រ១០០០០០៖

១៥. លោក ឈឹម សុធា និង វ៉ែន ចាន់នី ៥០០០០៖

១៥. លោក ឡុង ចាន់ថា ភរិយា និង បុត្រ ១០ក

១៦ .ឧ.សិ. ស៊ីវ អម្មារ៉ា និង ស្វាមី និង បុត្រ ១០ក

១៧. លោកហាក់ ងួន អ្នកស្រី ធំ និង បុត្រ២០ក

១៨. ឧ.ស. លី តុងយឿង .៥០០០០៖

១៩. លោក ខ្លឹម នាង នួន និងអ្នកស្រី សំសារ៉ាន់១០ក

២០.លោកយាយ ហួង និង បុត្រ ១០ក

២១. លោក តូវ ស៊ីវគង់ និង តែបាក់គី និង បុត្រ ១០ក

២២. លោក ឡយ ជីវ៉ន និង អ្នកស្រី យ៉ាវារី និង បុត្រ ១០ក

២៣ .លោក សេងលាងខេង និងអ្នកស្រីទូច ពៅ និងបុត្រ ៥ក

២៤ .លោក ចៅ ឫទ្ធី ហាង និង ភរិយា ព្រមទាំងបុត្រ ៥ក

២៥. លោក ខៀវ គឹមហួត និង អ្នកស្រី ស៊ូលក្ខិណា និង បុត្រ

២៦ .ឧ.ស. លឹម ឆាយ និង អ្នកស្រី មីសុខហ៊ាង ៥ក

២៧. លោក សួរ ស្រី ម៉ៅ និង ស្វាមី ព្រមទាំងបុត្រ ៥ក

២៨ .លោក ឡៅ ប៉ាក់ ស៊ឹង និង ភរិយា ព្រមទាំងបុត្រ ៥ក

២៩ .ឧ.សិ. ចាន់ ប៊ុនលី និង បុត្រ ២០០០០៛

៣០. ក្អួយ ម៉ាច និង ស្វាមី និង បុត្រ ៣ក

៣១. លោក ថា ប៊ុន ធឿន និង ភរិយា និង បុត្រ  ៣ក

៣២. លោក ស៊ាន បូរេត និង ហាក់ពៅ និង បុត្រ ៣ក

៣៣. លោក ប្លុង សាខន ភរិយា និង បុត្រ  ៣ក

៣៤ .ឧ.ស. សឿម និង ឧ.សិ. ចន្ថា ៣ក

៣៥ .ឧ.ស. គាំ និង ឧ.សិ. សារ៉ូ ៣ក

៣៦ .លោក គី វ៉ាន់ ង៉ោ ភរិយា និង បុត្រ ៣ក

៣៧. ឧ.សិ.  ភួង គឹមហេង និង បុត្រ ៣ក

៣៨. ឧ.សិ. គង់ ស៊ី នួន ព្រមទាំងបុត្រ ៣ក

៣៩. ឧ.សិ. គួច វ៉ារុណ និង បុត្រ ៣ក

៤០. លោក ទុន សុផាន់ណា និង ភរិយា និង បុត្រ ៣ក

៤១. លោក ថោង ភិរម្យ និង អ្នកស្រី ឡៅ ធិ និង បុត្រ ៣ក

៤២ .ឧ.ស. តែ មាស និង លោកយាយ ខេង វ៉ុង និង បុត្រ ៣ក

៤៣ .ស្រី រ័ត្ន ២ក

៤៤ .លោក ឌី យន និង ភរិយា គឹម ហ៊ាង និង បុត្រ ៣ក

៤៥. លោក វង វ៉ា និង ភរិយា សុខា និង បុត្រ ៣ក

៤៦. លោក ស៊ឹម ចាន់ទ្រី និង ភរិយា យក់ សាវ៉េត ៣ក

៤៧. លោក សុទ្ធ សំអោក (ភ.ភ.) ៣ក

៤៨. ឧ. ស.យក់ ឈុនលីនិងលោកយាយ តាន់ ប៊ុនលី និងបុត្រ ៣ក

៤៩ .ឧ.សិ. ចៅ ហាក់ មន្ថា និង បុត្រ និង ចៅ . ១០០០០៛

៥០. ឧ.ស. ចាន់ថា និង ឧ.សិ. ចាន់នី និង បុត្រ .១០០០០៛

៥១. លោកស៊ុន វ៉ាន់ បុត្រ និង ចៅ ១០៥០០៛

៥២. នាង ចេក ព្រមទាំងបុត្រ ១០៥០០៛

៥៣ .លោក ស៊ុម ហឿន ភរិយា និង បុត្រ ១០៥០០៛

៥៤. លោក កួយ ស៊ី ចាន់ ភរិយា អួន និង បុត្រ ១០៥០០៛

៥៥ .លោក ថុន វិបុល និង ភរិយា និង បុត្រ ១០៥០០៛

៥៦. ឧ.សិ. ប៉ូ ង៉ បុត្រ ព្រមទាំងចៅ ១០០០០៛

៥៧. ឧ.ស. សាន ឡុត និង ឧ.សិ. គល់ គឹមហាន ១០០០០៛

៥៨ .លោក ហេង គឹមហួន ភរិយា និង បុត្រ ៧០០០រ

៥៩ .ឧ.សិ. អ៊ិន ដាន់ បុត្រ ៧០០០រ

៦០. កញ្ញា ញ៉ែម ចាន់លក្ខិណា ៧០០០រ

៦១. លោក ម៉ក់ ដារ៉ុន ភរិយា និង បុត្រ ៧០០០រ

៦២ .លោក សុក ប៊ុនថុន ភរិយា និង បុត្រ ៧០០០រ

៦៣ .ឧ.សិ. ឡាស៊ី ផិន និង បុត្រ ៧០០០រ

៦៤. ឧ.សិ. កែវ រុំ និង បុត្រ និង ចៅ ៧០០០រ

៦៥. កញ្ញា ចាន់ ឡឹង ៧០០០រ

៦៦. លោកស្រីស៊ឹម សុវណ្ណ ស្វាមី និង បុត្រ ៧០០០រ

៦៧ .ឧ.ស. ប៊ុន សុវណ្ណ ឧសិ ឆូត ៧០០០រ

៦៨. ឧ.សិ. គឹម យ៉ុម និង បុត្រ ១០០០០រ

៦៩. លោក លួន ធូ និង បង ស និង បុត្រ ៧០០០រ

៧០ .អុ អែក ព្រមទាំង បុត្រ ៧០០០រ

៨០ .សេង សារើយ ៧០០០រ

៨១. ឧ.សិ. ទុន សៀប និង ឃួន ហំ ៧០០០រ

៨២ .ឧ.សិ. និម សារ៉ាន់ និង បុត្រ ៧០០០៛

៨៣ .ឧ.ស. យី សារុន ឧ.សិ. ដុក ឈឿត ៧០០០៛

៨៤. លោកស្រី ឌឹម រ៉ាវី និង បុត្រ ៧០០០៛

៨៥ .ឧ.សិ. តាន់ គឹម សុង និង បុត្រ និង ចៅ ៧០០០៛

៨៦ .អ្នកស្រី ផាន់ ឡៃហ៊ាង ស្វាមី និង បុត្រ ៧០០០៛

៨៧ .លោកញ៉ែម មាន អ្នកស្រី ទន់ សង្វាន និង បុត្រ ៧០០០៛

៨៨ .ឧ.សិ. ឈី គឹម ហ៊ាង និង បុត្រ ៧០០០៛

៨៩ .លោក ឆ្លែម គឹម ណុច និង ភរិយា រៀម វាសនា ៧០០០៛

៩០. លោក យាំ លឿង និង ភរិយា ឡៅ វ៉ុន និង បុត្រ ៧០០០៛

៩១ .លោក ប៉េង ប៊ុនលាង និង ភរិយា និង បុត្រ ៧០០០៛

៩២ .លោក ប៉ុច សុវណ្ណារិទ្ធិ និង អ្នកស្រី ធារី ៧០០០៛

៩៣. ចែ មុំ ព្រមទាំងបុត្រ ៧០០០៛

៩៤. លោក តាន់ គឹមទាវ និង បុត្រ ៧០០០៛

៩៥. លោក ឌឹក សារុន ភរិយា និង បុត្រ ៧០០០៛

៩៦ .លោក ឌុក គា ភរិយា និង បុត្រ ៧០០០៛

៩៧. លោក ហោ សំណាង និង ហួន គឹមហ៊ុន និង បុត្រ ៧០០០រ

៩៨. តាន់ មុំ និង បុត្រ ៧០០០រ

៩៩ .អ្នកស្រី ពៅ ដាន់ និង ស្វាមី ៨៥០០រ

១០០ .ឧ.ស. ហ៊ុន ផារិន ឧ.សិ. ខឿវ យ៉ាន់ ៨៥០០រ

១០១. ឧ.ស. ងិន លារិន ឧ.សិ. រៀម សុខា ៥០០០រ

១០២. ឧ.សិ. ហួត គឹម ណៃត ៥០០០រ

១០៣ .អ្នកស្រី សៀម ចាន់រី ស្វាមី និង បុត្រ ៥០០០រ

១០៤. វ៉ាន់ នី ៣៥០០រ

១០៥ .លោក យាយ អ៊ុក ងិន ៣៥០០រ

១០៦ .នុត ពៅ ៣៥០០រ

១០៧. លោក ពូ ឃិន និង ថៃរី ៣៥០០រ

១០៨ .លោក ខេង សុភាព និង ភរិយា ៣៥០០រ

១០៩.លោក អាង ឡៃ ហាន់ និង ភរិយា និង បុត្រ ៣៥០០រ

១១០. លោក កែវ ណារិន និង ភរិយា និង បុត្រ ៣៥០០រ

១១១. នួន វណ្ណី និង ស្វាមី និង បុត្រ ៣៥០០រ

១១២. កញ្ញា ប៉ាន់ រដ្ឋា ៣៥០០៛

១១៣. ឧ.សិ. ឆាន់ ង៉ាន់ និង បុត្រ ៣៥០០៛

១១៤. អ្នកស្រី ឆាវ ស្រី វុទ្ធ និង ស្វាមី និង បុត្រ ៣៥០០៛

១១៥.លោក ស៊ិន ទូច និង ភរិយា និង បុត្រ ៣៥០០៛

១១៦ .ម៉ា ឆាន់ យ៉ោ និង បុត្រ ៣៥០០៛

១១៧ .ឧ.សិ. អ៊ូ ដាវី និង បុត្រ ៣៥០០៛

១១៨ .លោក ហេង ប៊ុន ឈឿង ភរិយា និង បុត្រ ៣៥០០៛

១១៩ .ឧ.សិ. ឡាយ ឈន និង បុត្រ ៣៥០០៛

១២០ .ឧ.សិ. អុំ ចាន់ គុណា ស្វាមី និង បុត្រ ៣៥០០៛

១២១. ឧ.សិ. គ្រុយ ចិន្តា និង ស្វាមី និង បុត្រ ៣៥០០៛

១២២. ឧ.សិ. ញឹក សាគ្រី និង បុត្រ ៣៥០០៛

១២៣. អ្នកស្រី យិន ធី និង ស្វាមី និង បុត្រ ៣៥០០៛

១២៤. លោកស្រី ស៊ាន ផលា និង បុត្រ ៣៥០០៛

១២៥ .លោកស្រី លី សុខខិដា និង បុត្រ ៣៥០០៛

១២៦ .អា នាង ២០០០៛

១២៧. សុខ ប៊ុនថា ៣៥០០រ

១២៨ .សួន ធីតា ស្វាមី និង បុត្រ ៣៥០០រ

១២៩. ស៊ី វន ១០០០រ

១៣០ .លោកគ្រូ យា ថន ភរិយា និង បុត្រ ២០០០០រ

១៣១ .ឧ.សិ. ស៊ុន លួមនិង បុត្រ ១០ក

១៣២ .ឧ.ស. ហេង វុទ្ធី និង បុត្រ ១០ក

១៣៣. ឧ.ស. ជា ហោ និង ឧ.សិ. ស៊ូ ហៀក ៣ក

១៣៤ .ឧ.សិ.ហេង ស៊ីនួន ព្រមទាំងបុត្រ ១ក

១៣៥ .ឧ.សិ.យឹម តន់ ព្រមទាំងបុត្រ ១ក

## (ពុទ្ធបរិស័ទខេត្តបាត់ដំបង)

១.លោកម្ចាស់ចិត្តប្បសន្នោ សៀ សុវណ្ណានី  ១០ក្បាល

២.អ្នកគ្រូ ប៉ែនផល្លីនិងកូនស្រីសុវណ្ណា   ២៥$(សៀមរាប)

៣.ឧ.សិ.គី វណ្ណហាក់ព្រមទាំងកូនចៅ

៤.ឧ.សិ.ទ្បេ រឿម   ៥ក្បាល

៥.ឧ.សិ.ថងកែវវិមាន   ២០ក្បាល

៦.ឧ.សិ.គិមចន្ថា(ពៅ)  ២០ក្បាល

៧.លោកតាម៉ៅ ហុង

៨.ឧ.ស.ជា ទិត្យ

៩.ឧ.សិ.ហុង ធិន   ៥ក្បាល

១០.ឧ.សិ.អ៊ឹម ចាន់ណា ៥ក្បាល

១១.ឧ.សិ.អ៊ឹម ចាន់ណាក់   ៥ក្បាល

១២.ឧ.សិ.សាន គឹមស៊ាង ៥ក្បាល

